ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
ក្រុមប្រឹក្សាជាតិគណនេយ្យ

# CIFRS 13

# ការវាស់វែងតម្លៃសមស្រប

## Fair Value Measurement

ក្រុមប្រឹក្សាស្តង់ដាគណនេយ្យអន្តរជាតិ
International Accounting Standards Board (IASB®)

IFRS™

# អារម្ភកថា

ដោយសារនយោបាយ “**ឈ្នះ-ឈ្នះ**” របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ប្រទេសកម្ពុជាសម្រេចបាននូវឯកភាពជាតិ, បូរណភាពទឹកដី, អធិបតេយ្យ, និងសុខសន្តិភាពពេញលេញទូទាំងប្រទេស ហើយបង្កើតបានជាបុរេលក្ខណៈសម្បត្តិសម្រាប់ពង្រឹងស្ថិរភាពនយោបាយ, សណ្តាប់ធ្នាប់សង្គម និងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ដែលបានលើកកម្ពស់ជីវភាព, សុខមាលភាព និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនជាបន្តបន្ទាប់។ ដើម្បីបន្ត និងពង្រឹងនូវវឌ្ឍនភាពនេះ រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានដាក់ចេញនិងធ្វើបច្ចុប្បន្នកម្មជាបន្តបន្ទាប់នូវផែនការ និងយុទ្ធសាស្ត្រមួយនានា ដូចជា “**យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី១, ទី២ និង ទី៣**”, “**ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨**”, “**យុទ្ធសាស្ត្រត្រីកោណ**”, “**យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ២០១១-២០២០**” និង “**យុទ្ធសាស្ត្រគៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨**” ព្រមទាំងធ្វើការកែទម្រង់លើគ្រប់វិស័យ ដែលក្នុងនោះ ការកែទម្រង់លើការគ្រប់គ្រងប្រព័ន្ធហិរញ្ញវត្ថុ និងប្រព័ន្ធគណនេយ្យ ទាំងក្នុងវិស័យសាធារណៈ ទាំងក្នុងវិស័យឯកជន ជាអទិភាពចម្បងមួយ។

**ច្បាប់ស្តីពីគណនេយ្យសហគ្រាស សវនកម្មគណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យ** ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧០២/០១១ ចុះថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ២០០២ និងក្រុមប្រឹក្សាជាតិគណនេយ្យ ដែលត្រូវបានបង្កើតឡើងដោយអនុក្រឹត្យលេខ ០៣ ខែ មីនា ឆ្នាំ ២០០៣ ជាក្របខ័ណ្ឌគតិយុត្ត និងក្របខ័ណ្ឌស្ថាប័ន ក្នុងទិសដៅអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ការកែទម្រង់គណនេយ្យនិងសវនកម្មឯកជន ដើម្បីបង្កើតនូវបរិយាកាសទីផ្សារប្រកួតប្រជែងប្រកបដោយតម្លាភាព សម្រាប់ជំរុញកំណើនធុរៈកិច្ច និងវិនិយោគឆ្លងប្រទេសនៅកម្ពុជា ។ ក្រុមប្រឹក្សាជាតិគណនេយ្យ (ក.ជ.គ) ដែលជាស្ថាប័នបញ្ញត្តិករ និងនិយ័តករនៅក្នុងវិស័យគណនេយ្យនិងសវនកម្ម មានភារកិច្ចចម្បងក្នុងការដាក់ឱ្យអនុវត្តស្តង់ដាគណនេយ្យ, ស្តង់ដាសវនកម្ម និងក្របខ័ណ្ឌទស្សនទានគណនេយ្យតាមស្ថានភាពជាក់ស្តែងនៃសេដ្ឋកិច្ចកម្ពុជា ដោយអនុលោមតាមស្តង់ដាអន្តរជាតិ និងការវិវឌ្ឍជាអន្តរជាតិនៅក្នុងវិស័យនេះ ។

សៀវភៅស្តីពី “**ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា** ” ត្រូវបានបកប្រែទាំងស្រុងចេញពីស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ ដែលបានចេញផ្សាយដោយក្រុមប្រឹក្សាស្តង់ដាគណនេយ្យអន្តរជាតិ (International Accounting Standard Board-IASB) ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការប្រើប្រាស់របស់សហគ្រាសអាជីវកម្មក្នុងការរៀបចំព័ត៌មានហិរញ្ញវត្ថុរបស់ខ្លួន សំដៅធានាបាននូវតម្លាភាព, គណនេយ្យភាព និងភាពអាចជឿទុកចិត្តបាននៃរបាយការណ៍ហិរញ្ញវត្ថុ។ ការអនុវត្តស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា គឺជាកាតព្វកិច្ចរបស់ម្ចាស់សហគ្រាស, គណនេយ្យករ

និងសវនករផងដែរ។ ការអនុវត្តស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា មិនត្រឹមតែរួម-ចំណែកលើកកម្ពស់ប្រសិទ្ធភាពនៃការប្រមូលពន្ធជូនរដ្ឋប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងផ្តល់ព័ត៌មានហិរញ្ញវត្ថុដ៏មានសារៈប្រយោជន៍ដល់អ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុនៅក្នុងការសម្រេចចិត្តពាក់ព័ន្ធនឹងការចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ចនានា ។

ការដាក់ឱ្យអនុវត្តស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា គឺជាផ្នែកមួយនៃយុទ្ធសាស្ត្រ និងជាផែនការនៃការកសាងហេដ្ឋារចនាសម្ព័ន្ធទីផ្សារហិរញ្ញវត្ថុ ក្នុងផ្នែកអភិបាលកិច្ចសាជីវកម្ម និងហេដ្ឋារចនាសម្ព័ន្ធនៃ "**យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១១-២០២០**" របស់រាជរដ្ឋា-ភិបាលកម្ពុជា ដែលបានទទួលការអនុម័តពីគណៈរដ្ឋមន្ត្រីនៅក្នុងកិច្ចប្រជុំពេញអង្គ នាថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១១។

ក្នុងនាមក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ខ្ញុំសូមវាយតម្លៃខ្ពស់ និង សម្តែងនូវការកោតសរសើរដ៏ស្មោះចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ឯកឧត្តម **ងី តាយី** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាជាតិគណនេយ្យ និងសមាជិកក្រុមប្រឹក្សាជាតិគណនេយ្យទាំងអស់ ព្រមទាំងថ្នាក់ដឹកនាំ និងមន្ត្រីនៃលេខាធិការដ្ឋាន ក.ជ.គ ដែលបានខិតខំពុះពារគ្រប់ឧបសគ្គ និងលះបង់ពេលវេលា, ធនធាន និងកំលាំងកាយចិត្ត ក្នុងការធ្វើឱ្យឯកសារដ៏មានតម្លៃនេះលេចចេញជារូបរាងឡើង។

*រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៥*

**រដ្ឋមន្ត្រី**

**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

បណ្ឌិត **អូន ព័ន្ធមុនីរ័ត្ន**

# អារម្ភកថា

យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា បានរំលេចនូវទិសដៅចម្បង៤ គឺកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព ព្រមទាំងបានបង្ហាញយ៉ាងច្បាស់នូវគោលបំណងចម្បងរបស់រាជរដ្ឋាភិបាល ក្នុងការសម្រេចបាននិងការរក្សានូវកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព រួមទាំងកិច្ចអភិវឌ្ឍន៍សង្គមកិច្ចមួយដ៏រឹងមាំនិងជានិរន្តន៍ ដែលធានាកម្រិតជីវភាពនិងសុខដុមភាពរបស់ប្រជាជនឱ្យប្រសើរឡើងជាលំដាប់។ នៅក្នុងបរិការណ៍នេះ វិស័យគណនេយ្យនិងសវនកម្មមានតួនាទីយ៉ាងសំខាន់នៅក្នុងជីវិតសេដ្ឋកិច្ចនិងសង្គម ពិសេសនៅក្នុងការធានាភាពត្រឹមត្រូវច្បាស់លាស់, តម្លាភាព, គណនេយ្យភាព និងអភិបាលកិច្ចល្អ ក្នុងការគ្រប់គ្រងកិច្ចប្រតិបត្តិការហិរញ្ញវត្ថុ ទាំងក្នុងវិស័យសាធារណៈនិងវិស័យឯកជន។ អាស្រ័យហេតុនេះ រាជរដ្ឋាភិបាលបាន ចាត់ទុកវិស័យគណនេយ្យនិងសវនកម្មនេះ ជាផ្នែកមួយដ៏សំខាន់នៅក្នុងការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុរបស់ជាតិ ដូចមានចែងនៅក្នុង “**យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០១១-២០២០**”។

អនុវត្តតាមស្មារតីនៃយុទ្ធសាស្ត្រខាងលើ រាជរដ្ឋាភិបាលកម្ពុជា ដែលមានក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាសេនាធិការ បានជំរុញការអភិវឌ្ឍន៍វិស័យនេះយ៉ាងសកម្ម ផ្តើមចេញពីការកសាងមូលដ្ឋានគ្រឹះសម្រាប់ការចុះកិច្ចបញ្ជិកាគណនេយ្យនិងការធ្វើសវនកម្ម តាមរយៈការរៀបចំនិងដាក់ឱ្យប្រើនូវច្បាប់ស្តីពី “គណនេយ្យសហគ្រាស សវនកម្មគណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យ” នៅឆ្នាំ២០០២។ ផ្អែកតាមស្មារតីនៃច្បាប់ខាងលើ ក្នុងខែមករា ឆ្នាំ២០០៩ ស្តង់ដារគណនេយ្យកម្ពុជា ដែលរួមមាន “*ស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា* ” និង “*ស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូចនិងមធ្យម*” ត្រូវបានដាក់ឱ្យប្រើដោយប្រកាស*លេខ ០៦៨ ស.ហ.វ-ប្រ.ក ចុះថ្ងៃទី៨ ខែមករា ឆ្នាំ២០១៥*។ ក្នុងន័យនេះ សហគ្រាសសាធារណៈនិងក្រុមហ៊ុនឯកជននានាដែលកំពុងធ្វើប្រតិបត្តិការអាជីវកម្មនៅកម្ពុជា ត្រូវប្រើស្តង់ដាគណនេយ្យកម្ពុជាដើម្បីធ្វើជាមូលដ្ឋានសារវន្តនិងជាក្របខ័ណ្ឌសម្រាប់រៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួនដើម្បីធានាបាននូវតម្លាភាព គណនេយ្យភាព និងភាពអាចជឿទុកចិត្តបានលើរបាយការណ៍ហិរញ្ញវត្ថុពីសំណាក់អ្នកប្រើប្រាស់និងសាធារណៈជន ហើយក៏អាចជាបច្ច័យមួយជួយជំរុញកំណើនចំណូលសារពើពន្ធ និងជួយគាំទ្រដល់វឌ្ឍភាពនិងស្ថេរភាពនៃទីផ្សារហិរញ្ញវត្ថុ ក៏ដូចជាជួយជំរុញកំណើនសេដ្ឋកិច្ចជាតិ។

អាស្រ័យហេតុនេះ ខ្ញុំសូមលើកទឹកចិត្តសហគ្រាសដែលមានការពាក់ពន្ធ័ ឱ្យអនុវត្តស្តង់ដាដែលមាននៅក្នុងសៀវភៅនេះដើម្បីរៀបចំរបាយការណ៍ហិរញ្ញវត្ថុទាំងសម្រាប់ការគ្រប់គ្រងផ្ទៃក្នុងនិងសម្រាប់ការដាក់បង្ហាញទៅអ្នកដែលមានការពាក់ព័ន្ធនានា។

*រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥*

**រដ្ឋលេខាធិការ**

**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជា**

**ប្រធានក្រុមប្រឹក្សាជាតិគណនេយ្យ**

**វី តាយី**

១ ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុនេះ÷

(ក) កំណត់អត្ថន័យតម្លៃសមស្រប

(ខ) កំណត់នៅក្នុងក្របខណ្ឌទស្សនទានតែមួយសម្រាប់ការវាស់វែងតម្លៃសមស្រប និង

(គ) តម្រូវការលាតត្រដាងព័ត៌មានអំពីការវាស់វែងតម្លៃសមស្រប។

២ តម្លៃសមស្រមបគឺជាការវាស់វែងដែលផ្អែកលើទីផ្សារ មិនមែនជាការវាស់វែងដែលផ្អែកលើអង្គភាពណាមួយឡើយ។ សម្រាប់ទ្រព្យសកម្មនិងបំណុលខ្លះ ប្រតិបត្តិការទីផ្សារ ដែលអាចអង្កេតបាន ឬព័ត៌មានទីផ្សារអាចរកបាន។ សម្រាប់ទ្រព្យសកម្ម និងបំណុលខ្លះ ប្រតិបត្តិការទីផ្សារដែលអាចអង្កេតបាន ឬព័ត៌មានទីផ្សារមិនអាចរកបាន។ ទោះជាយ៉ាងណា កម្មវត្ថុនៃការវាស់វែងតម្លៃសមស្រប នៅក្នុងករណីទាំងពីរគឺ ដូចគ្នាដើម្បីប៉ាន់ស្មានថ្លៃដែលប្រតិបត្តិការមានការ*ជាប្រព័ន្ធ* ដើម្បីលក់ទ្រព្យសកម្ម ឬដើម្បីផ្ទេរបំណុលនឹងកើតឡើង រវាង*អ្នកចូលរួមទីផ្សារ*នាកាលបរិច្ឆេទនៃការវាស់វែងតាមលក្ខខណ្ឌទីផ្សារបច្ចុប្បន្ន (មានន័យថា ថ្លៃចុងគ្រានាកាលបរិច្ឆេទនៃការវាស់វែងដែលឈរលើទស្សនទានរបស់អ្នកចូលរួមទីផ្សារដែលកាន់កាប់ទ្រព្យសកម្មឬមានជំពាក់បំណុល)។

៣ នៅពេលដែលថ្លៃរបស់ទ្រព្យសកម្មស្រដៀងគ្នា ឬបំណុលស្រដៀងគ្នា មិនអាចអង្កេតបាន អង្គភាពវាស់វែងតម្លៃសមស្របដោយ ប្រើបច្ចេកទេស នៃ

ការវាយតម្លៃ ដែលធ្វើឱ្យអតិបរមា នូវការប្រើប្រាស់*ធាតុចូល ពាក់ ពន្ធ័ ដែលអាចអង្កេតបាន* និងអប្បបរមាការប្រើប្រាស់*ធាតុចូល ដែល មិនអាច អង្កេតបាន*។ ដោយសារតែ តម្លៃសមស្របគឺជាការវាស់វែងផ្អែក លើទីផ្សារ វាត្រូវបានវាស់វែងដោយ ប្រើសម្មតិកម្ម ដែលអ្នកចូលរួមទីផ្សារ នឹងប្រើ ប្រាស់នៅពេលកំណត់ថ្លៃលក់របស់ទ្រព្យសកម្ម ឬបំណុល ដោយ មានទាំង សម្មតិកម្មអំពីហានិភ័យផងដែរ។ជាលទ្ធផលចេតនារបស់អង្គភាព ដើម្បី កាន់កាប់ ឬលក់ទ្រព្យសកម្ម ឬដើម្បីបំពេញកាតព្វកិច្ចបំណុល នឹង មិនមាន ការពាក់ពន្ធ័ឡើយ នៅពេល វាស់វែងតម្លៃសមស្រប។

៤ និយមន័យនៃតម្លៃសមស្របផ្តោតលើទ្រព្យសកម្មនិងបំណុល ពីព្រោះពួក វាគឺជាវត្ថុដ៏ចំបងនៃការវាស់វែងគណនេយ្យ។ ជាការបន្ថែមស្តង់ដារបាយ ការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនេះ ត្រូវតែអនុវត្តចំពោះឧបករណ៍ ហិរញ្ញវត្ថុមូលធនផ្ទាល់របស់អង្គភាព ដែលវាស់វែងតាមតម្លៃសមស្រប។

## ក្របខណ្ឌ

**៥ ស្តង់ដារបាយការណ៍ទាក់ទងហិរញ្ញវត្ថុអន្តរជាតិនេះអនុវត្តនៅពេល ដែល ស្ត ង់ដារបាយការណ៍ទាក់ទងហិរញ្ញវត្ថុអន្តរជាតិផ្សេងទៀតតម្រូវ ឬអនុញ្ញាត្តិ ឱ្យ មានការវាស់វែងតម្លៃសមស្រប ឬការលាតត្រដាងអំពី ការវាស់វែងតម្លៃ សម ស្រប (និងការវាស់វែង ឧទាហរណ៍ តម្លៃសមស្របដកតម្លៃដើមលក់ ចេញ ដោយផ្អែកលើតម្លៃសមស្រប ឬការលាតត្រដាងអំពីការវាស់វែងទាំង នោះ) លើកលែងតែ បានបញ្ជាក់នៅក្នុងកថាខណ្ឌ៦ និងកថាខណ្ឌ៧។**

៦ ការវាស់វែង និងការតម្រូវ សម្រាប់ការលាតត្រដាងរបស់ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនេះមិនអនុវត្ត ចំពោះករណីដូចខាងក្រោម:

(ក) ប្រតិបត្តិការនៃការទូទាត់ផ្អែកលើប័ណ្ណភាគហ៊ុននៅក្នុងក្របខណ្ឌនៃស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ ២ *ការទូទាត់ផ្អែកលើបណ្ណ័ភាគហ៊ុន,*

(ខ) ប្រតិបត្តិការភតិសន្យាក្នុងក្រខណ្ឌស្តង់ដាគណនេយ្យអន្តរជាតិ១៧ *ភតិសន្យា* និង

(គ) ការវាស់វែងដែលមានភាពស្រដៀងគ្នានឹងតម្លៃសមស្រប ប៉ុន្តែមិនមែនជាតម្លៃសមស្រប ដូចជាតម្លៃពិតអាចទទួលស្គាល់នៅក្នុងស្តង់ដារគណនេយ្យអន្តរជាតិ ២សន្និធិ ឬ តម្លៃដែលប្រើនៅក្នុងស្តង់ដាគណនេយ្យអន្តរជាតិ ៣៦ *ការថយចុះតម្លៃរបស់ទ្រព្យសកម្ម*។

៧ ការលាតត្រដាងដែលតម្រូវដោយស្តង់ដារបាយការណ៍ទាក់ទងហិរញ្ញវត្ថុអន្តរជាតិនេះ មិនតម្រូវចំពោះ ករណីដូចខាងក្រោម:

(ក) ទ្រព្យសកម្មនៅក្នុងផែនការដែលវាស់វែងតាមតម្លៃសមស្របដោយអនុលោម តាមស្តង់ដាគណនេយ្យអន្តរជាតិ ១៩ *អត្ថប្រយោជន៍បុគ្គលិក*

(ខ) ការវិនិយោគនៅក្នុងផែនការអត្ថប្រយោជន៍សម្រាប់ការចូលនិវត្តន៍ដែលវាស់វែង តាមតម្លៃសមស្រប ដោយអនុលោមតាមស្តង់ដាគណនេយ្យអន្តរជាតិ ២៦ *គណនេយ្យនិងការរាយការណ៍ តាមផែនការអត្ថប្រយោជន៍សម្រាប់ការចូលនិវត្តន៍* និង

(គ) ទ្រព្យសកម្មដែលបរិមាណ ដែលអាចទទួលបានគឺស្មើនឹងតម្លៃសម ស្រេបដកនឹងតម្លៃដើមនៃការលក់ចោល ដោយអនុលោមតាមស្តង់ដារគណនេយ្យអន្តរជាតិ ៣៦។

៨ ក្របខណ្ឌនៃការវាស់វែងតម្លៃសមស្រេបបានបរិយាយនៅក្នុងស្តង់ដា របាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនេះ អនុវត្តទាំងការវាស់វែង ដំបូង និងការវាស់វែងជាបន្តបន្ទាប់ទៀត ប្រសិនបើតម្លៃសមស្រេបត្រូវបាន តម្រូវ ឬត្រូវបានអនុញ្ញាតិដោយស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិផ្សេងទៀត។

## ការវាស់វែង

### និយមន័យនៃតម្លៃសមស្រប

**៩ ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនេះកំណត់និយមន័យតម្លៃសមស្រប ថាជាថ្លៃដែលនឹងទទួលបានដោយការលក់ទ្រព្យសកម្ម ឬថ្លៃដែលបានសងចំពោះការផ្ទេរបំណុល នៅក្នុងប្រតិបត្តិការជា ប្រព័ន្ធិក រវាងអ្នកចូលរួមទីផ្សារនានានៅកាលបរិច្ឆេទនៃការវាស់វែង។**

១០ កថាខណ្ឌ ខ២ បរិយាយវិធីសាស្ត្រនៃការវាស់វែងតម្លៃសមស្របរួម។

### ទ្រព្យសកម្ម ឬ បំណុល

១១ ការវាស់វែងតម្លៃសមស្របគឺធ្វើឡើងសម្រាប់ទ្រព្យសកម្មនិងបំណុល ពិសេសណាមួយប៉ុណ្ណោះ។ ដូច្នេះ នៅពេលវាស់វែងតម្លៃសមស្រប អង្គភាពត្រូវរាប់បញ្ចូលនូវរាល់ចរិតលក្ខណៈរបស់ទ្រព្យសកម្ម ឬបំណុល នៅកាលបរិច្ឆេទ នៃការវាស់វែង។ ចរិតលក្ខណៈទាំងនោះ ជាឧទាហរណ៍ រួមមានដូចខាង ក្រោមៈ

(ក) លក្ខខណ្ឌនិងទីតាំងរបស់ទ្រព្យសកម្ម និង

(ខ) **ការដាក់កំហិត ប្រសិនបើមានលើការលក់និងការប្រើប្រាស់ទ្រព្យសកម្មនោះ។**

១២ ផលប៉ះពាល់លើការវាស់វែងកើតឡើង ពីចរិតលក្ខណៈពិសេស ខុសប្លែក ពីគ្នាអាស្រ័យលើរបៀបដែលចរិតលក្ខណៈនោះត្រូវបានរាប់បញ្ចូល ដោយអ្នកចូលរួមទីផ្សារ។

១៣ ទ្រព្យសកម្មឬបំណុលដែលវាស់វែងតាមតម្លៃសមស្របអាចមាន ដូចខាងក្រោមៈ

(ក) ទ្រព្យសកម្មឬបំណុលតែម្នាក់ឯង (ឧ.ឧបករណ៍ហិរញ្ញវត្ថុឬទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ) ឬ

(ខ) ក្រុមនៃទ្រព្យសកម្ម ក្រុមនៃបំណុល ឬក្រុមនៃទ្រព្យសកម្មនិងបំណុល (ឧ. អង្គ ឬអាជីវកម្មបង្កើតសាច់ប្រាក់)។

១៤ ទោះបីជាទ្រព្យសកម្ម ឬបំណុលតែម្នាក់ឯង ក្រុមនៃទ្រព្យសកម្ម ក្រុមនៃបំណុល ឬក្រុមនៃទ្រព្យសកម្មនិងបំណុលសម្រាប់គោលបំណងនៃការទទួលស្គាល់ ឬគោលបំណងនៃការលាតត្រដាង អាស្រ័យលើចំណែកនៃគណនី (unit of account)។ ចំណែកនៃគណនីរបស់ទ្រព្យសកម្ម ឬបំណុលត្រូវតែកំណត់ដោយ អនុលោមតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ ដែលតម្រូវឬអនុញ្ញាតិនូវការវាស់វែង តម្លៃសមស្របលើកលែងតែអ្វីដែលបានផ្តល់ឱ្យនៅក្នុងស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុនេះ។

## ប្រតិបត្តិការ

១៥ **ការវាស់វែងតម្លៃសមស្របសន្មតថា ទ្រព្យសកម្មឬបំណុលត្រូវបានដោះដូរនៅក្នុងប្រតិបត្តិការជាប្រព័ន្ធរវាងអ្នកចូលរួមក្នុងទីផ្សារដើម្បីលក់ទ្រព្យ**

**សកម្មឬផ្ទេរបំណុលនាកាលបរិច្ឆេទនៃការវាស់វែងតាមលក្ខខណ្ឌទីផ្សារ បច្ចុប្បន្ន។**

**១៦ ការវាស់វែងតម្លៃសមស្របសន្មតថា ប្រតិបត្តិការលក់ ឬផ្ទេរបំណុលកើត ឡើង:**

**(ក) នៅក្នុងទីផ្សារគោល (principal market) សម្រាប់ទ្រព្យសកម្ម ឬបំណុល, ឬ**

**(ខ) នៅពេលមិនមានទីផ្សារគោល, ទីផ្សារជាអាទិភាពបំផុត(most advantageous market) សម្រាប់ទ្រព្យសកម្ម ឬបំណុល។**

១៧ អង្គភាពមិនចាំបាច់ធ្វើការស្រាវជ្រាវដិតដល់ពេកអំពីទីផ្សារដែលអាចកើតមានទាំងអស់ ដើម្បីកំណត់ទីផ្សារគោល ឬក្នុងករណីមិនមានទីផ្សារគោល គឺកំណត់រកទីផ្សារជាអាទិភាពបំផុត ប៉ុន្តែ អង្គភាពត្រូវរាប់បញ្ចូលនូវរាល់ព័ត៌មានទាំងអស់ដែលអាចរកបានដោយសមរម្យ។ នៅពេលមិនមានភ័ស្តុតាងផ្ទុយពីនេះ ទីផ្សារដែលអង្គភាពតែងមានប្រតិបត្តិការលក់ទ្រព្យសកម្ម ឬផ្ទេរបំណុល ត្រូវបានគេសន្មតទុកជាមុនថាជាទីផ្សារគោល ឬក្នុងករណីមិនមានទីផ្សារគោល គឺយកទីផ្សារជាអាទិភាពបំផុត។

១៨ ប្រសិនបើមានទីផ្សារគោលសម្រាប់ទ្រព្យសកម្មឬបំណុល ការវាស់វែងតម្លៃសមស្របត្រូវបង្ហាញនូវថ្លៃនៅក្នុងទីផ្សារនោះ (ទោះបីជាថ្លៃនោះអាចអង្កេតបាន ឬប៉ាន់ស្មានដោយផ្ទាល់ដោយប្រើវិធីសាស្ត្រនៃការ វាយតម្លៃផ្សេង ក៏ដោយ) បើទោះបីជាថ្លៃនៅក្នុងទីផ្សារផ្សេងទៀត មានអាទិភាពជាងនា កាលបរិច្ឆេទនៃការ វាស់វែងក៏ដោយ។

១៩ អង្គភាពត្រូវមានលទ្ធភាពទៅកាន់ទីផ្សារគោល (ឬទីផ្សារជាអាទិភាពបំផុត) នាកាលបរិច្ឆេទ នៃការវាស់វែង។ ដោយសារតែអង្គភាពខុសៗគ្នា (និង

អាជីវកម្មនៅក្នុងអង្គភាពទាំងនោះ) មានសកម្មភាពខុសៗគ្នា អាចមានលទ្ធភាពទៅកាន់ទីផ្សារផ្សេងៗគ្នា, ទីផ្សារគោល (ទីផ្សារជាអាទិភាពបំផុត) សម្រាប់ទ្រព្យសកម្មឬបំណុលដូចគ្នាអាចមានភាពខុសគ្នា សម្រាប់អង្គភាពខុសគ្នា (និងហេតុដូច្នេះ អ្នកចូលរួមទីផ្សារ)ត្រូវពិចារណាអំពីទស្សនវិស័យរបស់អង្គភាព ដោយអនុញ្ញាតិឲ្យមានភាពខុសគ្នារវាង និងក្នុងចំណោមអង្គភាព ដែលមានសកម្មភាពខុសគ្នា។

២០ បើទោះបីជាអង្គភាពត្រូវតែអាចមានលទ្ធភាពទៅកាន់ទីផ្សារ អង្គភាពមិនចាំបាច់ត្រូវតែអាចលក់ទ្រព្យសកម្ម ឬផ្ទេរបំណុលដ៏ជាក់លាក់មួយ នាកាលបរិច្ឆេទនៃការវាស់វែងដើម្បីអាចវាស់វែងតម្លៃសមស្រប ដោយផ្អែកលើថ្លៃនៅក្នុងទីផ្សារនោះ។

២១ ទោះបីជានៅពេលដែលមិនមានទីផ្សារដែលអាចអង្កេតបាន ដើម្បីផ្តល់នូវព័ត៌មានការកំណត់ថ្លៃស្តីពីការលក់ទ្រព្យសកម្ម ឬការផ្ទេរបំណុល នាកាលបរិច្ឆេទនៃការវាស់វែង ការវាស់វែងតម្លៃសមស្របសន្មតថា ប្រតិបត្តិការកើតឡើងនាកាលបរិច្ឆេទនោះ ដោយបានពិចារណាពីទស្សនទាននៃអ្នកចូលរួមទីផ្សារមួយដែលកាន់កាប់ទ្រព្យសកម្ម ឬមានជំពាក់បំណុល។ ប្រតិបត្តិការបានសន្មតនោះកសាងបាននូវមូលដ្ឋាននៃការប៉ាន់ស្មានថ្លៃ សម្រាប់លក់ទ្រព្យសកម្ម ឬការផ្ទេរបំណុល។

## **អ្នកចូលរួមទីផ្សារ**

**២២ អង្គភាពត្រូវវាស់វែងតម្លៃសមស្របរបស់ទ្រព្យសកម្មឬបំណុល ដោយប្រើការសន្មតថា អ្នកចូលរួមទីផ្សារនឹងប្រើវានៅពេលកំណត់ថ្លៃទ្រព្យសកម្ម ឬ**

**បំណុល ដោយសម្មតថាអ្នកចូលរួមទីផ្សារធ្វើសកម្មភាព ដោយយោងតាមផលប្រយោជន៍សេដ្ឋកិច្ចដ៏ល្អបំផុតរបស់ខ្លួន ។**

២៣ នៅក្នុងការបង្កើតសន្ទតិកម្មទាំងនោះ អង្គភាពមិនចាំបាច់កំណត់អ្នកចូលរួមទីផ្សារជាក់លាក់ឡើយ។ ផ្ទុយទៅវិញ អង្គភាពត្រូវកំណត់ចរិតកលក្ខណៈដែលធ្វើឱ្យខុសគ្នាជាទូទៅរបស់អ្នកចូលរួមទីផ្សារ ដោយពិចារណាកត្តាជាក់លាក់នានាដែលមានចំពោះធាតុទាំងអស់ដូចខាងក្រោមៈ

(ក) ទ្រព្យសកម្មឬបំណុល

(ខ) ទីផ្សារគោល (ឬទីផ្សារអាទិភាពបំផុត) សម្រាប់ទ្រព្យសកម្មឬបំណុល និង

(គ) អ្នកចូលរួមទីផ្សារ ដែលអង្គភាពនឹងមានប្រតិបត្តិការ ជាមួយនៅក្នុង ទីផ្សារនោះ ។

### ថ្លៃលក់

២៤ **តម្លៃសមស្របគឺជាថ្លៃដែលនឹងត្រូវបានទទួលចំពោះការលក់ទ្រព្យសកម្ម ឬថ្លៃដែលត្រូវបង់ចំពោះការផ្ទេរ បំណុលនៅក្នុងប្រតិបត្តិការប្រព័ន្ធ** (orderly transaction) **មួយនៅក្នុងទីផ្សារគោល (ឬទីផ្សារអាទិភាពបំផុត) នាកាលបរិច្ឆេទនៃការវាស់វែងតាមលក្ខខណ្ឌទីផ្សារបច្ចុប្បន្ន(មានន័យថា ថ្លៃបិទទីផ្សារ) ដោយមិនគិតថាតើ ថ្លៃនោះអាចត្រូវបានអង្កេតដោយផ្ទាល់ ឬ ដោយប៉ាន់ស្មានដោយប្រើបច្ចេកទេសវាយតម្លៃផ្សេងទៀត។**

២៥ ថ្លៃលក់នៅក្នុងទីផ្សារគោល (ឬ ទីផ្សារដែលមានអាទិភាពបំផុត) បានប្រើដើម្បីវាស់វែងតម្លៃសមស្របរបស់ទ្រព្យសកម្ម ឬបំណុល មិនត្រូវបានកែសម្រួលសម្រាប់ចំណាយប្រតិបត្តិការឡើយ។ចំណាយប្រតិបត្តិការត្រូវបាន

រាប់បញ្ចូលដោយអនុលោមតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិផ្សេងទៀត។ ចំណាយប្រតិបត្តិការមិនមែនជាចរិតលក្ខណៈ នៃទ្រព្យសកម្ម ឬបំណុលឡើយ ប៉ុន្តែពួកវាមានលក្ខណៈជាក់លាក់ចំពោះប្រតិបត្តិការមួយនិងខុសៗគ្នាអាស្រ័យលើរបៀបនៃការកើតឡើងប្រតិបត្តិ-ការសម្រាប់ទ្រព្យសកម្ម ឬបំណុលរបស់អង្គភាព។

២៦ ចំណាយប្រតិបត្តិការមិនរាប់បញ្ចូលជាចំណាយដឹកជញ្ជូនឡើយ។ ប្រសិនបើ ទីតាំងគឺជាចរិតលក្ខណៈរបស់ទ្រព្យសកម្ម (ឧទាហរណ៍ ក្នុងករណីជា កុំម៉ូឌីធី (Commodity) ថ្លៃលក់នៅក្នុងទីផ្សារគោល (ឬទីផ្សារដែលមាន អាទិភាពបំផុត) នឹងត្រូវតែកែសម្រួលសម្រាប់ចំណាយនោះ ប្រសិនបើកើតមានដោយត្រូវដឹកជញ្ជូនទ្រព្យសកម្មនោះពីទីតាំងបច្ចុប្បន្នទៅទីផ្សារនោះ។

**ការអនុវត្តន៍ចំពោះទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ**

**ការប្រើខ្ពស់បំផុតនិងល្អបំផុតនៃទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ**

**២៧ ការវាស់វែងតម្លៃសមស្របនៃទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុរាប់បញ្ចូលនូវលទ្ធភាពរបស់អ្នកចូលរួមទីផ្សារ ដើម្បីបង្កើតអត្ថប្រយោជន៍សេដ្ឋកិច្ច ដោយប្រើទ្រព្យសកម្មនៅក្នុង*កម្រិតខ្ពស់បំផុតនិងល្អបំផុត* ឬដោយការលក់ ទ្រព្យសកម្មទៅអ្នកចូលរួមទីផ្សារម្នាក់ផ្សេងទៀតដែលនឹងប្រើទ្រព្យសកម្មនៅក្នុងកម្រិតខ្ពស់បំផុតនិងល្អបំផុត។**

២៨ ការប្រើខ្ពស់បំផុត និងល្អបំផុតនៃទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុរាប់បញ្ចូលនូវការប្រើទ្រព្យសកម្ម ដែលអាចមានរូបរាងជាក់លាក់ អាចអនុញ្ញាតិដោយច្បាប់ និងអាចមានលទ្ធផលផ្នែកហិរញ្ញវត្ថុ ដូចខាងក្រោមៈ

(ក) ការប្រើដែលអាចមានរូបរាងជាក់លាក់ រាប់បញ្ចូលនូវចរិតលក្ខណៈនៃរូបរាងរបស់ទ្រព្យសកម្ម ដែលអ្នកចូលរួមទីផ្សារនឹងរាប់បញ្ចូលនៅក្នុងការកំណត់ថ្លៃទ្រព្យសកម្ម (ឧ. ទីតាំងឬទំហំរបស់អចលនទ្រព្យ)។

(ខ) ការប្រើដែលអាចអនុញ្ញាតិដោយច្បាប់រាប់បញ្ចូលនូវការកំហិត តាមផ្លូវច្បាប់លើការប្រើប្រាស់ទ្រព្យសកម្ម ដែលអ្នកចូលរួមទីផ្សារនឹងដាក់បញ្ចូល នៅពេលកំណត់ថ្លៃទ្រព្យសកម្ម (ឧ. ច្បាប់កំណត់អំពីតំបន់ដែលអាចប្រើប្រាស់បានចំពោះអចលនទ្រព្យមួយ)។

(គ) ការប្រើដែលអាចមានលទ្ធផលហិរញ្ញវត្ថុ រាប់បញ្ចូលនូវការប្រើទ្រព្យសកម្មដែលអាចមានរូបរាងជាក់លាក់និងអាចមានការអនុញ្ញាតិ តាមផ្លូវច្បាប់ ដើម្បីបង្កើតចំណូល ឬលំហូរសាច់ប្រាក់គ្រប់គ្រាន់ (ដាក់បញ្ចូល នូវថ្លៃដើមនៃការបំប្លែងទ្រព្យសកម្ម ឱ្យទៅជាការប្រើប្រាស់នោះ) ដើម្បីបង្កើតបានផលចំណេញពី ការវិនិយោគដែលអ្នកចូលរួម

ទីផ្សារ ទាមទារពីការវិនិយោគនៅក្នុងទ្រព្យសកម្ម ដែលដាក់ឱ្យប្រើនោះ។

២៩ ការប្រើខ្ពស់បំផុតនិងល្អបំផុតត្រូវបានកំណត់ផ្អែកលើទស្សនទានរបស់អ្នកចូលរួមទីផ្សារ បើទោះបីជាអង្គភាពមានចង់មានការប្រើប្រាស់ផ្សេងពីនេះ។ ទោះជាយ៉ាងណា ការប្រើប្រាស់បច្ចុប្បន្ននៃទ្រព្យសកម្មរបស់អង្គភាពត្រូវបានសន្មតជាមុនថា វាជាការប្រើប្រាស់ខ្ពស់បំផុតនិងល្អបំផុត ដរាបណា ទីផ្សារ ឬកត្តា ផ្សេងទៀតបង្ហាញថា ការប្រើប្រាស់ផ្សេងទៀត ដោយអ្នក ចូលរួមទីផ្សារនឹងបង្កើតបានជាអតិបរមាតម្លៃរបស់ទ្រព្យសកម្ម។

៣០ ដើម្បីការពារស្ថានភាពប្រកួតប្រជែងរបស់ខ្លួន ឬសម្រាប់ហេតុផលផ្សេងទៀត អង្គភាពអាចមិនមានបំណង ប្រើទ្រព្យសកម្ម ដែលបានដោយ សកម្មឡើយ ឬអង្គភាពអាចមិនមានបំណងប្រើទ្រព្យសកម្មដោយយោង តាមការប្រើខ្ពស់បំផុតនិងល្អបំផុតនោះឡើយ។ ឧទាហរណ៍ វាអាចជាករណី នៃការទិញទ្រព្យ សកម្មអរូបិយដែលអង្គភាពមានគម្រោងប្រើ ដើម្បីជា ការពារដោយរារាំងអ្នកផ្សេងទៀតមិនឱ្យប្រើទ្រព្យសកម្មនោះ។យ៉ាងណាក៏ដោយ អង្គភាពត្រូវវាស់វែងតម្លៃសមស្របរបស់ទ្រព្យសកម្មមិនមែនហិរញ្ញ-វត្ថុ ដោយសន្មតការប្រើខ្ពស់បំផុតនិងល្អបំផុតដោយអ្នកចូលរួមទីផ្សារ។

## ការសន្មតនៃការវាយតម្លៃសម្រាប់ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ

៣១ ការប្រើខ្ពស់បំផុត និងល្អបំផុតសម្រាប់ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុបង្កើតបានជាការសន្មត នៃការវាយតម្លៃដែលបានប្រើ ដើម្បីវាស់វែងតម្លៃសមស្របរបស់ទ្រព្យសកម្ម ដូចខាងក្រោមៈ

(ក) ការប្រើខ្ពស់បំផុតនិងល្អបំផុត នៃទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុអាច ផ្តល់តម្លៃអតិបរមា ចំពោះអ្នកចូលរួមទីផ្សារតាមរយៈការប្រើរបស់វា នៅក្នុងការគួបផ្សំ ជាមួយទ្រព្យសកម្មផ្សេងទៀត ដើម្បីឱ្យទៅជាក្រុម (ដូចបានរៀបចំតម្លើង ឬមិនដូច្នោះទេមានរូបសណ្ឋានសម្រាប់ជាការ ប្រើប្រាស់) ឬនៅក្នុងការគួបផ្សំជាមួយទ្រព្យសកម្មនិងបំណុលផ្សេងៗ
ទៀត (ឧ. អាជីវកម្មមួយ)។

(១) ប្រសិនបើ ការប្រើខ្ពស់បំផុតនិងល្អបំផុតរបស់ទ្រព្យសកម្ម គឺត្រូវប្រើទ្រព្យសកម្មគួបផ្សំជា មួយនឹងទ្រព្យសកម្មផ្សេង ឬជាមួយទ្រព្យសកម្មនិងបំណុលផ្សេងៗទៀត តម្លៃសមស្របរបស់ ទ្រព្យសកម្មគឺជាថ្លៃ ដែលនឹងត្រូវទទួលបាននៅក្នុងប្រតិបត្តិការបច្ចុប្បន្ននៃការលក់ទ្រព្យសកម្ម ដោយសន្មតថាទ្រព្យសកម្មនោះនឹងត្រូវប្រើជាមួយទ្រព្យសកម្មផ្សេងទៀតឬជាមួយនឹងទ្រព្យសកម្ម ឬបំណុលផ្សេងទៀត និងសន្មតថាទ្រព្យសកម្ម និងបំណុលទាំងនោះ (មានន័យថាទ្រព្យសកម្មដែលបន្ថែមរបស់វាជាមួយនឹងបំណុលពាក់ពន្ធ័) នឹងអាចរកបានដោយអ្នកចូលរួមទីផ្សារ។

(២) បំណុលពាក់ពន្ធ័ជាមួយនឹងទ្រព្យសកម្មនោះនិងជាមួយទ្រព្យសកម្មបន្ថែម រួមមាន បំណុលដែលផ្តល់ជាទុនបង្វិល ប៉ុន្តែមិនរាប់បញ្ចូលជាមួយបំណុលដែលបានប្រើសម្រាប់ផ្តល់ទុនជាទ្រព្យសកម្មដែលមិននៅក្នុងក្រុមនៃទ្រព្យសកម្មនោះ។

(៣) ការសន្មតអំពីការប្រើខ្ពស់បំផុតនិងល្អបំផុតរបស់ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុនឹងត្រូវមាន សង្គតិភាពសម្រាប់គ្រប់ទ្រព្យ

សកម្មទាំងអស់ (ដែលការប្រើខ្ពស់បំផុត និងល្អបំផុតមានការពាក់ព័ន្ធ) របស់ក្រុមនៃទ្រព្យសកម្មឬក្រុមនៃទ្រព្យសកម្ម និងបំណុលដែលនៅក្នុងនោះទ្រព្យសកម្មនឹងត្រូវបានគេប្រើ។

(ខ) ការប្រើខ្ពស់បំផុតនិងល្អបំផុតនៃទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុអាចផ្តល់តម្លៃអតិបរមា ចំពោះអ្នកចូលរួមទីផ្សារ លើមូលដ្ឋានតែឯកឯង។ ប្រសិនបើ ការប្រើខ្ពស់បំផុតនិងល្អបំផុតរបស់ទ្រព្យសកម្មគឺត្រូវប្រើទ្រព្យសកម្ម ដោយផ្អែកលើមូលដ្ឋានឯកឯង តម្លៃសមស្របរបស់ទ្រព្យសកម្ម គឺជាថ្លៃដែលនឹងត្រូវទទួល បាននៅក្នុងប្រតិបត្តិការបច្ចុប្បន្នដើម្បីលក់ទ្រព្យសកម្មទៅអ្នកចូលរួមទីផ្សារដែលនឹងត្រូវប្រើទ្រព្យសកម្ម នោះលើមូលដ្ឋានតែឯកឯង។

៣២ ការវាស់វែងតម្លៃសមស្រប របស់ទ្រព្យសកម្ម មិនមែនហិរញ្ញវត្ថុសន្មតថាទ្រព្យសកម្មនោះ ត្រូវបានលក់ដោយមានសង្គតិភាព ជាមួយនឹងអង្គនៃគណនី ដែលបានបញ្ជាក់ នៅក្នុងស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញ-វត្ថុអន្តរជាតិផ្សេងៗទៀត (ដែលអាចជាទ្រព្យសកម្មនិមួយៗដោយឡែក)។ នោះគឺជាករណី ដែលសូម្បីតែនៅពេលដែល ការវាស់វែងតម្លៃសមស្របសន្មតថា ការប្រើខ្ពស់បំផុតនិងល្អបំផុតរបស់ទ្រព្យសកម្មនោះគឺត្រូវប្រើវាដោយការគួបផ្សំជាមួយនឹងទ្រព្យសកម្មផ្សេងទៀតឬជាមួយនឹងទ្រព្យសកម្ម និងបំណុលផ្សេងទៀត ពីព្រោះការវាស់វែងតម្លៃសមស្របសន្មតថា អ្នកចូលរួមទីផ្សារបានកាន់កាប់រួចជាស្រេចនូវទ្រព្យសកម្មបន្ថែម និងបំណុលពាក់ពន្ធ័។

៣៣ កថាខណ្ឌ ខ៣ បរិយាយការអនុវត្តន៍ការសន្មត នៃការវាយតម្លៃ សម្រាប់ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ។

## ការអនុវត្តន៍ចំពោះបំណុលនិងឧបករណ៍មូលធនផ្ទាល់របស់អង្គភាព

### គោលការណ៍ទូទៅ

៣៤ ការវាស់វែងតម្លៃសមស្របសន្មតថា បំណុលហិរញ្ញវត្ថុ និងបំណុលមិន មែនហិរញ្ញវត្ថុ ឬឧបករណ៍មូលធនផ្ទាល់របស់អង្គភាព (ឧ. ភាគកម្ម មូលធនផ្ទាល់បានបោះផ្សាយធ្វើជាតម្លៃតបសងនៅក្នុងការរួមបញ្ចូលអាជីវកម្ម)ត្រូវបានផ្ទេរទៅអ្នកចូលរួមទីផ្សារនាកាលបរិច្ឆេទនៃការវាស់វែង។ ការផ្ទេរបំណុលឬឧបករណ៍មូលធនផ្ទាល់របស់អង្គភាពសន្មត ដូចខាង ក្រោមៈ

(ក) បំណុលនៅតែជំពាក់ដដែល ហើយអ្នកទទួលការផ្ទេរដែលជាអ្នកចូលរួមទីផ្សារនឹងត្រូវតម្រូវឱ្យបំពេញ កាតព្វកិច្ចបំណុលនោះ។ បំណុលនឹងមិនត្រូវបានទូទាត់ជាមួយនឹងសមភាគី ឬមិនដូច្នោះបំណុលត្រូវបានទូទាត់នាកាលបរិច្ឆេទនៃការវាស់វែង។

(ខ) ឧបករណ៍មូលធនផ្ទាល់របស់អង្គភាពនឹងនៅតែជំពាក់ ហើយអ្នកទទួលការផ្ទេរដែលជាអ្នកចូលរួមទីផ្សារនឹងបន្តសិទ្ធិ និងការទទួលខុសត្រូវពាក់ពន្ធ័នឹងឧបករណ៍មូលធនផ្ទាល់នោះ។ ឧបករណ៍ មូលធនផ្ទាល់នោះមិនអាចលុបចោល ឬមិនដូច្នោះ បំណុលត្រូវបានទូទាត់នាកាលបរិច្ឆេទនៃការវាស់វែង។

៣៥ បើទោះបីជានៅពេលដែលមិនមានទីផ្សារដែលអាចអង្កេតបាន ដើម្បីផ្តល់ព័ត៌មានអំពីការកំណត់ថ្លៃ ស្តីពីការផ្ទេរបំណុល ឬឧបករណ៍មូលធនផ្ទាល់របស់អង្គភាព (ឧ. ដោយសារតែការកំហិតតាមកិច្ចសន្យាឬតាមផ្លូវច្បាប់ផ្សេងៗរារាំងការផ្ទេរនៃធាតុទាំងនេះ) អាចមានទីផ្សារ ដែលអាចអង្កេតបានសម្រាប់ ធាតុទាំងនោះប្រសិនបើពួកវាត្រូវបានកាន់កាប់ដោយបណ្តាភាគី

ផ្សេងទៀត ថាជាទ្រព្យសកម្ម (ឧ. សញ្ញាប័ណ្ណក្រុមហ៊ុន ឬ ជម្រើសពិសេសនៃការទិញវិញនូវមូលបត្រកម្មសិទ្ធិរបស់អង្គភាពមួយ)។

៣៦ នៅគ្រប់ករណី, អង្គភាពត្រូវធ្វើអតិប្បរមាកម្មការប្រើប្រាស់ធាតុចូលដែលអាចអង្កេតបាន និងអប្បបរមាកម្ម ការប្រើប្រាស់ធាតុចូល ដែលមិនអាចអង្កេតបាន ដើម្បីឆ្លើយតបទៅនឹងកម្មវត្ថុ នៃការវាស់វែងតម្លៃសមស្រប ដែលនឹងត្រូវប៉ាន់ស្មានថ្លៃតាមប្រតិបត្តិការប្រព័ន្ធ ដើម្បីផ្ទេរបំណុល ឬ ឧបករណ៍មូលធនផ្ទាល់ ដែលនឹងកើតឡើងរវាងអ្នកចូលរួមទីផ្សារ នាកាលបរិច្ឆេទនៃការវាស់វែងតាមលក្ខខណ្ឌទីផ្សារបច្ចុប្បន្ន។

*បំណុលនិងឧបករណ៍មូលធនផ្ទាល់ដែលកាន់កាប់ ដោយភាគីផ្សេងទៀត ដែលយកធ្វើជាទ្រព្យសកម្ម*

៣៧ **នៅពេលដែលថ្លៃសម្រង់សម្រាប់ការផ្ទេរបំណុលដូចគ្នាឬបំណុលស្រដៀងគ្នា ឬឧបករណ៍មូលធនផ្ទាល់របស់អង្គភាពមិនអាចរកបាន ធាតុស្រដៀងគ្នា ត្រូវបានកាន់កាប់ដោយភាគីផ្សេងទៀតដែលយកធ្វើជាទ្រព្យសកម្ម អង្គភាព ត្រូវវាស់វែងតម្លៃសមស្របរបស់បំណុល ឬឧបករណ៍មូលធនផ្ទាល់នោះ ដោយឈរលើ ទស្សនទានរបស់អ្នកចូលរួមទីផ្សារ ដែលបានកាន់កាប់ធាតុ ស្រដៀងគ្នានោះថាជាទ្រព្យសកម្ម នាកាលបរិច្ឆេទនៃការវាស់វែង។**

៣៨ ក្នុងករណីបែបនេះ អង្គភាពត្រូវវាស់វែងតម្លៃសមស្របរបស់បំណុល ឬ ឧបករណ៍មូលធនផ្ទាល់ ដូចខាងក្រោម:

(ក) ប្រើថ្លៃសម្រង់នៅក្នុងទីផ្សារសកម្មសម្រាប់ធាតុស្រដៀងគ្នា ដែលបានកាន់កាប់ដោយភាគីផ្សេងទៀត ធ្វើជាទ្រព្យសកម្ម ប្រសិនបើ ថ្លៃនោះអាចរកបាន។

(ខ) ប្រសិនបើថ្លៃនោះមិនអាចរកបាន ត្រូវប្រើធាតុចូលដែលអាចអង្កេតបានផ្សេងទៀតដូចជា ថ្លៃសម្រង់នៅក្នុងទីផ្សារ ដែលមិនសកម្មសម្រាប់ធាតុស្រដៀងគ្នាដែលបានកាន់កាប់ដោយភាគីផ្សេងទៀតធ្វើជាទ្រព្យសកម្ម។

(គ) ប្រសិនបើ ថ្លៃអាចអង្កេតបាននៅក្នុងករណី (ក) និង (ខ) មិនអាចរកបាន ចូរប្រើបច្ចេកទេសនៃការវាយតម្លៃផ្សេងទៀត ដូចជា:

(១) វិធីសាស្ត្រប្រាក់ចំណេញ (ឧ. បច្ចេកទេសតម្លៃបច្ចុប្បន្នសុទ្ធដែលរាប់បញ្ចូលលំហូរសាច់ប្រាក់ អនាគតដែលអ្នកចូលរួមទីផ្សារនឹងសង្ឃឹមថា ទទួលបានពីការកាន់កាប់បំណុល ឬឧបករណ៍មូលធនផ្ទាល់ ដែលស្ថិតនៅក្នុង ការកាន់កាប់ដោយភាគីផ្សេងៗទៀតធ្វើជាទ្រព្យសកម្ម, ចូរមើលកថាខណ្ឌខ១០ និងខ១១)។

(២) វិធីសាស្ត្រទីផ្សារ (ឧ. ការប្រើថ្លៃសម្រង់ សម្រាប់បំណុល ស្រដៀងគ្នា ឬឧបករណ៍មូលធនផ្ទាល់ ដែលបានកាន់កាប់ដោយភាគីផ្សេងៗទៀតធ្វើជាទ្រព្យសកម្ម, ចូរមើលកថាខណ្ឌខ៥-ខ៧)។

៣៩ អង្គភាពត្រូវកែសម្រួលថ្លៃសម្រង់របស់បំណុល ឬឧបករណ៍មូលធនផ្ទាល់របស់អង្គភាពដែលបានកាន់កាប់ដោយភាគីផ្សេងទៀត ដែលធ្វើជាទ្រព្យសកម្ម តែក្នុងករណីដែលមានកត្តាជាក់លាក់នានាចំពោះទ្រព្យសកម្មនោះដែលមិនអាចអនុវត្តបាន សម្រាប់ការវាស់វែងតម្លៃសមស្របរបស់បំណុល ឬឧបករណ៍មូលធនផ្ទាល់។ អង្គភាព ត្រូវធានាថា ថ្លៃរបស់ទ្រព្យសកម្ម មិនឆ្លុះបញ្ចាំង អំពីផលប៉ះពាល់នៃការកំហិតណាមួយដែលរារាំងដល់ការ លក់

ទ្រព្យសកម្មនោះ។ កត្តាមួយចំនួនដែលអាចបង្ហាញថា ថ្លៃសម្រង់របស់ទ្រព្យសកម្មគួរតែត្រូវបានកែសម្រួលដោយរួមបញ្ចូលកត្តាខាងក្រោមៈ

(ក) សម្រង់ថ្លៃសម្រាប់ទ្រព្យសកម្មដែលទាក់ទងនឹងបំណុលស្រដៀងគ្នា (តែមិនដូចគ្នា) ឬឧបករណ៍មូលធន ដែលបានកាន់កាប់ ដោយភាគីផ្សេងទៀត ធ្វើជាទ្រព្យសកម្ម។ឧទាហរណ៍ បំណុលឬឧបករណ៍មូលធនផ្ទាល់អាចមានចរិតលក្ខណៈពិសេស(ឧ.គុណភាពឥណទានរបស់ក្រុមហ៊ុនបោះផ្សាយ) ដែលមានលក្ខណៈខុសគ្នាពីអ្វី ដែលបានឆ្លុះបញ្ចាំងនៅក្នុងតម្លៃសមស្របរបស់បំណុលដែលស្រដៀងគ្នា ឬឧបករណ៍មូលធនដែលបានកាន់កាប់ធ្វើជាទ្រព្យសកម្ម។

(ខ) អង្គនៃគណនីសម្រាប់ទ្រព្យសកម្មមិនដូចគ្នានឹងអង្គគណនី សម្រាប់បំណុលនិងឧបករណ៍មូលធនផ្ទាល់នោះទេ។ ឧទាហរណ៍ សម្រាប់បំណុលនៅក្នុងករណីខ្លះថ្លៃរបស់ទ្រព្យសកម្មឆ្លុះបញ្ចាំងនូវថ្លៃគួបផ្សំសម្រាប់កញ្ចប់មួយ ដែលរួមមានទាំងបរិមាណដល់កំណត់សងពីក្រុមហ៊ុនបោះផ្សាយនិងពីការធ្វើឱ្យប្រសើរឡើង នូវឥណទានរបស់ភាគីទីបី។ ប្រសិនបើ អង្គនៃគណនី សម្រាប់បំណុលមិនមែនជាកញ្ចប់គួបផ្សំ កម្មវត្ថុគឺត្រូវវាស់វែងតម្លៃសមស្របរបស់បំណុលរបស់ក្រុមហ៊ុនបោះផ្សាយ មិនមែនជាតម្លៃសមស្របរបស់កញ្ចប់ដែលបានគួបផ្សំនោះឡើយ។ ដូច្នេះ នៅក្នុងករណីបែបនេះ អង្គភាពនឹងត្រូវកែសម្រួលថ្លៃបានអង្កេត សម្រាប់ទ្រព្យសកម្មដោយ ត្រូវដកចេញនូវផលប៉ះពាល់នៃការធ្វើឱ្យប្រសើរឡើងនូវឥណទានរបស់ភាគីទីបី។

***បំណុលនិងឧបករណ៍មូលធនផ្ទាល់ដែលមិនត្រូវបានកាន់កាប់ដោយភាគីផ្សេងៗ ដែលជាទ្រព្យសកម្ម***

៤០ **នៅពេលដែលថ្លៃសម្រង់សម្រាប់ការផ្ទេរបំណុលដែលដូចគ្នា ឬដែល ស្រដៀងគ្នាឬឧបករណ៍មូលធនផ្ទាល់របស់អង្គភាពមិនអាចរកបាន ហើយ ធាតុដូចគ្នាមិនត្រូវបានកាន់កាប់ដោយភាគីផ្សេងទៀត ដែលធ្វើជាទ្រព្យ សកម្ម អង្គភាពត្រូវវាស់វែងតម្លៃសមស្របរបស់បំណុល ឬឧបករណ៍ មូលធនផ្ទាល់ ដោយប្រើបច្ចេកទេសវាយតម្លៃដោយឈរលើទស្សនៈ នៃ អ្នកចូលរួមទីផ្សារ ដែលមានជំពាក់បំណុលឬមានការទាមទារ លើមូលធន ផ្ទាល់។**

៤១ ឧទាហរណ៍ នៅពេលអនុវត្តបច្ចេកទេសតម្លៃបច្ចុប្បន្ន អង្គភាពអាចរាប់បញ្ចូលចំណុចខាងក្រោមៈ

(ក) លំហូរសាច់ប្រាក់ចេញ ពេលអនាគត ដែលអ្នកចូលរួមទីផ្សារនឹងរំពឹងថានឹងកើតឡើងនៅក្នុងការបំពេញកាតព្វកិច្ចបំណុល, ដោយរួមមានទាំងកម្រៃតបសងដែលអ្នកចូលរួមទីផ្សារនឹងទាមទារ សម្រាប់ការទទួលយកកាតព្វកិច្ចបំណុល (មើល កថាខណ្ឌប៣១-ខ៣៣)។

(ខ) បរិមាណដែលអ្នកចូលរួមទីផ្សារនឹងទទួលបាន ដោយការចូលទៅក្នុង ឬបោះផ្សាយបំណុល ដែលដូចគ្នា ឬឧបករណ៍មូលធនផ្ទាល់ ដោយប្រើការសន្មតថា អ្នកចូលរួមទីផ្សារនឹងប្រើវានៅពេលកំណត់ថ្លៃធាតុដូចគ្នា(ឧ.មានចរិតលក្ខណៈឥណទានដូចគ្នា) នៅក្នុងទីផ្សារគោល (ឬទីផ្សារដែលមានអាទិភាពបំផុត) សម្រាប់ការបោះផ្សាយបំណុល ឬឧបករណ៍មូលធនផ្ទាល់ជាមួយនឹងលក្ខខណ្ឌនៃកិច្ចសន្យាដូចគ្នា។

**ហានិភ័យមិនមែនប្រតិបត្តិការ**

**៤២ តម្លៃសមស្របរបស់បំណុលឆ្លុះបញ្ចាំងអំពីផលប៉ះពាល់របស់*ហានិភ័យ មិនមែនប្រតិបត្តិការ*។ហានិភ័យ មិនមែនប្រតិបត្តិការរួមមាន តែមិនកំណត់ ត្រឹមហានិភ័យឥណទានផ្ទាល់ខ្លួនរបស់អង្គភាព (ដូចបានកំណត់អត្ថន័យ នៅក្នុងស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ ៧ *ឧបករណ៍ ហិរញ្ញវត្ថុៈការលាតត្រដាង*)។ ហានិភ័យមិនមែនប្រតិបត្តិការត្រូវបានសន្មត ថាវាដូចគ្នាតាំងពីមុននិងក្រោយការផ្ទេរ បំណុល។**

៤៣ នៅពេលវាស់វែងតម្លៃសមស្របរបស់បំណុល អង្គភាពត្រូវរាប់បញ្ចូលនូវផលប៉ះពាល់នៃហានិភ័យឥណទាន (ជំហរឥណទាន) និងកត្តាផ្សេងៗទៀតដែលអាចមានឥទ្ធិពលលើលទ្ធភាព ដែលកាតព្វកិច្ចបំណុលនឹងត្រូវបានឬនឹងមិនត្រូវបានបំពេញ។ ផលប៉ះពាល់អាចមានភាពខុសគ្នាអាស្រ័យលើបំណុល ឧទាហរណ៍ៈ

(ក) តើបំណុលគឺជាកាតព្វកិច្ចត្រូវប្រគល់សាច់ប្រាក់ (បំណុលហិរញ្ញវត្ថុ) ឬជាកាតព្វកិច្ច ត្រូវប្រគល់ទំនិញ ឬសេវាកម្ម (បំណុលមិនមែនហិរញ្ញវត្ថុ)។

(ខ) លក្ខខណ្ឌនៃការធ្វើឱ្យប្រសើរឡើងនៃឥណទានទាក់ទងនឹងបំណុល ប្រសិនបើមាន។

៤៤ តម្លៃសមស្របរបស់បំណុលឆ្លុះបញ្ចាំងផលប៉ះពាល់នៃហានិភ័យ មិនមែនប្រតិបត្តិការលើមូលដ្ឋាននៃអង្គគណនី។ អ្នកបោះផ្សាយបំណុលបានបោះផ្សាយជាមួយនឹងការធ្វើឱ្យប្រសើរឡើងនៃឥណទានរបស់ ភាគីទីបី ដែលមិនអាចញែកចេញពីគ្នាបាន ដែលត្រូវបានរាប់បញ្ចូលដាច់ដោយឡែកពី គ្នាសម្រាប់បំណុលនោះ នឹងមិនត្រូវបញ្ចូលនូវផលប៉ះពាល់ នៃការធ្វើឱ្យ

ប្រសើរឡើងនៃឥណទានឡើយ (ឱ. ការធានាបំណុលរបស់ភាគីទីបី) នៅក្នុងការវាស់វែងតម្លៃសមស្របរបស់បំណុល។ ប្រសិនបើ ការធ្វើឱ្យប្រសើរឡើងនៃឥណទានត្រូវបានរាប់បញ្ចូលដាច់ដោយឡែកពីបំណុល អ្នកបោះផ្សាយ នឹងត្រូវរាប់បញ្ចូលជំហរឥណទានផ្ទាល់ខ្លួន និងមិនមែនជាជំហរឥណទានរបស់អ្នកធានាដែលជាភាគីទីបីឡើយនៅពេលវាស់វែងតម្លៃសមស្របរបស់បំណុល។

## ការដាក់កំហិតដើម្បីរារាំងការផ្ទេរបំណុលឬឧបករណ៍មូលធនផ្ទាល់របស់អង្គភាព

៤៥ នៅពេលវាស់វែងតម្លៃសមស្របរបស់បំណុល ឬឧបករណ៍មូលធនផ្ទាល់របស់អង្គភាព អង្គភាពមិនត្រូវរាប់បញ្ចូលធាតុដាច់ដោយឡែក ឬការកែសម្រួលចំពោះធាតុចូលផ្សេងទៀតទាក់ទងនឹងអត្ថិភាព នៃការដាក់កំហិតដែលរារាំងការផ្ទេរធាតុទាំងនោះ។ ផលប៉ះពាល់នៃការដាក់កំហិត ដែលរារាំងការផ្ទេរបំណុល ឬឧបករណ៍មូលធនផ្ទាល់របស់អង្គភាព ត្រូវបានរួមបញ្ចូលដោយវាទរហិត ឬដោយនិប្បរិយាយ នៅក្នុងធាតុចូលផ្សេងទៀតទៅក្នុងការវាស់វែងតម្លៃសមស្រប។

៤៦ ឧទាហរណ៍ នៅកាលបរិច្ឆេទ នៃប្រតិបត្តិការទាំងម្ចាស់បំណុល និងកូនបំណុលបានទទួលយកនូវថ្លៃប្រតិបត្តិការ សម្រាប់បំណុលដោយមានការយល់ដឹងពេញលេញថាកាតព្វកិច្ចនោះរួមមានការដាក់កំហិតដែលរារាំងការផ្ទេររបស់វា។ ជាលទ្ធផលនៃការដាក់កំហិតនេះ កំពុងត្រូវបានរាប់បញ្ចូលនៅក្នុងថ្លៃប្រតិបត្តិការ ធាតុដាច់ដោយឡែក ឬការកែសម្រួលចំពោះធាតុដែលមានស្រាប់មិនត្រូវបានតម្រូវនាកាល បរិច្ឆេទនៃប្រតិបត្តិការ ដើម្បីឆ្លុះបញ្ចាំងផលប៉ះពាល់ នៃការដាក់កំហិតលើការផ្ទេរ។ ស្រដៀងគ្នានេះ

ធាតុដាច់ដោយឡែក ឬការកែសម្រួលចំពោះធាតុ ដែលមានស្រាប់ មិនត្រូវបានតម្រូវនាកាលបរិច្ឆេទនៃការវាស់វែងជាបន្តបន្ទាប់ទៀតដើម្បីឆ្លុះបញ្ចាំងផលប៉ះពាល់នៃការដាក់កំហិតលើការផ្ទេរ។

## បំណុលហិរញ្ញវត្ថុដែលមានលក្ខណៈពិសេសនៃតម្រូវការ

៤៧ តម្លៃសមស្របរបស់បំណុលហិរញ្ញវត្ថុដែលមានលក្ខណៈពិសេស នៃតម្រូវការ (ឧ.ប្រាក់បញ្ញើរតាមការកំណត់) មិនតិចជាងបរិមាណត្រូវសង តាមការតម្រូវ ត្រូវបានបញ្ចុះតម្លៃតាំងពីកាលបរិច្ឆេទដំបូងដែលបរិមាណនោះអាចត្រូវបានតម្រូវឱ្យសង។

## ការអនុវត្តន៍ចំពោះទ្រព្យសកម្មហិរញ្ញវត្ថុនិងបំណុលហិរញ្ញវត្ថុដោយមានស្ថានភាពនៃការកាត់កងនៅក្នុងហានិភ័យទីផ្សារនិងហានិភ័យឥណទានសមភាគី

៤៨ អង្គភាពដែលកាន់កាប់របស់ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុត្រូវប្រឈមនឹងហានិភ័យទីផ្សារ (ដូចបានកំណត់នៅក្នុងស្តង់ដាបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ ៧) និងហានិភ័យឥណទាន(ដូចបានកំណត់នៅក្នុងស្តង់ដាបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ៧) របស់ សមភាគីនិមួយៗ។ ប្រសិនបើ អង្គភាពគ្រប់គ្រងក្រុម នៃទ្រព្យសកម្ម ហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុឈរលើមូលដ្ឋាននៃការប្រឈមសុទ្ធសាធ របស់ខ្លួនទៅនឹងហានិភ័យទីផ្សារ ឬហានិភ័យឥណទាន អង្គភាពត្រូវបាន អនុញ្ញាតិឱ្យអនុវត្តការលើកលែង ចំពោះស្តង់ដាបាយការណ៍ទាក់ទងនឹង ហិរញ្ញវត្ថុអន្តរជាតិនេះសម្រាប់ការវាស់វែងតម្លៃសមស្រប។ ការលើកលែង នោះអនុញ្ញាតិឱ្យអង្គភាពវាស់វែងតម្លៃសមស្របរបស់ក្រុម នៃទ្រព្យសកម្មហិរញ្ញវត្ថុ និង

បំណុលហិរញ្ញវត្ថុឈរលើមូលដ្ឋានថ្លៃ ដែលនឹងទទួលបាន ដើម្បីលក់ស្ថានភាពជំហររយៈពេលវែងសុទ្ធ (មានន័យថា ទ្រព្យសកម្ម)សម្រាប់ការប្រឈមនឹង ហានិភ័យដ៏ជាក់លាក់មួយ ឬដើម្បីផ្ទេរស្ថានភាព ជំហររយៈពេលខ្លីសុទ្ធ (មានន័យថាបំណុល) សម្រាប់ការប្រឈមនឹងហា- និភ័យដ៏ជាក់លាក់មួយ នៅក្នុងប្រតិបត្តិការប្រព័ន្ធរវាងអ្នកចូលរួមទីផ្សារ នាកាលបរិច្ឆេទនៃការវាយតម្លៃក្រោមលក្ខខណ្ឌទីផ្សារធម្មតា។ យោងតាម នោះអង្គភាពត្រូវវាស់វែងតម្លៃសមស្របរបស់ក្រុមនៃទ្រព្យសកម្មហិរញ្ញវត្ថុនិងបំណុលហិរញ្ញវត្ថុដោយមានសង្គតិភាពជាមួយនឹងរបៀប ដែលអ្នកចូល រួមទីផ្សារនឹងកំណត់ថ្លៃ ចំពោះការប្រឈមហានិភ័យសុទ្ធ នាកាលបរិច្ឆេទ នៃការវាស់វែង។

៤៩ អង្គភាពត្រូវបានអនុញ្ញាតិឱ្យប្រើការលើកលែងនៅក្នុងកថាខណ្ឌ ៤៨ តែនៅក្នុងករណីទាំងអស់ដូចខាងក្រោមៈ

(ក) គ្រប់គ្រងក្រុមនៃទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុឈរលើមូលដ្ឋាននៃប្រឈមសុទ្ធទៅនឹង ហានិភ័យទីផ្សារដ៏ជាក់លាក់មួយ (ឬ ហានិភ័យនានា) ឬទៅនឹងហានិភ័យឥណទានរបស់សមភាគីដោយ អនុលោមតាមការគ្រប់គ្រងហានិភ័យដែលបានចងក្រង ឬយុទ្ធសាស្ត្រវិនិយោគរបស់អង្គភាព,

(ខ) ផ្តល់ព័តិមានដោយឈរលើមូលដ្ឋាននោះ ស្តីពីក្រុមនៃទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ ចំពោះបុគ្គលិកគ្រប់គ្រងសំខាន់ៗរបស់អង្គភាព ដូចបានកំណត់នៅក្នុងស្តង់ដាគណនេយ្យអន្តរជាតិ ២៤ *ការលាតត្រដាងភាគីពាក់ពន្ធ័* និង

(គ) ត្រូវបានតម្រូវ ឬត្រូវបានជ្រើសរើស ដើម្បីវាស់វែងទ្រព្យសកម្ម ហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ តាមតម្លៃសមស្របនៅក្នុងរបាយ-ការណ៍ស្ថានភាពហិរញ្ញវត្ថុនាចុងការិយបរិច្ឆេទរាយការណ៍នីមួយៗ។

៥០ ការលើកលែងនៅក្នុងកថាខណ្ឌ ៤៨ មិនទាក់ទងនឹង ការដាក់បង្ហាញរបាយការណ៍ហិរញ្ញវត្ថុឡើយ។ នៅក្នុងករណីខ្លះមូលដ្ឋាន នៃការដាក់បង្ហាញឧបករណ៍ហិរញ្ញវត្ថុនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុខុសគ្នាពីមូដ្ឋាននៃការវាស់វែងឧបករណ៍ហិរញ្ញវត្ថុ ឧទាហរណ៍ ប្រសិនបើស្តង់ដាបាយការណ៍ទាក់ទងនឹង ហិរញ្ញវត្ថុអន្តរជាតិមិនតម្រូវឱ្យ ឬមិនអ នុញ្ញាតិឱ្យឧបករណ៍ហិរញ្ញវត្ថុត្រូវបានវាស់វែងដោយឈរលើមូលដ្ឋានស្ថានភាពជំហរសុទ្ធ។ នៅក្នុងករណីបែបនេះ អង្គភាពអាចចាំបាច់ត្រូវបែងចែក ការកែសម្រួល តាមកម្រិតនៃផលបត្រ (សូមមើល កថាខណ្ឌ៥៣-៥៦) ចំពោះទ្រព្យសកម្មឬបំណុលនិមួយៗដែលបង្កើតបានជាក្រុមនៃទ្រព្យសកម្ម ហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ ដែលបានគ្រប់គ្រងឈរលើមូលដ្ឋាន នៃការប្រឈមនឹងហានិភ័យសុទ្ធរបស់អង្គភាព។ អង្គភាពត្រូវធ្វើការបែងចែកបែបនោះ លើមូលដ្ឋានសមហេតុផល និងមានសង្គតិភាព ដោយប្រើ វិធីសាស្រ្ត សមស្របតាមកាលៈទេសៈ។

៥១ អង្គភាព ត្រូវធ្វើការសម្រេចចិត្ត អំពីគោលនយោបាយគណនេយ្យមួយដោយអនុលោមតាមស្តង់ដាគណនេយ្យអន្តរជាតិ ៨ *គោលនយោបាយគណនេយ្យ បម្រែបម្រួលនៅក្នុងការប៉ាន់ស្មានគណនេយ្យ និងលំអៀង* ដើម្បីប្រើនូវការលើកលែងនៅក្នុងកថាខណ្ឌ៤៨។អង្គភាពដែលប្រើការលើកលែងនោះ ត្រូវអនុវត្តគោលនយោបាយគណនេយ្យនោះ រួមមានទាំងគោលនយោបាយសម្រាប់បែងចែកការកែសម្រួលថ្លៃទិញ-ថ្លៃលក់ផងដែរ

(សូមមើលកថាខណ្ឌ ៥៣-៥៥) និងការកែសម្រួលឥណទាន (សូមមើលកថាខណ្ឌ៥៦) ប្រសិនបើ អាចអនុវត្តបានដោយមានសង្គតិភាព ពីការិយ-បរិច្ឆេទមួយទៅការិយបរិច្ឆេទមួយទៀតសម្រាប់ក្រុមផលបត្រដ៏ជាក់លាក់មួយ។

៥២ ការលើកលែងនៅក្នុងកថាខណ្ឌ ៤៨ អនុវត្តចំពោះតែទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុដែលស្ថិត នៅក្នុងក្របខណ្ឌ នៃស្តង់ដាគណនេយ្យអន្តរជាតិ ៣៩ *ឧបករណ៍ហិរញ្ញវត្ថុៈការទទួលស្គាល់និងការវាស់វែង* ឬ ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ៩ *ឧបករណ៍ហិរញ្ញវត្ថុ*។

**ការប្រឈមនឹងហានិន័យទីផ្សារ**

៥៣ នៅពេលប្រើការលើកលែងនៅក្នុងកថាខណ្ឌ ៤៨ ដើម្បីវាស់វែងតម្លៃសមស្របរបស់ក្រុមនៃទ្រព្យសកម្មហិរញ្ញវត្ថុនិងបំណុលហិរញ្ញវត្ថុ ដែលគ្រប់គ្រងដោយឈរលើមូលដ្ឋាន នៃការប្រឈមសុទ្ធរបស់អង្គភាព ទៅនឹង ហានិភ័យទីផ្សារដ៏ជាក់លាក់មួយ (ឬហានិភ័យនានា) អង្គភាពត្រូវអនុវត្តថ្លៃនៅក្នុងក្របខណ្ឌគម្លាតថ្លៃលក់-ថ្លៃទិញ ដែលជាតំណាងដ៏ប្រសើរបំផុត នៃតម្លៃសមស្របតាមកាលៈទេសៈ ចំពោះការប្រឈមសុទ្ធ របស់អង្គភាពចំពោះហានិផ័យទីផ្សារទាំងនោះ (សូមមើល កថាខណ្ឌ ៧០ និង ៧១)។

៥៤ នៅពេលប្រើការលើកលែងនៅក្នុងកថាខណ្ឌ ៤៨ អង្គភាព ត្រូវធនាថា ហានិភ័យទីផ្សារ (ហានិភ័យនានា) ដែលអង្គភាពត្រូវប្រឈមស្ថិតនៅក្នុង ក្រុមនៃទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ ដែលមានភាពដូចគ្នា យ៉ាងខ្លាំង។ឧទាហរណ៍ អង្គភាពនឹងមិនត្រូវគួផ្សំហានិភ័យអត្រាការប្រាក់ទាក់ទងនឹងទ្រព្យសកម្ម ហិរញ្ញវត្ថុជាមួយនឹងហានិភ័យថ្លៃរបស់ កុំម្ម៉ូឌីធីទាក់ទងនឹងបំណុលហិរញ្ញវត្ថុ ដោយសារតែ ការធ្វើដូច្នោះនឹងមិនសម្រាល

ដល់ការប្រឈមរបស់អង្គភាពទៅនឹងហានិភ័យអត្រាការប្រាក់ឬហានិភ័យថ្លៃរបស់កុម្មូឌីធីឡើយ។ នៅពេលប្រើការលើកលែងនៅក្នុងកថាខណ្ឌ ៤៨ ហានិភ័យសំខាន់ៗនានា ដែលបណ្តាលមកពី ប៉ារ៉ាម៉ែត្រ ហានិភ័យទីផ្សារ ដែលមិនមានភាពដូចគ្នាត្រូវបានគេរាប់បញ្ចូលទៅក្នុងការវាស់វែងតម្លៃសមស្របរបស់ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ ដែលនៅក្នុងក្រុមនោះ។

៥៥ ស្រដៀងគ្នានេះ រយៈពេលនៃការប្រឈមរបស់អង្គភាពចំពោះហានិភ័យ ទីផ្សារ (ឬ ហានិភ័យនានា) កើតឡើងពីទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ នឹងត្រូវតែមានភាពដូចគ្នាយ៉ាងខ្លាំង។ ឧទាហរណ៍ អង្គភាព ដែលប្រើកិច្ចសន្យាអនាគតរយៈពេល ១២ខែ ជាមួយនឹងលំហូរសាច់ប្រាក់ ដែលពាក់ពន្ធ័នឹងតម្លៃរយៈពេល ១២ខែ នៃការប្រឈមនឹងហានិភ័យអត្រា ការប្រាក់ លើឧបករណ៍ហិរញ្ញវត្ថុរយៈពេល ៥ឆ្នាំ ដែលស្ថិតនៅក្នុងក្រុម មួយដែលបានកើតឡើងតែពីទ្រព្យសកម្មហិរញ្ញវត្ថុនិងបំណុលហិរញ្ញវត្ថុទាំងនោះធ្វើការវាស់វែងតម្លៃសមស្រប នៃការប្រឈម ចំពោះហានិភ័យអត្រាការប្រាក់រយៈពេល ១២ខែ ដោយឈរលើមូលដ្ឋានសុទ្ធ និងការប្រឈមហានិភ័យអត្រាការប្រាក់នៅសល់ (មានន័យថា ពី២-៥ឆ្នាំ) លើមូលដ្ឋានដុល។

## ការប្រឈមនឹងហានិន័យទីផ្សាររបស់សមនាគីជាក់លាក់មួយ

៥៦ នៅពេលប្រើ ការលើកលែងនៅក្នុង កថាខណ្ឌ ៤៨ ដើម្បីវាស់វែងតម្លៃ សមស្របរបស់ក្រុមនៃទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ ជាមួយ សមភាគីដ៏ជាក់លាក់មួយ អង្គភាព ត្រូវរាប់បញ្ចូលផលប៉ះពាល់ នៃការប្រឈម

សុទ្ធរបស់អង្គភាព ទៅនឹងហានិភ័យឥណទានរបស់សមភាគីនោះ ឬការប្រឈមសុទ្ធរបស់សមភាគី ទៅនឹងហានិភ័យឥណទានរបស់អង្គភាព នៅក្នុងការវាស់វែងតម្លៃសមស្របនៅពេលដែលអ្នកចូលរួមទីផ្សារនឹងរាប់បញ្ចូលកិច្ចព្រមព្រៀងដែលមានស្រាប់ណាមួយដែលធ្វើឱ្យធូរស្បើយនូវការប្រឈមនឹងហានិភ័យឥណទាននៅក្នុងហេតុការណ៍ នៃការខកខានមិនបានសង (ឧ. កិច្ចព្រមព្រៀងកំណត់ តម្លៃសុទ្ធទូលំទូលាយមួយ ជាមួយ សមភាគីឬកិច្ចព្រមព្រៀង ដែលតម្រូវឱ្យមានការដោះដូរទ្រព្យដាក់បញ្ចាំដែលឈរលើមូលដ្ឋាននៃការប្រឈមសុទ្ធរបស់ភាគីនិមួយៗ ចំពោះហានិ- ភ័យឥណទានរបស់ភាគីផ្សេងទៀត)។ ការវាស់វែងតម្លៃសមស្របត្រូវឆ្លុះបញ្ចាំងការរំពឹងទុករបស់អ្នកចូលរួមទីផ្សារអំពីលទ្ធភាពដែលកិច្ចព្រមព្រៀងនោះនឹងអាចអនុវត្តបានតាមផ្លូវច្បាប់ នៅក្នុងហេតុការណ៍នៃការខកខានមិនបានសង។

## តម្លៃសមស្របនៅពេលនៃការទទួលស្គាល់ដំបូង

៥៧ នៅពេលដែលទ្រព្យសកម្មត្រូវបានទិញឬបំណុលត្រូវបានទទួលយក នៅក្នុងប្រតិបត្តិការនៃការដោះដូរ សម្រាប់ទ្រព្យសកម្ម និងបំណុលនោះថ្លៃប្រតិបត្តិការ គឺជាថ្លៃដែលបានបង់ដើម្បីទទួលបាននូវទ្រព្យសកម្ម ឬថ្លៃបានទទួលដើម្បីយកបំណុល (ថ្លៃចូល)។ ផ្ទុយទៅវិញ តម្លៃសមស្របរបស់ទ្រព្យសកម្មឬបំណុលគឺជាថ្លៃដែលនឹងត្រូវទទួលបានដើម្បីលក់ទ្រព្យសកម្ម ឬថ្លៃបានបង់ដើម្បីផ្ទេរបំណុល (ថ្លៃដកថយ)។ បណ្តាអង្គភាព មិនចាំបាច់ត្រូវលក់ទ្រព្យសកម្មតាមថ្លៃបានបង់ ដើម្បីទទួលបានទ្រព្យសកម្មទាំងនោះ

ឡើយ។ ស្រដៀងគ្នានេះ បណ្តាអង្គភាពមិនចាំបាច់ផ្ទេរបំណុល តាមថ្លៃដែលបានទទួលដើម្បីយកបំណុលនោះឡើយ។

៥៨ នៅក្នុងករណីជាច្រើន ថ្លៃប្រតិបត្តិការស្មើនឹងតម្លៃសមស្រប (ឧ.ដែលអាចជាករណី នាពេលកាលបរិច្ឆេទប្រតិបត្តិការដើម្បីទិញទ្រព្យសកម្មមួយ បានកើតឡើងនៅក្នុងទីផ្សារដែលទ្រព្យសកម្មនោះត្រូវបានគេលក់)។

៥៩ នៅពេលកំណត់ថាតើតម្លៃសមស្របនាពេល នៃការទទួលស្គាល់ដំបូងស្មើនឹងថ្លៃប្រតិបត្តិការ អង្គភាពត្រូវរាប់បញ្ចូលកត្តាជាក់លាក់នានា ទៅក្នុងប្រតិបត្តិការនិងទៅក្នុងទ្រព្យសកម្មឬបំណុល។ កថាខណ្ឌ ខ៤ បរិយាយ បណ្តាស្ថានភាពដែលថ្លៃប្រតិបត្តិការ មិនអាចតំណាងឱ្យតម្លៃសមស្រប របស់ទ្រព្យសកម្មឬបំណុលនាពេលនៃការទទួលស្គាល់ដំបូង។

៦០ ប្រសិនបើ ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិផ្សេងទៀតតម្រូវ ឬអនុញ្ញាតិឱ្យអង្គភាពវាស់វែងទ្រព្យសកម្ម ឬបំណុលមួយ ជាលើកដំបូងតាមតម្លៃសមស្រប ហើយថ្លៃប្រតិបត្តិការខុសគ្នាពីតម្លៃ សមស្រប អង្គភាពត្រូវទទួលស្គាល់ចំណេញ ឬខាត នៅក្នុងគណនីចំណេញ ឬខាត ដរាបណា មានស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ ចែង ដោយឡែក។

**បច្ចេកទេសនៃការវាយតម្លៃ**

៦១ **អង្គភាពត្រូវប្រើបច្ចេកទេសនៃការវាយតម្លៃដែលសមរម្យតាមកាលៈទេសៈ និងដែលមានទិន្នន័យគ្រប់គ្រាន់អាចរកបានសម្រាប់វាស់វែងតម្លៃសមស្រប ដោយធ្វើអតិបរមាកម្មនូវការប្រើប្រាស់ធាតុចូលដែលអាចអង្កេតបាន និងធ្វើអប្បរមាកម្មនូវការប្រើប្រាស់ធាតុចូលដែលមិនអាចអង្កេតបាន។**

៦២ កម្មវត្ថុនៃការប្រើបច្ចេកទេសនៃការវាយតម្លៃគឺដើម្បីប៉ាន់ស្មានថ្លៃ ដែលប្រតិបត្តិការប្រព័ន្ធមួយដើម្បីលក់ទ្រព្យសកម្មទេ ដើម្បីផ្ទេរបំណុល ដែលនឹង កើតឡើងរវាងបណ្តាអ្នកចូលរួមទីផ្សារនាកាលបរិច្ឆេទនៃការវាស់វែងតាម លក្ខខណ្ឌទីផ្សារបច្ចុប្បន្ន។បច្ចេកទេសនៃការវាយតម្លៃដែលគេនិយមប្រើជាទូទៅគឺ វិធីសាស្ត្រទីផ្សារ វិធីសាស្ត្រថ្លៃដើម និងវិធីសាស្ត្រប្រាក់ ចំណេញ។ ទិដ្ឋភាពចំបងនៃវិធីសាស្ត្រទាំងនេះត្រូវបានសង្ខេបនៅក្នុង កថាខណ្ឌខ៥ -ខ១១។ អង្គភាពត្រូវប្រើបច្ចេកទេសនៃការវាយតម្លៃ ដែល មានសង្គតិភាព ជាមួយវិធីសាស្ត្រមួយឬច្រើនខាងលើ ដើម្បីវាស់វែងតម្លៃ សមស្រប។

៦៣ នៅក្នុងករណីខ្លះ បច្ចេកទេសវាយតម្លៃតែមួយនឹងសមស្របជាង (ឧ.នៅពេលវាយតម្លៃទ្រព្យសកម្ម ឬបំណុល ដោយប្រើថ្លៃសម្រង់នៅក្នុងទីផ្សារសកម្ម សម្រាប់ទ្រព្យសកម្ម ឬបំណុលដូចគ្នា)។ នៅក្នុងករណីខ្លះទៀត វិធីសាស្ត្រវាយតម្លៃ ច្រើននឹងមានភាពសមស្របជាង (ឧ.ដែលអាចជា ករណីនៃការវាយតម្លៃ អង្គបង្កើតសាច់ប្រាក់)។ ប្រសិនបើ បច្ចេកទេស នៃការវាយតម្លៃច្រើនត្រូវបានប្រើ ដើម្បីវាស់វែងតម្លៃសមស្របលទ្ធផល (មានន័យថាការចង្អុលបង្ហាញនៃតម្លៃសមស្របតាមវិធីសាស្ត្រនិមួយៗ) ត្រូវតែបានវាយតម្លៃដោយពិចារណានូវភាពសមហេតុសមផល នៃលំដាប់ លំដោយនៃ

តម្លៃដែលបានបង្ហាញតាមរយៈលទ្ធផលទាំងនោះ។ ការវាស់ វែងតម្លៃសមស្រប គឺជាចំណុចមួយដែលនៅក្នុងលំដាប់លដោយនៃតម្លៃនោះ គឺជាតំណាងដ៏ប្រសើរនៃតម្លៃសមស្របតាមកាលៈទេសៈ។

៦៤ ប្រសិនបើថ្លៃប្រតិបត្តិការ គឺជាតម្លៃសមស្រប នៅគ្រានៃការទទួលស្គាល់ដំបូង ហើយបច្ចេកទេសនៃការវាយតម្លៃដែលប្រើធាតុចូល ដែលមិនអាចអង្កេតបាន នឹងត្រូវប្រើដើម្បីវាស់វែងតម្លៃសមស្របសម្រាប់ការិយបរិច្ឆេទបន្តបន្ទាប់ទៀតបច្ចេកទេសវាយតម្លៃ នឹងត្រូវបានគេក្រិតតាមខ្នាត ដែលដោយការធ្វើបែបនេះ ការទទួលស្គាល់លើកដំបូងផ្តល់នូវលទ្ធផល ដែល បច្ចេកទេសវាយតម្លៃស្មើនឹងថ្លៃប្រតិបត្តិការ។ ការក្រិតតាមខ្នាតធានាថាបច្ចេកទេសនៃការវាយតម្លៃឆ្លុះបញ្ចាំងលក្ខខណ្ឌទីផ្សារបច្ចុប្បន្ន ហើយវានឹងជួយអង្គភាពកំណត់ថាតើវាមានភាពចាំបាច់ ដែលត្រូវមានការកែសម្រួលមួយចំពោះបច្ចេកទេសវាយតម្លៃ ឬយ៉ាងណា (ឧ. អាចមានចរិតលក្ខណៈមួយរបស់ទ្រព្យសកម្ម ឬបំណុល ដែលមិនឆ្លើយតបនឹងបច្ចេកទេសនៃការវាយតម្លៃ)។ បន្ទាប់ពីការទទួលស្គាល់ដំបូងនៅពេលវាស់វែងតម្លៃសមស្របដោយប្រើបច្ចេកទេសនៃការវាយតម្លៃ ឬបច្ចេកទេស ដែលប្រើធាតុចូលមិនអាចអង្កេតបាន អង្គភាព ត្រូវធានាថាបច្ចេកទេសនៃការវាយតម្លៃទាំងនោះឆ្លុះបញ្ចាំងទិន្នន័យទីផ្សារ ដែលអាចអង្កេតបាន (ឧ.ថ្លៃសម្រាប់ទ្រព្យសកម្មឬបំណុលស្រដៀងគ្នា) នាកាលបរិច្ឆេទនៃការវាស់វែង។

៦៥ បច្ចេកទេសនៃការវាយតម្លៃដែលបានប្រើដើម្បីវាស់វែងតម្លៃសមស្រប ត្រូវតែអនុវត្តដោយសង្គតិភាព។ ទោះជាយ៉ាងណា ការផ្លាស់ប្តូរបច្ចេកទេសវាយតម្លៃ ឬរបៀបនៃការអនុវត្តន៍របស់វា (ឧ.ការផ្លាស់ប្តូរ នៃបរិមាណទម្ងន់របស់វានៅពេលបច្ចេកទេសនៃការវាយតម្លៃចំរុះត្រូវបានប្រើ ឬការ

ផ្លាស់ប្តូរ នៅក្នុងការកែសម្រួលមួយដែលបានអនុវត្ត ចំពោះបច្ចេកទេស នៃការវាយតម្លៃមួយ) មានភាពសមស្រប ប្រសិនបើការផ្លាស់ប្តូរនោះធ្វើឲ្យការវាស់វែងមានតម្លៃស្មើ ឬមានលក្ខណៈជាតំណាងឱ្យតម្លៃសមស្របតាមកាលៈទេសៈ។នោះអាចជាករណីប្រសិនបើមាន ជាឧទាហរណ៍ព្រឹត្តិការណ៍ណាមួយខាងក្រោមកើតឡើង÷

(ក) ទីផ្សារថ្មីបានកើតឡើង

(ខ) ព័ត៌មានថ្មីអាចរកបាន

(គ) ព័ត៌មានដែលបានប្រើពីមុនមិនមានទៀតទេ

(ឃ) បច្ចេកទេសវាយតម្លៃកាន់តែប្រសើរឡើង ឬ

(ង) លក្ខខណ្ឌទីផ្សារមានការផ្លាស់ប្តូរ។

៦៦ ការពិនិត្យឡើងវិញដែលកើតចេញពីការផ្លាស់ប្តូរបច្ចេកទេសវាយតម្លៃ ឬរបៀបនៃការអនុវត្តន៍របស់វាត្រូវរាប់បញ្ចូលថាជាការផ្លាស់ប្តូរ នៅក្នុងការប៉ាន់ស្មានគណនេយ្យ ដោយអនុលោមតាមស្តង់ដាគណនេយ្យអន្តរជាតិ៨។ ទោះជាយ៉ាងណា បណ្តាការលាតត្រដាង (ស.ក.អ.ន) សម្រាប់ការផ្លាស់ប្តូរនៅក្នុងការប៉ាន់ស្មានគណនេយ្យ មិនត្រូវ បានតម្រូវសម្រាប់ការពិនិត្យឡើងវិញដែលជាលទ្ធផលនៃការផ្លាស់ប្តូរ នៅ ក្នុងបច្ចេកទេសនៃការវាយតម្លៃ ឬរបៀបនៃការអនុវត្តន៍របស់វាឡើយ។

**បណ្តាធាតុចូលសម្រាប់បច្ចេកទេសនៃការវាយតម្លៃ**

**គោលការណ៍ទូទៅ**

**៦៧ បច្ចេកទេសនៃការវាយតម្លៃដែលបានប្រើដើម្បីវាស់វែងតម្លៃសមស្របត្រូវតែអតិបរមានូវការប្រើប្រាស់ធាតុចូលពាក់ពន្ធ័ដែលអាចអង្កេត និងត្រូវ តែអប្បរមានូវការប្រើប្រាស់ធាតុចូលដែលមិនអាចអង្កេតបាន។**

៦៨ ឧទាហរណ៍អំពីទីផ្សារ ដែលនៅក្នុងនោះធាតុចូល អាចត្រូវបានគេអង្កេតបានសម្រាប់ទ្រព្យសកម្ម និងបំណុល (ឧ.ឧបករណ៍ហិរញ្ញវត្ថុ) រួមមាន ទីផ្សារប្តូរប្រាក់ ទីផ្សារឈ្មួញកណ្តាល ទីផ្សារឈ្មួញកម្រៃជើងសារ និង ទីផ្សាររវាងភារប្បទាយីនិងភារប្បទាយី (principal-to-principal) (សូម មើលកថាខណ្ឌខ៣៤)។

៦៩ អង្គភាពត្រូវជ្រើសរើសធាតុចូលដែលមានសង្គតិភាពជាមួយចរិតលក្ខណៈរបស់ទ្រព្យសកម្ម ឬបំណុល ដែលអ្នកចូលរួមទីផ្សារ នឹងត្រូវរាប់បញ្ចូល នៅក្នុងប្រតិបត្តិការសម្រាប់ទ្រព្យសកម្មឬបំណុល (មើលកថាខណ្ឌ ១១និង១២)។ នៅក្នុងករណីខ្លះ ចរិតលក្ខណៈទាំងនោះកើតចេញពីការអនុវត្តន៍ការកែសម្រួល ដូចជា តម្លៃបុព្វលាភឬតម្លៃអប្បហារ (ឧ.តម្លៃបុព្វលាភសម្រាប់ការត្រួតត្រាឬអប្បហារនៃភាគកម្មមិនមានការត្រួតត្រា)។ ទោះជាយ៉ាងណាការវាស់វែងតម្លៃសមស្របនឹងមិនរួមបញ្ចូលទៅក្នុងតម្លៃបុព្វលាភឬតម្លៃអប្បហារដែលមិនមានសង្គតិភាពជាមួយចំណែកគណនីនៅក្នុងស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុដែលតម្រូវ ឬអនុញ្ញាតិឱ្យការវាស់ វែងតម្លៃសមស្រប (មើល កថាខណ្ឌ ១៣និង១៤)។ តម្លៃបុព្វលាភ ឬ តម្លៃអប្បហារដែលឆ្លុះបញ្ចាំងអំពីទំហំដូចជាចរិតលក្ខណៈនៃការកាន់កាប់កម្មសិទ្ធិរបស់អង្គភាព (ជាពិសេស កត្តាជាឧបសគ្គ ដែលកែសម្រួលថ្លៃ សម្រង់

របស់ទ្រព្យសកម្មឬបំណុលពីព្រោះទំហំនៃការជួញដូរប្រចាំថ្ងៃរបស់ ទីផ្សារមិនមានភាពគ្រប់គ្រាន់ដើម្បីស្រូបយកបរិមាណនៃការកាន់កាប់ដែលគ្រប់គ្រង ដោយអង្គភាពមួយ ដូចបានបរិយាយនៅក្នុងកថាខណ្ឌ ៨០) ជាជាង ជាចរិតលក្ខណៈរបស់ទ្រព្យសកម្មឬបំណុល (ឧ.តម្លៃបុព្វលាភសម្រាប់ការត្រួតត្រា នៅពេលវាស់វែងតម្លៃសមស្រប របស់ភាគកម្មមានការត្រួតត្រា) មិនត្រូវបានអនុញ្ញាតិ នៅក្នុងការវាស់វែងតម្លៃសមស្រប ឡើយ។ ក្នុងគ្រប់ករណីទាំងអស់ ប្រសិនបើមាន ថ្លៃសម្រង់នៅក្នុងទីផ្សារ សកម្មមួយ (មានន័យថាធាតុចូលកម្រិតទី ១) សម្រាប់ទ្រព្យសកម្ម ឬ បំណុល អង្គភាពត្រូវប្រើថ្លៃនោះ ដោយមិនមានការកែសម្រួល នៅពេល វាស់វាស់វែងតម្លៃសមស្រប លើកលែងតែអ្វីដែលចែង នៅក្នុងកថាខណ្ឌ ៧៩។

## ធាតុចូលដែលផ្អែកលើថ្លៃលក់និងថ្លៃទិញ

៧០ ប្រសិនបើ ទ្រព្យសកម្មឬបំណុលដែលបានវាស់វែងតាមតម្លៃសមស្របមានថ្លៃទិញនិងថ្លៃលក់ (ឧ.ធាតុចូលពីទីផ្សារឈ្មួញកណ្តាល) ថ្លៃដែលស្ថិត នៅក្នុងគំលាតនៃថ្លៃលក់-ថ្លៃទិញ ដែលជាតំណាងដ៏ល្អបំផុតនៃតម្លៃសម ស្របតាមកាលៈទេសៈ នឹងត្រូវបានប្រើ ដើម្បីវាស់វែងតម្លៃសមស្រប ដោយមិនគិតថាធាតុចូលត្រូវបានគេធ្វើចំណាត់ថ្នាក់នៅត្រង់កន្លែងណានៅក្នុងឋានានុក្រមរបស់តម្លៃសមស្រប(មានន័យថា កម្រិតទី១ កម្រិតទី២ ឬកម្រិតទី៣ សូមមើលកថាខណ្ឌ ៧២-៩០) ឡើយ។ ការប្រើថ្លៃទិញ សម្រាប់ស្ថានភាពទ្រព្យសកម្ម និងការប្រើថ្លៃលក់សម្រាប់ស្ថានភាពបំណុល ត្រូវបានអនុញ្ញាតិក៏ប៉ុន្តែមិនតម្រូវឡើយ។

៧១ ស្តង់ដារបាយការណ៍ហិរញ្ញវត្ថុនេះមិនហាមឃាត់ការប្រើថ្លៃពាក់កណ្តាល ទីផ្សារ ឬវិធីនៃការកំណត់ថ្លៃផ្សេងទៀត ដែលត្រូវបានប្រើ ដោយអ្នកចូល រួមទីផ្សារ ដែលមធ្យោបាយជាក់ស្តែង សម្រាប់ការវាស់វែងតម្លៃសមស្រប នៅក្នុងគំលាតនៃថ្លៃលក់-ទិញ។

## ឋានានុក្រមតម្លៃសមស្រប

៧២ ដើម្បីបង្កើនសង្គតិភាព និងភាពអាចប្រៀបធៀបបាន នៅក្នុងការវាស់វែងតម្លៃសមស្របនិងការលាតត្រដាងពាក់ពន្ធ័ ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនេះ បង្កើតឋានានុក្រមតម្លៃសមស្រប ដែលបែងចែកតាមប្រភេទទៅជាបីកម្រិត (មើលកថាខណ្ឌ ៧៦ -៩០) ដែលជាធាតុចូល នៅក្នុងបច្ចេកទេសនៃការវាយតម្លៃ ដែលបានប្រើសម្រាប់វាស់វែងតម្លៃសមស្រប។ ឋានានុក្រមនៃតម្លៃសមស្រប ផ្តល់នូវអាទិភាពខ្ពស់បំផុតចំពោះថ្លៃសម្រង់ (មិនទាន់កែសម្រួល) នៅក្នុងទីផ្សារសកម្ម សម្រាប់ទ្រព្យសកម្ម ឬបំណុលដូចគ្នា (ធាតុចូលកម្រិតទី១) និងអាទិភាពទាបបំផុតចំពោះធាតុចូលមិនអាចអង្កេតបាន (ធាតុចូលកម្រិតទី៣)។

៧៣ នៅក្នុងករណីខ្លះ ធាតុចូលដែលបានប្រើ ដើម្បីវាស់វែងតម្លៃសមស្របសម្រាប់ទ្រព្យសកម្ម ឬបំណុល អាចត្រូវបានបែងចែកជាប្រភេទ តាមកម្រិតខុសៗគ្នា នៃឋានានុក្រម នៃតម្លៃសមស្រប។ ក្នុងករណីទាំងនោះ ការវាស់វែងតម្លៃសមស្របត្រូវបានបែងចែកទាំងស្រុងនៅក្នុងកម្រិតដូចគ្នានៃឋានានុក្រមតម្លៃសមស្រប ដូចជាធាតុចូលកម្រិតទាបបំផុត មានសារៈសំខាន់ចំពោះការវាស់វែងទាំងមូល។ ការវាយតម្លៃភាពមានសារៈសំខាន់នៃធាតុចូលសំខាន់ ចំពោះការវាស់វែងទាំងស្រុង ទាមទារនូវការវិនិច្ឆ័យ,

រាប់បញ្ចូលនូវកត្តាជាក់លាក់នានាចំពោះទ្រព្យសកម្ម ឬបំណុល។ ការកែសម្រួល ដើម្បីទទួលបាននៅពេលនៃការវាស់វែងដែលផ្អែកលើតម្លៃសមស្រប មានដូចជា ចំណាយលើការលក់ នៅពេលវាស់វែងតម្លៃសមស្របដកចេញចំណាយលើការលក់ ដោយមិនត្រូវបានគេរាប់បញ្ចូល នៅពេលកំណត់កម្រិត នៃឋានានុក្រមរបស់តម្លៃសមស្រប ដែលនៅក្នុងនោះការវាស់វែងតម្លៃសមស្របត្រូវបានគេបែងចែកជាប្រភេទ។

៧៤ ភាពអាចរកបាន នៃធាតុចូល ដែលពាក់ពន្ធ័និងអញ្ញាថាភាពទាក់ទងរបស់វាអាចមានផលប៉ះពាល់ដល់ការជ្រើសរើសបច្ចេកទេសវា នៃការវាយតម្លៃដែលសមស្រប (មើល កថាខណ្ឌ៦១)។ ទោះជាយ៉ាងណា ឋានានុក្រមតម្លៃសមស្របកំណត់អាទិភាពនូវធាតុចូល ចំពោះបច្ចេកទេស នៃការវាយតម្លៃ, មិនមែនបច្ចេកទេសវាយតម្លៃ ដែលបានប្រើដើម្បីវាស់វែងតម្លៃសមស្រប។ ឧទាហរណ៍ ការវាស់វែងតម្លៃសមស្របដែលបានបង្កើត ដោយ ប្រើបច្ចេកទេសតម្លៃបច្ចុប្បន្ន អាចត្រូវបានគេបែងចែកជាប្រភេទ នៅក្នុងកម្រិតទី២ ឬកម្រិតទី៣ អាស្រ័យលើធាតុចូល ដែលមានសារៈសំខាន់ចំពោះការវាស់វែងទាំងស្រុង និងកម្រិតនៃឋានានុក្រមរបស់តម្លៃសមស្របនៅក្នុងក្របខណ្ឌនៃធាតុចូលទាំងនោះត្រូវបានបែងចែកជាប្រភេទ។

៧៥ ប្រសិនបើធាតុចូលអាចអង្កេតបានទាមទារនូវការកែសម្រួលដោយប្រើធាតុចូលមិនអាចអង្កេតបាន ហើយការកែសម្រួលនោះជា ហេតុបណ្តាលឲ្យមានការវាស់វែងតម្លៃសមស្របតាមកម្រិតទាបជាង ឬកម្រិតខ្ពស់ជាងដ៏មានសារៈសំខាន់, ជាលទ្ធផលការវាស់វែង នឹងត្រូវបានបែងចែកជាប្រភេទនៅក្នុងកម្រិតទី៣ នៃឋានានុក្រមនៃតម្លៃសមស្រប។ ឧទាហរណ៍ ប្រសិនបើអ្នកចូលរួមទីផ្សារនឹងត្រូវរាប់បញ្ចូលនូវផលប៉ះពាល់នៃការកំហិត លើ

ការលក់របស់ទ្រព្យសកម្មនៅពេលប៉ាន់ស្មានថ្លៃរបស់ទ្រព្យសកម្ម អង្គភាពត្រូវកែសម្រួលថ្លៃសម្រង់ដើម្បីឆ្លុះបញ្ចាំងផលប៉ះពាល់នៃការដាក់កំហិត។ ប្រសិនបើ ថ្លៃសម្រង់គឺជាធាតុចូលកម្រិតទី ២ ហើយការកែសម្រួល គឺជាធាតុចូល មិនអាចអង្កេតបានដែលមានសារៈសំខាន់ ចំពោះការវាស់វែងទាំងស្រុង ការវាស់វែងនឹងត្រូវបែងចែកជាប្រភេទនៅក្នុងកម្រិតទី ៣ នៃឋានានុក្រមតម្លៃសមស្រប។

## ធាតុចូលកម្រិតទី១

៧៦ ធាតុចូលកម្រិតទី ១ គឺជាថ្លៃសម្រង់ (មិនទាន់កែសម្រួល) នៅក្នុងទីផ្សារសកម្មសម្រាប់ទ្រព្យសកម្ម ឬបំណុលដូចគ្នា ដែលអង្គភាពអាចទទួលបាននៅកាលបរិច្ឆេទនៃការវាស់វែង។

៧៧ ថ្លៃសម្រង់នៅក្នុងទីផ្សារសកម្មផ្តល់នូវភស្តុតាងដែលអាចជឿជាក់បំផុត នៃតម្លៃសមស្របនិងត្រូវបានគេប្រើដោយមិនមានការកែសម្រួល ដើម្បីវាស់វែងតម្លៃសមស្របនៅពេលណាដែលអាចរកបាន លើកលែងតែ ដូចបានបញ្ជាក់នៅក្នុងកថាខណ្ឌ ៧៩។

៧៨ ធាតុចូលកម្រិតទី ១ នឹងអាចរកបានសម្រាប់ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុជាច្រើន ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុមួយចំនួនអាចត្រូវបានគេដោះដូរនៅក្នុងទីផ្សារសកម្មចំរុះ (មានន័យថា នៅតាមទីផ្សារដោះដូរផ្សេងៗគ្នា)។ ហេតុដូច្នេះ ការផ្តោតនៅក្នុងកម្រិតទី១ គឺអាស្រ័យលើការកំណត់ លក្ខខណ្ឌទាំងពីរខាងក្រោមៈ

(ក) ទីផ្សារគោលសម្រាប់ទ្រព្យសកម្មឬបំណុល ឬនៅក្នុងករណី មិនមានទីផ្សារគោល គឺទីផ្សារដែលមាន អាទិភាពបំផុតសម្រាប់ទ្រព្យសកម្មឬបំណុលនោះ និង

(ខ) តើអង្គភាពអាចមានប្រតិបត្តិការសម្រាប់ទ្រព្យសកម្ម ឬបំណុល តាមថ្លៃនៅក្នុងទីផ្សារនាកាលបរិច្ឆេទនៃការវាស់វែង។

៧៩ អង្គភាពមិនត្រូវធ្វើការកែសម្រួលទៅលើធាតុចូលកម្រិត ១ លើកលែងតែកាលៈទេសៈដូចខាងក្រោមៈ

(ក) នៅពេល អង្គភាពកាន់កាប់ភាគច្រើននៃទ្រព្យសកម្ម ឬបំណុល ស្រដៀងគ្នា (តែមិនដូចគ្នា) (ឧ.មូលបត្របំណុល) ដែលត្រូវបាន វាស់វែងតាមតម្លៃសមស្រប ហើយថ្លៃសម្រង់ នៅក្នុងទីផ្សារសកម្ម អាចរកបាន ប៉ុន្តែមិនអាចទទួលបាន សម្រាប់ទ្រព្យសកម្ម និង បំណុលនិមួយៗដោយឡែកៗពីគ្នា (ជាមួយនឹងភាគច្រើននៃទ្រព្យ សកម្ម ឬបំណុលស្រដៀងគ្នាត្រូវបានកាន់កាប់ដោយអង្គភាព វានឹង មានការលំបាកដើម្បីទទួលបានព័ត៌មានអំពីថ្លៃសម្រាប់ទ្រព្យសកម្ម និងបំណុលនិមួយៗនាកាលបរិច្ឆេទនៃការវាស់វែង)។នៅក្នុងករណីនោះជាមធ្យោបាយជាក់ស្តែង អង្គភាព អាចវាស់វែងតម្លៃសមស្របដោយប្រើវិធីសាស្ត្រកំណត់ថ្លៃផ្សេងទៀតដែលមិនពឹង ផ្អែកទាំងស្រុងទៅលើថ្លៃសម្រង់ (ឧ.ការកំណត់ថ្លៃបែបម៉ាទ្រីស)។ ទោះជាយ៉ាងណា ការប្រើវិធីសាស្ត្រកំណត់ថ្លៃផ្សេងទៀត បណ្តាលឲ្យមានការបែងចែកប្រភេទនៃការវាស់វែងតម្លៃសមស្របនៅក្នុងកម្រិតទាបជាងនៃឋានានុក្រមតម្លៃសមស្រប។

(ខ) នៅពេលដែល ថ្លៃសម្រង់នៅក្នុងទីផ្សារសកម្មមិនតំណាងឱ្យតម្លៃសមស្រប នាកាលបរិច្ឆេទនៃការវាស់វែង។ នេះអាចជាករណីឧទាហរណ៍ ប្រសិនបើព្រឹត្តិការណ៍សំខាន់ៗ (ដូចជា ប្រតិបត្តិការនៅក្នុងទីផ្សារគោលទៅទីផ្សារគោល, ការជួញដូរនៅក្នុងទីផ្សារកម្រេជើងសារ ឬសេចក្តីជូនដំណឹង) កើតឡើងបន្ទាប់ពី ការបិទទីផ្សារ ប៉ុន្តែមុនកាលបរិច្ឆេទនៃការវាស់វែង។ អង្គភាពត្រូវបង្កើត និងត្រូវអនុវត្តដោយសង្គតិភាព នូវគោលនយោបាយ សម្រាប់កំណត់រកព្រឹត្តិការណ៍ទាំងនោះដែលអាចមានផលប៉ះពាល់ដល់ ការវាស់វែងតម្លៃសមស្រប។ ទោះជាយ៉ាងណា ប្រសិនបើថ្លៃសម្រង់ ត្រូវបានកែសម្រួលសម្រាប់ព័ត៌មានថ្មី ការកែសម្រួលនឹងបណ្តាលឱ្យការវាស់វែងតម្លៃសមស្របបានបែងចែកជាប្រភេទនៅក្នុងកម្រិតទាបជាងនៃឋានានុក្រមតម្លៃសមស្រប។

(គ) នៅពេលវាស់វែងតម្លៃសមស្របរបស់បំណុល ឬឧបករណ៍មូលធនផ្ទាល់របស់អង្គភាព ដោយប្រើថ្លៃសម្រង់សម្រាប់ធាតុ ដូចគ្នាដែលបានជួញដូរជាទ្រព្យសកម្មនៅទីផ្សារសកម្ម ហើយថ្លៃនោះចាំបាច់ត្រូវតែ កែសម្រួលសម្រាប់បណ្តាកត្តាជាក់លាក់ចំពោះធាតុនោះ ឬទ្រព្យសកម្មនោះ (សូមមើលកថាខណ្ឌ ៣៩)។ ប្រសិនបើ មិនមានការកែសម្រួល ចំពោះថ្លៃសម្រង់របស់ទ្រព្យសកម្ម មិនត្រូវបានទាមទារ លទ្ធផលគឺ ការវាស់វែងតម្លៃសមស្រប ត្រូវបានបែងចែកជាប្រភេទនៅក្នុងកម្រិតទី ១ នៃឋានានុក្រមតម្លៃសមស្រប។ ទោះជាយ៉ាងណា ការកែសម្រួកណាមួយ ចំពោះថ្លៃសម្រង់របស់ទ្រព្យ

សកម្ម បណ្ដាលឱ្យការវាស់វែងតម្លៃសមស្របបានបែងចែកនៅក្នុងកម្រិតទាបជាងនៃឋានានុក្រមតម្លៃសមស្រប។

៨០ ប្រសិនបើអង្គភាពកាន់កាប់ស្ថានភាពទ្រព្យសកម្ម ឬបំណុលទោល (ដោយរួមមាន ស្ថានភាពដែលរួមមានទ្រព្យសកម្មឬបំណុលដូចគ្នា ដូចជាការកាន់កាប់ឧបករណ៍ហិរញ្ញវត្ថុ) ហើយទ្រព្យសកម្ម ឬបំណុលត្រូវបានជួញដូរ នៅក្នុងទីផ្សារសកម្ម តម្លៃសមស្របរបស់ទ្រព្យសកម្ម ឬបំណុល ត្រូវតែវាស់វែងនៅក្នុងកម្រិតទី ១ ថាជាលទ្ធផលនៃថ្លៃសម្រង់ សម្រាប់ទ្រព្យសកម្ម ឬបំណុលនិមួយៗ និងបរិមាណ ដែលកាន់កាប់ដោយអង្គភាព។ នោះគឺជាករណី ប្រសិនបើ ទំហំនៃការជួញដូរប្រចាំថ្ងៃធម្មតារបស់ទីផ្សារមិនគ្រប់គ្រាន់ដើម្បីស្រូបយកបរិមាណដែលកាន់កាប់និងដាក់ការបញ្ជាទិញ ដើម្បីលក់ស្ថានភាពនោះ នៅក្នុងប្រតិបត្តិការទោល អាចមានផលប៉ះពាល់ដល់ថ្លៃសម្រង់។

## ធាតុចូលកម្រិតទី២

៨១ ធាតុចូលកម្រិតទី ២ គឺជាធាតុចូលដែលមិនមែនជាថ្លៃសម្រង់ ដែលមាននៅក្នុងធាតុចូលកម្រិតទី ១ ដែលអាចអង្កេតបានសម្រាប់ទ្រព្យសកម្ម ឬបំណុលដោយផ្ទាល់ ឬដោយប្រយោល។

៨២ ប្រសិនបើទ្រព្យសកម្មឬបំណុលមានលក្ខខណ្ឌកំណត់ជាក់លាក់ (លក្ខខណ្ឌតាមកិច្ចសន្យា) ធាតុចូលកម្រិតទី ២ ត្រូវតែជាធាតុដែលអាចអង្កេតបានសម្រាប់លក្ខខណ្ឌពេញលេញ ដ៏មានសារៈសំខាន់របស់ ទ្រព្យសកម្ម ឬបំណុល។ ធាតុចូលកម្រិតទី២ រួមមានដូចខាងក្រោម:

(ក) ថ្លៃសម្រង់របស់ទ្រព្យសកម្ម ឬបំណុលស្រដៀងគ្នា នៅក្នុងទីផ្សារសកម្ម។

(ខ) ថ្លៃសម្រង់សម្រាប់ទ្រព្យសកម្មឬបំណុលដូចគ្នានៅក្នុងទីផ្សារ ដែលមិនសកម្ម។

(គ) ធាតុចូលផ្សេងទៀតដែលមិនមែនថ្លៃសម្រង់ ដែលអាចអង្កេតបានសម្រាប់ទ្រព្យសកម្មឬបំណុលនោះ ឧទាហរណ៍:

(១) អត្រាការប្រាក់និងអត្រាចំណេញដែលអាចអង្កេតបាន នៅក្នុងចន្លោះសម្រង់ទូទៅ

(២) ភាពងាយប្រែប្រួលដែលតម្រូវ

(៣) តំណាងឥណទាន

(ឃ) ធាតុចូលជាមាណីករណ៍ទីផ្សារ

៨៣ ការកែសម្រួលលើធាតុចូលកម្រិតទី ២ នឹងមានការប្រែប្រួល អាស្រ័យលើបណ្ដាកត្តាជាក់លាក់ដែលមានចំពោះទ្រព្យសកម្ម ឬបំណុល។ កត្តាទាំងនោះរួមមានដូចខាងក្រោមៈ

(ក) លក្ខខណ្ឌ ឬទីតាំងរបស់ទ្រព្យសកម្ម

(ខ) វិសាលភាពដែលធាតុចូលទាក់ទងនឹងធាតុនានា ដែលអាចប្រៀបធៀបបានទៅនឹងទ្រព្យសកម្ម ឬបំណុលនោះ(រួមមានទាំងកត្តានានាដែលបានបរិយាយនៅក្នុងកថាខណ្ឌ ៣៩) និង

(គ) ទំហំឬកម្រិតនៃសកម្មភាពនៅក្នុងទីផ្សារដែល នៅក្នុងនោះធាតុចូលត្រូវបានគេអង្កេត។

៨៤ ការកែសម្រួលទៅលើធាតុចូលកម្រិតទី ២ ដែលមានសារៈសំខាន់ ចំពោះការវាស់វែងទាំងមូលបណ្ដាលឱ្យការវាស់វែងតម្លៃសមស្រប បានបែងចែក

ជាប្រភេទស្ថិតនៅក្នុងកម្រិតទី ៣ នៃឋានានុក្រមតម្លៃសមស្រប ប្រសិនបើការកែសម្រួលនោះប្រើប្រាស់ធាតុចូលដែលមិនអាចអង្កេតបានសំខាន់ៗ។

៨៥ កថាខណ្ឌ ខ៣៥ បរិយាយការប្រើប្រាស់ធាតុចូលកម្រិតទី ២ សម្រាប់ទ្រព្យសកម្ម និងបំណុលមួយចំនួន។

## ធាតុចូលកម្រិតទី៣

៨៦ ធាតុចូលកម្រិតទី ៣ គឺជាធាតុចូល មិនអាចអង្កេតបានសម្រាប់ទ្រព្យសកម្ម និងបំណុល។

៨៧ ធាតុចូល មិនអាចអង្កេតបានត្រូវតែប្រើ ដើម្បីវាស់វែងតម្លៃសមស្របទៅតាមវិសាលភាព ដែលធាតុចូល មិនអាចអង្កេតបានពាក់ពន្ធ័មិនអាចរកបានដោយអនុញ្ញាតិ សម្រាប់ស្ថានភាព ដែលមានសកម្មភាពទីផ្សារតិចតួចសម្រាប់ទ្រព្យសកម្ម ឬបំណុលនាកាលបរិច្ឆេទវាស់វែង។ ទោះជាយ៉ាងណាគោលបំណងនៃការវាស់វាស់តម្លៃសមស្រប នៅតែដដែល មានន័យថាជាថ្លៃដកថយនាកាលបរិច្ឆេទនៃការវាស់វែង ដែលឈរលើទស្សនទាន របស់អ្នកចូលរួមទីផ្សារ ដែលកាន់កាប់ទ្រព្យសកម្ម ឬមានបំណុល។ ដូច្នេះ ធាតុចូលមិនអាចអង្កេតបានត្រូវឆ្លុះបញ្ចាំងនូវការសន្មត ដែលអ្នកចូលរួម ទីផ្សារនឹងប្រើនៅពេលកំណត់ថ្លៃទ្រព្យសកម្ម ឬបំណុល ដោយរួមមាន ទាំងការសន្មតអំពីហានិភ័យផងដែរ។

៨៨ ការសន្មតអំពីហានិភ័យរួមមានហានិភ័យដែលបង្កប់ នៅក្នុងបច្ចេកទេសនៃការវាយតម្លៃជាក់លាក់មួយដែលបានប្រើដើម្បីវាស់វេងតម្លៃសមស្រប (ដូចជា ម៉ូឌែលនៃការកំណត់ថ្លៃ) និងហានិភ័យដែលបង្កប់នៅក្នុងធាតុចូលដែលដាក់នៅក្នុងបច្ចេកទេសនៃការវាយតម្លៃ។ ការវាស់វែងមួយដែលមិន

រាប់បញ្ចូលនូវការកែសម្រួលសម្រាប់ហានិភ័យនឹងមិនតំណាងឱ្យការវាស់វែងតម្លៃសមស្របឡើយ ប្រសិនបើអ្នកចូលរួមទីផ្សារនឹងដាក់បញ្ចូលវា នៅពេលកំណត់ថ្លៃទ្រព្យសកម្មឬបំណុល។ ឧទាហរណ៍ វាអាចជាការចាំបាច់ដើម្បីរួមបញ្ចូល ការកែសម្រួលហានិភ័យ នៅពេលមានភាពមិនប្រាកដប្រជានៃការវាស់វែងដ៏សំខាន់ (ឧ.នៅពេលមានការថយចុះនូវទំហំ ឬកម្រិតនៃសកម្មភាពនៅពេលប្រៀបធៀបជាមួយសកម្មភាពជាធម្មតារបស់ទីផ្សារសម្រាប់ទ្រព្យសកម្មឬបំណុលនោះ ឬទ្រព្យសកម្មឬបំណុលស្រដៀងគ្នា, ហើយ អង្គភាពបានកំណត់ថាថ្លៃប្រតិបត្តិការ ឬថ្លៃសម្រង់មិនតំណាងឱ្យតម្លៃសមស្រប ដូចបានបរិយាយនៅក្នុងកថាខណ្ឌខ៣៧-ខ៤៧)។

៨៩ អង្គភាពត្រូវបង្កើតធាតុចូលដែលមិនអាចអង្កេតបាន ដោយប្រើព័ត៌មាន ល្អបំផុតដែលមានតាមកាលៈទេសៈ ដែលអាចដាក់បញ្ចូលទៅក្នុងទិន្នន័យផ្ទាល់របស់អង្គភាព។ ដើម្បីបង្កើតធាតុចូល ដែលមិនអាចអង្កេតបានអង្គ-ភាពអាចចាប់ផ្តើម ពីទិន្នន័យផ្ទាល់របស់អង្គភាព ប៉ុន្តែអង្គភាពត្រូវតែកែសម្រួលទិន្នន័យទាំងមូល ប្រសិនបើព័ត៌មានដែលមាននោះបង្ហាញថា អ្នកចូល រួមទីផ្សារនឹងប្រើទិន្នន័យផ្សេង ឬមាន អ្វីពិសេសចំពោះអង្គភាព ដែលមិន អាចរកបានចំពោះអ្នកចូលរួមទីផ្សារ (ឧ.ការបង្កើតឥទ្ធិពលរួម នៅកម្រិត អង្គភាព)។ អង្គភាពមិនចាំបាច់ត្រូវខិតខំខ្លាំងពេកដើម្បីទទួល បានព័ត៌មាន អំពីការសន្មតរបស់អ្នកចូលរួមទីផ្សារឡើយ។ ទោះជាយ៉ាង ណាអង្គភាពត្រូវដាក់បញ្ចូលរាល់ព័ត៌មាន អំពីការសន្មតរបស់អ្នកចូលរួមទីផ្សារដែលអាចរកបានដោយសមរម្យ ។ ធាតុចូលដែលមិនអាច អង្កេតបានដែលបានបង្កើតឡើងតាមរបៀបដូចដែលបានបរិយាយ ខាងលើ ត្រូវបាន

ចាត់ទុកថាជាការសន្មតរបស់អ្នកចូលរួមទីផ្សារ និងឆ្លើយតបគោលបំណង នៃការវាស់ វែងតម្លៃសមស្រប។

៩០ កថាខណ្ឌ ខ៣៦ បរិយាយអំពីការប្រើប្រាស់ធាតុចូលកម្រិតទី ៣ សម្រាប់ទ្រព្យសកម្មនិងបំណុលមួយចំនួន។

## ការលាតត្រដាងព័ត៌មាន

**៩១ អង្គភាពត្រូវលាតត្រដាងព័ត៌មានដែលជួយអ្នកប្រើរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួនវាយតម្លៃបានទាំងពីរចំណុចដូចខាងក្រោមៈ**

**(ក) សម្រាប់ទ្រព្យសកម្មនិងបំណុលដែលត្រូវបានវាស់វែងតាមតម្លៃ សមស្របឈរលើមូលដ្ឋានទៀងទាត់ ឬមិនទៀតទាត់ នៅក្នុង របាយការណ៍ស្ថានភាពហិរញ្ញវត្ថុបន្ទាប់ពីការទទួលស្គាល់លើកដំបូង នូវបច្ចេកទេសនៃការវាយតម្លៃនិងធាតុចូលដែលបានប្រើ ដើម្បី បង្កើតការវាស់វែងទាំងនោះ។**

**(ខ) សម្រាប់ការវាស់វាស់វែងតម្លៃសមស្របដែលកើតឡើងជាទៀងទាត់ដោយប្រើធាតុចូលមិនអាចអង្កេតបានសំខាន់ៗ (កម្រិតទី៣), ផលប៉ះពាល់នៃការវាស់វែងលើចំណេញ ឬខាត ឬចំណេញ បន្ទាប់ បន្សំផ្សេងៗ សម្រាប់កាលបរិច្ឆេទនោះ។**

៩២ ដើម្បីឆ្លើយតបទៅនឹងកម្មវត្ថុនៅក្នុងកថាខណ្ឌ៩១ អង្គភាពត្រូវពិចារណាចំណុចទាំងអស់ខាងក្រោមៈ

(ក) កម្រិតលំអិតដែលចាំបាច់ដើម្បីបំពេញការតម្រូវ នៃការលាតត្រដាងព័ត៌មាន

(ខ) កម្រិតនៃការបញ្ជាក់ន័យដែលដាក់លើការតម្រូវផ្សេងៗ

(គ) ទំហំនៃការរួមផ្ដុំឬការមិនរួមផ្ដុំដែលត្រូវអនុវត្ត

(ឃ) តើអ្នកប្រើរបាយការណ៍ហិរញ្ញវត្ថុត្រូវការព័ត៌មានបន្ថែម ដើម្បីវាយតម្លៃព័ត៌មានជាបរិមាណវិស័យ ដែលបានលាតត្រដាងឬទេ។

ប្រសិនបើ ការលាតត្រដាងដែលបានផ្ដល់អនុលោមតាម ស្ដង់ដារបាយ-ការណ៍ ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនេះ និងស្ដង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិផ្សេងទៀត មិនគ្រប់គ្រាន់ដើម្បីឆ្លើយតបទៅនឹងគោលបំណងនានានៅក្នុងកថាខណ្ឌ ៩១ អង្គភាពត្រូវលាតត្រដាងព័ត៌មានបន្ថែមដែលចាំបាច់ដើម្បីឆ្លើយតបទៅនឹងគោលបំណងទាំងនោះ។

៩៣ ដើម្បីឆ្លើយតបទៅនឹង គោលបំណងនៃកថាខណ្ឌ ៩១ អង្គភាពត្រូវលាតត្រដាងជាអប្បបរមានូវព័ត៌មាន ដូចខាងក្រោមសម្រាប់ថ្នាក់និមួយៗ នៃទ្រព្យសកម្មនិងបំណុល (មើល កថាខណ្ឌ ៩៤ សម្រាប់ព័ត៌មានស្ដីពីការកំណត់ថ្នាក់សមស្របរបស់ទ្រព្យសកម្ម និងបំណុល) ដែលបានវាស់វែងតាមតម្លៃសមស្រប (ដោយរួមមានការវាស់វែងផ្អែកលើតម្លៃសមស្របដែលស្ថិតនៅក្នុងក្របខណ្ឌនៃស្ដង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនេះ) នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុបន្ទាប់ពីការទទួលស្គាល់លើកដំបូង:

(ក) សម្រាប់ការវាស់វែងតម្លៃសមស្របដែលធ្វើឡើងជាទៀងទាត់ និងមិនទៀងទាត់ការវាស់វែងតម្លៃសមស្របនាកាលបរិច្ឆេទរាយការណ៍, ហើយ សម្រាប់ការវាស់វែងតម្លៃសមស្របដែលកើតឡើងមិនទៀងទាត់នូវហេតុផលសម្រាប់ការវាស់វែង។ ការវាស់វែងតម្លៃសមស្របដែលកើតឡើងជាទៀងទាត់សម្រាប់ទ្រព្យសកម្ម ឬបំណុល គឺជាការវាស់វែងដែលស្ដង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុតម្រូវ ឬ

អនុញ្ញាតិនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ នាចុងការិយ-បរិច្ឆេទរាយការណ៍និមួយៗ។ ការវាស់វែងតម្លៃសមស្រប ដែលមិនកើតឡើងជាទៀងទាត់សម្រាប់ទ្រព្យសកម្មនិងបំណុលគឺជាការវាស់វែង ដែលស្តង់ដារបាយការណ៍ទាក់ទងនឹង ហិរញ្ញវត្ថុតម្រូវ ឬអនុញ្ញាតិ នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ នៅតាមកាលៈទេសៈ (ឧ. នៅពេលអង្គភាពវាស់វែងទ្រព្យសកម្ម ដែលបានរក្សាទុកសម្រាប់លក់តាមតម្លៃសមស្រប ដកចេញចំនាយដើម្បីលក់ ដោយអនុលោមតាម ស្តង់ដារបាយការណ៍ទាក់ទងនឹង ហិរញ្ញវត្ថុ ៥ *ទ្រព្យសកម្ម រយៈពេលវែងរក្សាទុកសម្រាប់លក់ និងប្រតិបត្តការ បានបញ្ឈប់* ដោយសារតែតម្លៃសមស្របរបស់ទ្រព្យសកម្មដក ចេញចំណាយដើម្បីលក់មានតម្លៃទាបជាងបរិមាណលើបញ្ជីរបស់វា)។

(ខ) សម្រាប់ការវាស់វែងតម្លៃសមស្របដែលធ្វើឡើងជាទៀងទាត់ និងមិនទៀងទាត់ កម្រិតនៃឋានានុក្រមរបស់តម្លៃសមស្រប ដែលនៅក្នុងនោះការវាស់វែងតម្លៃសមស្របត្រូវបានបែងចែកជាប្រភេទនៅក្នុងផ្នែកដែលពួកស្ថិតនៅ (កម្រិត១, កម្រិត២ ឬ កម្រិត៣)។

(គ) សម្រាប់ទ្រព្យសកម្មនិងបំណុលដែលកាន់កាប់នាចុងការិយបរិច្ឆេទរាយការណ៍ ដែលត្រូវបានវាស់វែង តាមតម្លៃសមស្របឈរលើ មូលដ្ឋានទៀងទាត់ បរិមាណនៃការផ្ទេរណាមួយរវាងកម្រិត ១ និងកម្រិត ២ នៃឋានានុក្រមតម្លៃសមស្រប ហេតុផលសម្រាប់ការផ្ទេរទាំងនោះ និងគោលនយោបាយរបស់អង្គភាព សម្រាប់កំណត់នៅពេលនៃការផ្ទេរ រវាងកម្រិតទាំងនោះ ហាក់ដូចជាបានកើតឡើង

(មើលកថាខណ្ឌ ៩៥)។ ការផ្ទេរទៅក្នុងកម្រិតនិមួយៗ ត្រូវតែលាតត្រដាងនិងពិភាក្សាដាច់ដោយឡែកពីការផ្ទេរចេញពីកម្រិតនិមួយៗ។

(ឃ) សម្រាប់ការវាស់វែងតម្លៃសមស្របដែលធ្វើឡើងជាទៀងទាត់ និងមិនទៀងទាត់ដែលបានបែងចែកនៅក្នុងកម្រិត ២ និងកម្រិត ៣ នៃឋានានុក្រមតម្លៃសមស្រប ការបរិយាយនៃបច្ចេកទេសវាយតម្លៃ និងធាតុចូល ដែលបានប្រើនៅក្នុង ការវាស់វែងតម្លៃសមស្រប។ ប្រសិនបើ មានការផ្លាស់ប្ដូរនៅក្នុងបច្ចេកទេសវាយតម្លៃ (ឧ.ការផ្លាស់ប្ដូរពីវិធីសាស្ត្រទីផ្សារទៅវិធីសាស្ត្រ ឬការប្រើបច្ចេកទេស នៃការវាយតម្លៃបន្ថែម) អង្គភាពត្រូវលាតត្រដាងការផ្លាស់ប្ដូរនោះ និងហេតុផលនៃការផ្លាស់ប្ដូរ។ សម្រាប់ការវាស់វែងដែលបានបែងចែកនៅក្នុងកម្រិត៣នៃឋានានុក្រមតម្លៃសមស្រប អង្គភាព ត្រូវបង្ហាញព័ត៌មានជាបរិមាណវិស័យ អំពីធាតុចូល ដែលមិនអាចអង្កេតបានដែលបានប្រើនៅក្នុងការវាស់វែងតម្លៃសមស្រប។ អង្គភាពមិនត្រូវបានតម្រូវឱ្យបង្កើតព័ត៌មានជាបរិមាណវិស័យដើម្បីអនុលោមតាមការតម្រូវសម្រាប់ការលាតត្រដាងឡើយ ប្រសិនបើ ធាតុចូលដែលមិនអាចអង្កេតបានមានលក្ខខណៈជាបរិមាណវិស័យនោះ មិនត្រូវបានបង្កើតឡើង ដោយអង្គភាព នៅពេលវាស់វែងតម្លៃសមស្រប (ឧ.នៅពេលអង្គភាពប្រើថ្លៃដែលបានមកពី ប្រតិបត្តិការមុនៗ ឬព័ត៌មាន អំពីការកំណត់ថ្លៃដោយគ្មានការកែសម្រួលពី ភាគីទីបី)។ ទោះជាយ៉ាងណា នៅពេលផ្ដល់នូវការលាតត្រដាងនេះ អង្គភាពមិនអាចបោះបង់ចោលធាតុចូល ដែលមិនអាចអង្កេតបាន ដែល

មានក្ខខណៈជាបរិមាណវិស័យ ដែលមានសារៈសំខាន់ចំពោះការវាស់វែងតម្លៃសមស្របនិងអាចរកបានយ៉ាងសមរម្យដោយអង្គភាព។

(ង) សម្រាប់ការវាស់វែងតម្លៃសមស្រប ដែលបានបែងចែកជាប្រភេទនៅក្នុងកម្រិត៣នៃឋានានុក្រមតម្លៃសមស្រប ការសម្របសម្រួលរវាងសមតុល្យដើមគ្រា និងសមតុល្យចុងគ្រា ដោយលាតត្រដាងដាច់ដោយឡែកនូវបម្រែបម្រួលនៅក្នុងការិយបរិច្ឆេទ ដែលអាចកំណត់បានដូចខាងក្រោមៈ

(១) ចំណេញឬខាតសរុបសម្រាប់ការិយបរិច្ឆេទបានទទួលស្គាល់នៅក្នុងផ្នែកចំណេញ ឬខាត និងធាតុតាមជួរដេកនៅក្នុងផ្នែកចំណេញ ឬខាត ដែលចំណេញ ឬខាតនោះ ត្រូវបានទទួលស្គាល់។

(២) ចំណេញ ឬខាតសរុប សំរាប់ការិយបរិច្ឆេទបានទទួលស្គាល់នៅក្នុងផ្នែកចំណេញបន្ទាប់បន្សំផ្សេងៗ និងធាតុតាមជួរដេកនៅក្នុងផ្នែកចំណេញបន្ទាប់បន្សំផ្សេងៗ ដែលនៅក្នុងនោះចំណេញ ឬខាត ត្រូវបានទទួលស្គាល់។

(៣) ការទិញ ការលក់ ការបោះផ្សាយ និងការទូទាត់ (ប្រភេទនៃបម្រែបម្រួលទាំងនោះ ត្រូវលាតត្រដាងដាច់ដោយឡែកពី គ្នា)។

(៤) បរិមាណនៃការផ្ទេរចូលទៅនិងចេញពីកម្រិតទី ៣ នៃឋានានុក្រមតម្លៃសមស្រប ហេតុផលនៃការផ្ទេរទាំងនោះ និងគោលនយោបាយរបស់អង្គភាពសម្រាប់ការកំណត់នៅពេលផ្ទេររវាងកម្រិតនានា ហាក់ដូចជាបានកើតឡើង (មើល កថា

ខណ្ឌ ៩៥)។ ការផ្ទេរចូលទៅក្នុងកម្រិត៣ត្រូវបានលាតត្រដាងនិងពិភាក្សាដាច់ដោយឡែកពីការផ្ទេរចេញកម្រិត៣។

(ច) សម្រាប់ការវាស់វែងតម្លៃសមស្របជាទៀងទាត់ដែលបានបែងចែកជាប្រភេទនៅក្នុងកម្រិត ៣ នៃឋានានុក្រមតម្លៃសមស្របបរិមាណនៃចំណេញ ឬខាត សម្រាប់ការិយបរិច្ឆេទនៅក្នុង (ង) និង (ឈ) ដែលរួមមាននៅក្នុងផ្នែកចំណេញ ឬខាត ដែលអាចរួមចំណែកដល់បម្រែបម្រួលចំណេញ ឬខាត មិនទាន់ជាក់ស្តែងទាក់ទងនឹងទ្រព្យសកម្ម និងបំណុលទាំងនោះដែលបានកាន់កាប់នាចុងការិយបរិច្ឆេទរាយការណ៍, និងធាតុនិមួយៗនៅក្នុងផ្នែកចំណេញ ឬខាត ដែលចំណេញឬខាតមិនទាន់ជាក់ស្តែងទាំងនោះត្រូវបានទទួលស្គាល់។

(ឆ) សម្រាប់ការវាស់វែងតម្លៃសមស្របទាំងទៀងទាត់និងមិនទៀងទាត់ដែល បានបែងចែកជាប្រភេទនៅក្នុងកម្រិត ៣ នៃឋានានុក្រម នៃតម្លៃ សមស្រប, ការបរិយាយអំពីដំណើរការនៃការវាយតម្លៃ ដែលបាន ប្រើដោយអង្គភាព(រួមមានឧទាហរណ៍ របៀបដែលអង្គភាពសម្រេច អំពីបណ្តាគោលនយោបាយ និងបែបបទនៃការវាយតម្លៃនិងវិភាគ បម្រែបម្រួលនៅក្នុងការវាស់វែងតម្លៃសមស្របពីការិយបរិច្ឆេទមួយទៅការិយបរិច្ឆេទមួយទៀត)។

(ជ) សម្រាប់ការវាស់វែងតម្លៃសមស្របទៀងទាត់ដែលបានដាក់នៅក្នុងកម្រិត៣នៃឋានានុលក្រមតម្លៃសមស្របៈ

(១) សម្រាប់ការវាស់វែងទាំងអស់នេះ ការបរិយាយខ្លីៗ អំពីភាពងាយប្រែប្រួល នៃការវាស់វែងតម្លៃសមស្រប ទៅនឹងបម្រែ បម្រួលនៃធាតុចូល ដែលមិនអាចអង្កេតបាន ប្រសិនបើ បម្រែ

ប្រែប្រួលនៅក្នុងធាតុចូលទាំងនោះមានបរិមាណខុសគ្នា ដែលអាចធ្វើឱ្យមានឥទ្ធិពលជាដុំកំភួនដល់ការវាស់វែងតម្លៃសមស្របខ្ពស់ជាង ឬទាបជាង។ ប្រសិនបើមាន អន្តរទំនាក់ ទំនងរវាងធាតុចូលទាំងនោះ និងធាតុចូល មិនអាចអង្កេតបានផ្សេងៗទៀត នៅក្នុងការវាស់វែងតម្លៃសមស្របអង្គភាព ត្រូវផ្តល់នូវការបរិយាយ នៃអន្តរទំនាក់ទំនងទាំងនោះ និង របៀបដែលពួកគេអាចពង្រីក ឬសម្រាលនូវ ផលប៉ះពាល់នៃបម្រែបម្រួលនានា នៅក្នុងធាតុចូលដែលមិនអាចអង្កេត បានលើការវាស់វែងតម្លៃសមស្រប។ ដើម្បីអនុលោមតាម ការតម្រូវសម្រាប់ការលាតត្រដាងនោះ ការបរិយាយខ្លីៗនៃភាពងាយប្រែប្រួលនៅក្នុងធាតុចូលដែលមិនអាចអង្កេតបានត្រូវដាក់បញ្ចូល នៅក្នុងកម្រិតទាបបំផុត នូវធាតុចូល ដែល មិនអាចអង្កេតបាន ដែលបានលាតត្រដាង នៅពេលអនុ-លោម តាម (ឃ)។

(២) សម្រាប់បំណុលនិងទ្រព្យសកម្មហិរញ្ញវត្ថុ ប្រសិបើមានការប្រែប្រួលមួយ ឬច្រើននៃធាតុចូលដែលមិនអាចអង្កេតបានដើម្បីឆ្លុះបញ្ចាំងនូវការសន្មតផ្សេងទៀតដែលអាចមាននឹងធ្វើឱ្យមានការផ្លាស់ប្តូរជាដុំកំភួន លើតម្លៃសមស្រប អង្គភាពត្រូវវាយការណ៍អំពីហេតុការណ៍នោះ និងលាតត្រដាងផលប៉ះពាល់នៃការផ្លាស់ប្តូរទាំងនោះ។ អង្គភាព ត្រូវលាតត្រដាងផលប៉ះពាល់ នៃការផ្លាស់ប្តូរទាំងនោះ ដើម្បីឆ្លុះបញ្ចាំងនូវការសន្មតផ្សេងទៀត ដែលអាចមានត្រូវបានគេគណនា។

សម្រាប់គោលបំណងនោះភាពមានសារៈសំខាន់ ត្រូវតែបាន វិនិច្ឆ័យដោយយោងតាមផ្នែកចំណេញឬខាត និងទ្រព្យសកម្ម សរុបនិងបំណុលសរុប ឬនៅពេលដែលការផ្លាស់ប្តូរក្នុងតម្លៃ សមស្រប ត្រូវបានទទួលស្គាល់ នៅក្នុងផ្នែកចំណូលបន្ទាប់ បន្សំ, ទៅក្នុងមូលធនផ្ទាល់។

(ឈ) សម្រាប់ការវាស់វែង តម្លៃសមស្របទៀងទាត់ និងមិនទៀងទាត់ ប្រសិនបើ ការប្រើល្អបំផុតនិងខ្ពស់បំផុតនៃទ្រព្យសកម្ម មិនមែន ហិរញ្ញវត្ថុខុសគ្នាពី ការប្រើប្រាស់បច្ចុប្បន្នរបស់ខ្លួន អង្គភាពត្រូវ លាតត្រដាង នូវហេតុការណ៍នោះ និងមូលហេតុ ដែលទ្រព្យសកម្ម មិនមែនហិរញ្ញវត្ថុត្រូវបានគេប្រើតាមរបៀបមួយដែលខុសគ្នាពីការ ប្រើល្អបំផុតនិងខ្ពស់បំផុតនោះ។

៩៤ អង្គភាពត្រូវកំណត់ថ្នាក់សមរម្យសម្រាប់ទ្រព្យសកម្ម និងបំណុល ដោយ ឈរលើមូលដ្ឋានខាងក្រោម:

(ក) សភាព, ចរិតលក្ខណៈនិងហានិភ័យរបស់ទ្រព្យសកម្ម និងបំណុល និង

(ខ) កម្រិតនៃឋានានុក្រមតម្លៃសមស្រប ដែលនៅក្នុងនោះ ការវាស់វែង តម្លៃសមស្របត្រូវបានបែងចែក ជាប្រភេទ។

ចំនួននៃថ្នាក់អាចច្រើនជាងការវាស់វែងតម្លៃសមស្របដែលបានបែងចែក ប្រភេទនៅក្នុងកម្រិត៣នៃឋានានុក្រមតម្លៃសមស្រប ពីព្រោះការវាស់វែង ទាំងនោះមានកម្រិត នៃភាពមិនប្រាកដប្រជា និងអញ្ញាថាភាពធំជាង។ការ កំណត់ថ្នាក់សមរម្យសម្រាប់ទ្រព្យសកម្មនិងបំណុលសម្រាប់ការលាត ត្រដាងតម្លៃសមស្របគួរតែបានផ្តល់ឱ្យនូវការវិនិច្ឆ័យ ដែលបានតម្រូវ។

ថ្នាក់ មួយនៃទ្រព្យសកម្មនិងបំណុលនឹងតែងតែតម្រូវនូវភាពមិនប្រមូលផ្តុំធំជាង ធាតុនិមួយៗ ដែលបានបង្ហាញ នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។ ទោះជាយ៉ាងណា អង្គភាពត្រូវផ្តល់ព័ត៌មានគ្រប់គ្រាន់ ដើម្បីអនុញ្ញាតិឱ្យមាន ការសម្របសម្រួលចំពោះធាតុនិមួយៗ ដែលបានបង្ហាញ នៅក្នុងរបាយ- ការណ៍ស្ថានភាពហិរញ្ញវត្ថុ។ ប្រសិនបើ ស្តង់ដាររបាយការណ៍ទាក់ទងនឹង ហិរញ្ញវត្ថុអន្តរជាតិផ្សេងទៀត បញ្ជាក់អំពីថ្នាក់នៃទ្រព្យសកម្ម និងបំណុល អង្គភាពអាចប្រើថ្នាក់នោះ ដើម្បីផ្តល់នូវការលាតត្រដាងដែលបានតម្រូវ នៅក្នុងស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនោះ ប្រសិនបើ ថ្នាក់នោះបំពេញតាមការតម្រូវនៅក្នុងកថាខណ្ឌនេះ។

៩៥ អង្គភាពត្រូវលាតត្រដាង និងអនុវត្តតាមដោយសង្គតិភាពនូវគោលនយោ-បាយរបស់ខ្លួនសម្រាប់ការកំណត់ នៅពេលដែលការផ្ទេររវាងកម្រិតនានានៃឋានានុក្រមតម្លៃសមស្រប ហាក់ដូចជាត្រូវបានកើតឡើង ដោយអនុ-លោមតាមកថាខណ្ឌ៩៣(គ)និង(ង)(៤)។គោលនយោបាយអំពីការកំណត់ពេលវេលា នៃការទទួលស្គាល់ការផ្ទេរត្រូវតែដូចគ្នា សម្រាប់ការផ្ទេរទៅក្នុងកម្រិតនានា ដូចជាការផ្ទេរចេញពីកម្រិតទាំងនោះ។ ឧទាហរណ៍ បណ្តាគោលនយោបាយសម្រាប់កំណត់ពេលវេលានៃការផ្ទេរ រួមមានដូចខាងក្រោមៈ

(ក) កាលបរិច្ឆេទ នៃព្រឹត្តិការណ៍ ឬការផ្លាស់ប្តូរកាលៈទេសៈ ដែល បណ្តាល ឱ្យមានការផ្ទេរ

(ខ) កាលបរិច្ឆេទដើមគ្រានៃការិយបរិច្ឆេទរាយការណ៍

(គ) កាលបរិច្ឆេទចុងគ្រានៃការិយបរិច្ឆេទរាយការណ៍

៩៦ ប្រសិនបើ អង្គភាពសម្រេចបង្កើតគោលនយោបាយគណនេយ្យ ដើម្បីប្រើការលើកលែងនៅក្នុងកថាខណ្ឌ ៤៨, អង្គភាពត្រូវលាតត្រដាងនូវហេតុ-ការណ៍នោះ។

៩៧ សម្រាប់ថ្នាក់និមួយៗនៃទ្រព្យសកម្មនិងបំណុលដែលមិនវាស់វែងតាមតម្លៃសមស្របក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ ប៉ុន្តែតម្លៃសមស្របត្រូវបានគេលាតត្រដាង, អង្គភាព ត្រូវលាតត្រដាងព័ត៌មាន ដែលតម្រូវដោយ កថាខណ្ឌ ៩៣(ខ), (ឃ) និង (ឈ)។ ទោះជាយ៉ាងណា អង្គភាពមិន តម្រូវឱ្យផ្តល់នូវការលាតត្រដាងជាលក្ខណៈបរិមាណវិស័យ អំពីធាតុចូល ដែលមិនអាចអង្កេតបានសំខាន់ៗ ដែលបានប្រើនៅក្នុងការវាស់តម្លៃសម ស្របក្នុងកម្រិតទី ៣ នៃឋានានុក្រមតម្លៃសមស្រប ដែលតម្រូវដោយកថាខណ្ឌ ៩៣ (ឃ)។ សម្រាប់ទ្រព្យសកម្ម និងបំណុល បែបនោះអង្គភាព មិនចាំបាច់ផ្តល់នូវការលាតត្រដាងផ្សេងទៀតដែលតម្រូវ ដោយស្តង់ដា របាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនេះឡើយ។

៩៨ សម្រាប់បំណុលដែលវាស់វែងតាមតម្លៃសមស្រប និងត្រូវបានបោះផ្សាយជាមួយនឹងការធ្វើឱ្យប្រសើរឡើងនៃឥណទានរបស់ភាគីទីបី ដែលមិនអាចផ្តាច់ចេញពីគ្នាបាន អ្នកបោះផ្សាយត្រូវលាតត្រដាងនូវការលេចឡើង នៃការធ្វើឱ្យប្រសើរឡើងនៃឥណទាននោះ និងថាតើ វាបានឆ្លុះបញ្ចាំងនៅក្នុងការវាស់វែងតម្លៃ សមស្របរបស់បំណុលដែរឬទេ។

៩៩ អង្គភាពត្រូវបង្ហាញការលាតត្រដាងជាលក្ខណៈបរិមាណវិស័យ ដែលបានតម្រូវដោយស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ នៅក្នុងទម្រង់ជាតារាង ដរាបណាទម្រង់ផ្សេងទៀតមានភាពសមស្រប។

## ឧបសម្ព័ន្ធ ក

## ពាក្យបានកំណត់អត្ថន័យ

*ឧបសម្ព័ន្ធនេះគឺជាផ្នែកមួយនៃស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ*

| | |
|---|---|
| **ទីផ្សារសកម្ម** | ជាទីផ្សារដែលប្រតិបត្តិការសម្រាប់ទ្រព្យសកម្មនិងបំណុលកើតឡើងដោយមានប្រេកង់និងទំហំគ្រប់គ្រាន់ ដើម្បីផ្តល់នូវព័ត៌មានអំពីការកំណត់ថ្លៃ ដោយឈរលើមូលដ្ឋាននិរន្តន៍។ |
| **វិធីសាស្ត្រថ្លៃដើម** | បច្ចេកទេសនៃការវាយតម្លៃដែលឆ្លុះបញ្ចាំងអំពីបរិមាណដែលនឹងទាមទារនាពេលបច្ចុប្បន្នដើម្បីជំនួស សមត្ថភាពសេវាកម្មរបស់ ទ្រព្យសកម្មមួយ (ជាធម្មតា សំដៅ តម្លៃដើមជំនួសបច្ចុប្បន្ន។ |
| **ថ្លៃឈានចូល** | ថ្លៃដែលបានបង់ ដើម្បីទទួលបានទ្រព្យសកម្ម ឬថ្លៃ ដែលបានទទួល ដើម្បីទទួលយកបំណុលនៅក្នុងប្រតិបត្តិការ នៃការដោះដូរមួយ។ |
| **ថ្លៃដកថយ** | ថ្លៃដែលនឹងទទួលបានដោយការលក់ទ្រព្យសកម្ម ឬថ្លៃដែលនឹងត្រូវបង់សម្រាប់ការផ្ទេរបំណុល។ |
| **លំហូរសាច់ប្រាក់មធ្យម** | បំណែងចែកមធ្យមភាគ តាម ប្រូបាប៊ីលីតេ នៃលំហូរសាច់ប្រាក់អនាគត។ |
| **តម្លៃសមស្រប** | ថ្លៃដែលនឹងទទួលបានពីការលក់ទ្រព្យសកម្ម ឬថ្លៃដែលត្រូវបង់ដោយសារការផ្ទេរបំណុលនៅក្នុងប្រតិបត្តិការជាប្រព័ន្ធកក្នុងចំណោមអ្នកចូលរួមនៅក្នុងទីផ្សារនាកាលបរិច្ឆេទនៃការវាស់វែង។ |

| | |
|---|---|
| **ការប្រើដោយល្អបំផុតនិងខ្ពស់បំផុត** | ការប្រើទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុដោយអ្នកចូលរួមទីផ្សារ ដែលនឹងធ្វើឱ្យបានជាអតិបរមានូវតម្លៃរបស់ទ្រព្យសកម្ម ឬក្រុម នៃ ទ្រព្យសកម្មនិងបំណុល(អាជីវកម្ម)ដែលនៅក្នុងនោះទ្រព្យសកម្មនឹងត្រូវបានគេប្រើ។ |
| **វិធីសាស្ត្រប្រាក់ចំណូល** | បច្ចេកទេស នៃការវាយតម្លៃដែលបំប្លែងតម្លៃអនាគត (លំហូរសាច់ប្រាក់ឬប្រាក់ចំណូល និងចំណាយ) ទៅជាតម្លៃបច្ចុប្បន្ន តែមួយគត់។ ការវាស់វែងតម្លៃសមស្របត្រូវបានកំណត់ ដោយឈរលើមូលដ្ឋាននៃតម្លៃ ដែលបានបង្ហាញដោយការរំពឹងរបស់ទីផ្សារបច្ចុប្បន្នអំពីតម្លៃអនាគតទាំងនោះ។ |
| **ធាតុចូល** | ការសន្មតដែលថា អ្នកចូលរួមទីផ្សារនឹងប្រើ នៅពេលកំនត់ថ្លៃទ្រព្យសកម្ម ឬបំណុល ដោយរួមមានការសន្មតអំពីហានិភ័យ ដូចខាងក្រោមៈ<br>(ក) ហានិភ័យ ដែលបង្កប់នៅក្នុងបច្ចេកទេស នៃការវាយតម្លៃដែលបានប្រើដើម្បីវាស់វែងតម្លៃសមស្រប (ដូចជា មូលឌែល នៃការកំនត់ថ្លៃ) និង<br>(ខ) ហានិភ័យដែលបង្កប់ នៅក្នុងធាតុចូល នៃបច្ចេកទេសវាយតម្លៃធាតុចូលរួមមាន ធាតុចូលអាចអង្កេតបាន និងធាតុចូល មិនអាចអង្កេតបាន។ |
| **ធាតុចូលកម្រិត១** | ថ្លៃសម្រង់ (មិនទាន់កែសម្រួល) នៅក្នុងទីផ្សារសកម្មសម្រាប់ទ្រព្យសកម្មដូចគ្នាឬបំណុលដូចគ្នា ដែលអង្គភាពអាចទទួលបាននាកាលបរិច្ឆេទនៃការវាយតម្លៃ។ |

**ធាតុចូលកម្រិត២** ធាតុចូលនានា ដែលមិនមែនជាថ្លៃសម្រង់ ដែលមាននៅក្នុងកម្រិត ១ ដែលអាចអង្កេតបានដោយផ្ទាល់ឬដោយប្រយោលសម្រាប់ទ្រព្យសកម្មនិងបំណុល។

**ធាតុចូលកម្រិត៣** ធាតុចូលមិនអាចអង្កេតបានសម្រាប់ទ្រព្យសកម្មឬ បំណុល។

**វិធីសាស្រ្តទីផ្សារ** បច្ចេកទេស នៃការវាយតម្លៃដែលប្រើថ្លៃ និងព័ត៌មានពាក់ព័ន្ធផ្សេងៗ ដែលបានបង្កើតឡើងដោយប្រតិបត្តិការ ទីផ្សារទាក់ទងនឹងទ្រព្យសកម្មដូចគ្នា ឬអាចប្រៀបធៀបបាន (មានន័យថា ស្រដៀងគ្នា), បំណុលដូចគ្នា ឬអាចប្រៀបធៀបបាន (មានន័យ ថា ស្រដៀងគ្នា) ឬក្រុមនៃទ្រព្យសកម្មនិងបំណុលដូចគ្នា ឬអាចប្រៀបធៀបបាន (មានន័យថា ស្រដៀងគ្នា), ឧទាហរណ៍ អាជីវកម្ម។

**ធាតុចូលដែលបានបញ្ជាក់ដោយទីផ្សារ** ធាតុចូលដែលបានមកពីឬបានបញ្ជាក់អះអាងដោយទិន្ន័យទីផ្សារដែលអាចអង្កេតបាន តាមរយៈមេគុណសហសម្ពន្ធ័ឬ ដោយមធ្យោបាយផ្សេងៗ។

**អ្នកចូលរួមទីផ្សារ** អ្នកទិញ និងអ្នកលក់នៅក្នុងទីផ្សារគោល (ឬ ទីផ្សារដែលមានអាទិភាពបំផុត) សម្រាប់ទ្រព្យសកម្ម ឬបំណុលដែលមានចរិតលក្ខណៈ ដូចខាងក្រោមៈ

(ក) ពួកគេមិនពាក់ពន្ធ័គ្នា មានន័យថា ពួកគេមិនមែនជាភាគីដែលពាក់ពន្ធ័គ្នា ដូចបានកំណត់ នៅក្នុងស្តង់ដាគណនេយ្យ អន្តរជាតិ ២៤, ទោះជាយ៉ាងណា ថ្លៃនៅក្នុងប្រតិបត្តិការពាក់ ពន្ធ័អាច

ត្រូវបានប្រើធ្វើ ជាធាតុចូល នៅក្នុងការវាស់វែងតម្លៃ សមស្រប ប្រសិនបើ អង្គភាព មានភស្តុតាងគ្រប់គ្រាន់ដែល បញ្ជាក់ថា ប្រតិបត្តិការបានកើតឡើងតាមលក្ខខណ្ឌទីផ្សារ។

(ខ) ពួកគេមានចំណេះដឹងការយល់ ដោយសមហេតុផល អំពីទ្រព្យសកម្មឬបំណុល ហើយប្រតិបត្តិការនោះប្រើគ្រប់ព័ត៌មានដែលមាន រួមមានទាំងព័ត៌មាន ដែលអាចទទួលបានតាមរយៈការសិក្សាយ៉ាងល្អិតល្អន់ដែលមានជាប្រក្រតីនិងតាមទម្លាប់។

(គ) ពួកគេមានលទ្ធភាពចូលរួមនៅក្នុងប្រតិបត្តិការនៃទ្រព្យសកម្មនិងបំណុលនោះ។

(ឃ) ពួកគេមានឆន្ទៈចូលរួមនៅក្នុងប្រតិបត្តិការនៃទ្រព្យសកម្មឬបំណុល មានន័យថា ពួកគេត្រូវបានជម្រុញទឹកចិត្ត ប៉ុន្តែមិនត្រូវបានបង្ខំ ឬបង្គាប់ឱ្យធ្វើដូច្នោះឡើយ។

| | |
|---|---|
| **ទីផ្សារដែលមានអាទិភាពបំផុត** | ទីផ្សារដែលធ្វើឱ្យជាអតិបរមានូវបរិមាណដែលនឹងទទួលបានពីការលក់ទ្រព្យសកម្ម ឬធ្វើឱ្យជាអប្បរមានូវបរិមាណ ដែលនឹងត្រូវបង់សងដែលកើតឡើង ដោយការផ្ទេរបំណុល បន្ទាប់ពីដកចេញនូវចំណាយប្រតិបត្តិការនិងចំណាយដឹកជញ្ជូន។ |
| **ហានិភ័យ ដែលកើតឡើងដោយការមិនអនុវត្តតាម** | ហានិភ័យដែលអង្គភាពនឹងមិនត្រូវអនុវត្តនូវកាតព្វកិច្ច។ហានិភ័យដែលកើតឡើងដោយការមិនអនុវត្តតាម រួមមាន ប៉ុន្តែមិនកំណត់ត្រឹម ហានិភ័យឥណទានផ្ទាល់ខ្លួនរបស់អង្គភាព។ |
| **ធាតុចូលអាចអង្កេតបាន** | ធាតុចូលដែលបានបង្កើតឡើងដោយប្រើទិន្នន័យទីផ្សារ ដូចជាព័ត៌មានដែលមានជាសាធារណៈអំពីព្រឹត្តិការណ៍ ឬប្រតិបត្តិការ |

ជាក់ស្តែង, ហើយដែលឆ្លុះបញ្ចាំងការសន្មតនានា ដែលអ្នកចូលរួមទីផ្សារនឹងប្រើនៅពេលកំណត់ថ្លៃ ទ្រព្យសកម្មនិងបំណុល។

**ប្រតិបត្តិការប្រព័ន្ធិក** ប្រតិបត្តិការ ដែលសន្មតថា ការប្រឈមទៅនឹងទីផ្សារសម្រាប់រយៈពេលមួយ មុនពេលដែលកាលបរិច្ឆេទ នៃការវាស់វែងអនុញ្ញាតិសម្រាប់សកម្មភាពម៉ាឃីតទីងដែលមានជាប្រក្រតីនិងជាទម្លាប់ សម្រាប់ប្រតិបត្តិការនានាពាក់ពន្ធ័នឹងទ្រព្យសកម្ម ឬបំណុល, វាមិនមែនជាប្រតិបត្តិការបង្ខំ (ឧ. ការប្រកាសក្ស័យធនដោយបង្ខំ ឬការលក់ចេញដោយបង្ខំ)។

**ទីផ្សារគោល** ទីផ្សារដែលមានទំហំ និងកម្រិតសកម្មភាពខ្លាំង សម្រាប់ទ្រព្យសកម្មនិងបំណុល។

**កម្រៃធានាហានិភ័យ** កម្រៃតបសងដែលអ្នកចូលរួមទីផ្សារប្រភេទមិនស្វែងរកហានិភ័យបានស្វែងរក សម្រាប់ការទទួលយកនូវភាពមិនប្រាកដប្រជាដែលមាននៅក្នុងលំហូរសាច់ប្រាក់របស់ទ្រព្យសកម្មនិងបំណុល។

**ចំណាយប្រតិបត្តិការ** ចំណាយពាក់ពន្ធ័នឹងការលក់ ឬការផ្ទេរបំណុល នៅក្នុងទីផ្សារគោល (ឬទីផ្សារដែលមានអាទិភាពបំផុត) សម្រាប់ទ្រព្យសកម្ម ឬបំណុលដែលដែលមានការពាក់ពន្ធ័ដោយផ្ទាល់ទៅនឹងការលក់ទ្រព្យសកម្មឬការផ្ទេរ និងបំពេញបានលក្ខណៈវិនិច្ឆ័យទាំងពីរដូចខាងក្រោមៈ

(ក) ចំណាយដែលកើតចេញ ដោយផ្ទាល់ពី ឬដែលមានសារៈសំខាន់ចំពោះប្រតិបត្តិការ

(ខ) ចំណាយដែលមិនបានកើតឡើងដោយអង្គភាពដែលបានធ្វើការសម្រេចចិត្តលក់ទ្រព្យសកម្ម ឬការផ្ទេរបំណុល ដែលមិនបានធ្វើឡើង (ស្រដៀងគ្នាទៅនឹងចំណាយលើការលក់ ដូចបានកំណត់ នៅក្នុងស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរ-ជាតិ៥)

| | |
|---|---|
| **ចំណាយដឹកជញ្ជូន** | ចំណាយ ដែលកើតនឹងឡើង ចំពោះការដឹកជញ្ជូនទ្រព្យសកម្ម ពីទីតាំងបច្ចុប្បន្នទៅទីផ្សារគោល (ឬ ទីផ្សារដែលមានអាទិភាពបំផុត)។ |
| **ចំណែកនៃគណនី** | ជាកម្រិតដែលទ្រព្យសកម្ម ឬបំណុលត្រូវបានរួមបញ្ចូលគ្នា ឬត្រូវបានបំបែកចេញពីគ្នា នៅក្នុងស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ សម្រាប់គោលបំនងនៃការទទួលស្គាល់។ |
| **ធាតុចូលមិនអាចអង្កេតបាន** | ជាធាតុចូលដែលទិន្នន័យទីផ្សារមិនអាចរកបាន ហើយដែលត្រូវបានបង្កើតឡើងដោយប្រើព័ត៌មានដ៏ល្អបំផុត ដែលមានស្តីពី ការសន្មតដែលអ្នកចូលរួមទីផ្សារនឹងប្រើនៅពេលកំណត់ថ្លៃលក់របស់ទ្រព្យសកម្មឬបំណុល។ |

## ឧបសម្ព័ន្ធ ខ

## សេចក្តីណែនាំអនុវត្ត

*ឧបសម្ព័ន្ធនេះគឺជាផ្នែកមួយនៃស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ។វាបរិយាយអំពីការអនុវត្ត កថាខណ្ឌ ១-៩៩ និងមានសិទ្ធិអំណាចដូចគ្នានឹងផ្នែកផ្សេងទៀត នៃស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ។*

B១ ការវិនិច្ឆ័យ ដែលបានប្រើនៅក្នុងស្ថានភាពនៃការវាយតម្លៃផ្សេងៗគ្នា អាចមានភាពខុសគ្នា។ ឧបសម្ព័ន្ធនេះបរិយាយនូវការវិនិច្ឆ័យដែលអាចអនុវត្តបាននៅពេល ដែល អង្គភាពមួយវាស់វែងតម្លៃសមស្រប នៅក្នុងស្ថានភាពនៃការវាយតម្លៃផ្សេងៗគ្នា។

### វិធីសាស្ត្រនៃការវាយវាស់វែងតម្លៃសមស្រប

B២ កម្មវត្ថុនៃការវាស់វែងតម្លៃសមស្រប គឺត្រូវប៉ាន់ស្មានថ្លៃ ដែលប្រតិបត្តិការប្រព័ន្ធមួយដើម្បីលក់ទ្រព្យសកម្ម ឬដើម្បីផ្ទេរបំណុលនឹងកើតឡើង រវាងអ្នកចូលរួមទីផ្សារនាកាលបរិច្ឆេទនៃការវាស់វែងនៅក្រោម លក្ខខណ្ឌទីផ្សារបច្ចុប្បន្ន។ការវាស់វែងតម្លៃសមស្របតម្រូវឱ្យអង្គភាពកំណត់នៅប្រការទាំងអស់ខាងក្រោមៈ

(ក) ទ្រព្យសកម្ម ឬបំណុល ដែលជាប្រធានបទនៃការវាស់វែង (ដោយមានសង្គតិភាពជាមួយចំណែកនៃគណនី)។

(ខ) សម្រាប់ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ, ផលដំបូងនៃការវាយតម្លៃដែលមានភាពសមស្របសម្រាប់ការវាស់វែង(ដោយមានសង្គតិភាពជាមួយនឹងការប្រើប្រាស់ខ្ពស់បំផុតនិងល្អបំផុត)។

(គ) ទីផ្សារគោល (ឬ ទីផ្សារមានអាទិភាពបំផុត) សម្រាប់ទ្រព្យសកម្ម ឬ បំណុល។

(ឃ) បច្ចេកទេសវាយតម្លៃ ដែលសមស្របសម្រាប់ការវាស់វែង ដោយពិចារណាអំពីភាពអាចរកបាននៃទិន្នន័យ ដែលត្រូវបានបង្កើតឡើងនូវធាតុចូលដែលតំណាង នូវការសន្មតដែលថា អ្នកចូលរួមទីផ្សារនឹងប្រើ នៅពេលធ្វើការកំណត់ថ្លៃទ្រព្យសកម្ម ឬបំណុល និងកម្រិតនៃឋានានុក្រមតម្លៃសមស្របដែលនៅក្នុងនោះធាតុចូល ត្រូវបានចាត់ជាផ្នែកៗ។

## ផលដំបូងនៃការវាយតម្លៃសម្រាប់ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ (កថាខណ្ឌ ៣១-៣៣)

៣៣ នៅពេលវាស់វែងតម្លៃសមស្របរបស់ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ ដែលបានប្រើនៅក្នុងការគួបផ្សំជាមួយទ្រព្យសកម្មផ្សេងទៀតឱ្យទៅជាក្រុម (ដូចបានដំឡើង ឬកំណត់ទុកសម្រាប់ការប្រើប្រាស់) ឬជាការគួបផ្សំជាមួយទ្រព្យសកម្មនិងបំណុល (ឧ.អង្គភាពអាជីវកម្ម) នូវផលប៉ះពាល់ នៃផលដំបូងនៃការវាយតម្លៃអាស្រ័យតាមកាលៈទេសៈ។ ឧទាហរណ៍ៈ

(ក) តម្លៃសមស្របរបស់ទ្រព្យសកម្មអាចដូចគ្នាបើទោះបីជាទ្រព្យសកម្មត្រូវបានប្រើដោយឈរលើមូលដ្ឋានតែឯកឯង ឬនៅក្នុងការគួបផ្សំជាមួយទ្រព្យសកម្មផ្សេងៗឬជាមួយទ្រព្យសកម្មនិងបំណុលផ្សេងៗ។ វាអាចជាករណីថា ប្រសិនបើទ្រព្យសកម្ម គឺជាអង្គភាពអាជីវកម្មដែលអ្នកចូលរួមទីផ្សារ នឹងបន្តប្រតិបត្តិការ។ នៅក្នុងករណីនោះប្រតិបត្តិការ នឹងពាក់ពន្ធ័ការវាយតម្លៃអង្គភាពអាជីវកម្មទាំងមូល។ ការប្រើទ្រព្យសកម្មជាក្រុមនៅក្នុងអង្គភាពអាជីវកម្មកំពុងដំណើរការ

នឹងបង្កើតបានសហថាមពលដែលនឹងអាចរកបាន ដោយអ្នកចូលរួមទីផ្សារ (មានន័យថា សហថាមពលរបស់អ្នកចូលរួម ដែលហេតុដូច្នេះ នឹងមានផលប៉ះពាល់ដល់តម្លៃសមស្របរបស់ ទ្រព្យសកម្មដោយផ្អែកលើមូលដ្ឋានតែឯកឯង ឬការគួបផ្សំជាមួយនឹង ទ្រព្យសកម្មផ្សេងទៀត ឬជាមួយនឹងទ្រព្យសកម្ម និងបំណុលផ្សេងៗទៀត) ។

(ខ) ការប្រើទ្រព្យសកម្មមួយ ដោយគួបផ្សំជាមួយនឹង ទ្រព្យសកម្មផ្សេងទៀត ឬជាមួយនឹងទ្រព្យសកម្មនិងបំណុលផ្សេងៗទៀត អាចត្រូវបានដាក់បញ្ចូលទៅក្នុងការវាស់វែងតម្លៃសមស្របតាមរយៈការកែសម្រួលជាមួយនឹងតម្លៃរបស់ទ្រព្យសកម្ម ដែលបានប្រើដោយឈរលើមូលដ្ឋានតែឯកឯង។នោះអាចជាករណី ដែលទ្រព្យសកម្ម គឺជាគ្រឿងម៉ាស៊ីន ហើយការវាស់វែងតម្លៃសមស្រប ត្រូវបានកំណត់ដោយប្រើថ្លៃដែលបានអង្កេតសម្រាប់គ្រឿងម៉ាស៊ីន ដែលស្រដៀងគ្នា (មិនត្រូវបានដំឡើងឬកំណត់ទុកសម្រាប់ការប្រើ) ត្រូវបានកែសម្រួលសម្រាប់ចំណាយដឹកជញ្ជូននិងចំណាយថ្លៃដំឡើង ដើម្បីឱ្យការវាស់វែងតម្លៃសមស្របឆ្លុះបញ្ចាំងលក្ខខណ្ឌបច្ចុប្បន្ន និងទីតាំងរបស់គ្រឿងម៉ាស៊ីន (បានដំឡើងនិងកំណត់ទុកសម្រាប់ប្រើ)។

(គ) ការប្រើទ្រព្យសកម្មមួយ ដោយគួបផ្សំជាមួយនឹងទ្រព្យសកម្មផ្សេងទៀត ឬជាមួយនឹងទ្រព្យសកម្ម និងបំណុលផ្សេងៗទៀត អាចត្រូវបានដាក់បញ្ចូល ទៅក្នុងការវាស់វែងតម្លៃសមស្រប តាមរយៈការសន្មតដែលបានប្រើរបស់អ្នកចូលរួមទីផ្សារ ដើម្បីវាស់វែងតម្លៃ សមស្របរបស់ទ្រព្យសកម្ម។ ឧទាហរណ៍ ប្រសិនបើ ទ្រព្យសកម្ម គឺជាស

ន្និធិស្ថិតនៅក្នុងការផលិត ដែលមានលក្ខណៈឯក ហើយអ្នក ចូលរួមទីផ្សារនឹងបំប្លែងសន្និធិនិនោះ ឱ្យទៅជាផលិតផលសម្រេច តម្លៃសមស្របរបស់សន្និធិនឹងត្រូវសន្មតថា អ្នកចូលរួម ទីផ្សារបានទទួលយកនូវម៉ាស៊ីនដែលមានលក្ខណៈពិសេសដែលចាំបាច់ ដើម្បីបំប្លែងសន្និធិឱ្យទៅជាផលិតផលសម្រេច។

(ឃ) ការប្រើទ្រព្យសកម្មមួយ ដោយគួបផ្សំជាមួយនឹងទ្រព្យសកម្មផ្សេងទៀត ឬជាមួយនឹងទ្រព្យសកម្មនិងបំណុលផ្សេងៗទៀត អាចត្រូវបានដាក់បញ្ចូលទៅក្នុងបច្ចេកទេសនៃការវាស់វែងតម្លៃ ដែលបានប្រើ ដើម្បីវាស់វែងតម្លៃសមស្របរបស់ទ្រព្យសកម្ម។ នោះអាចជាករណី នៅពេលដែលប្រើវិធីសាស្ត្រ ប្រាក់ចំណេញអតិរេក ពីការិយបរិច្ឆេទច្រើនដំណាក់កាល ដើម្បីវាស់វែងតម្លៃសមស្របរបស់ទ្រព្យសកម្មអរូបី ពីព្រោះថាបច្ចេកទេសវាយតម្លៃបានដាក់បញ្ចូលដោយជាក់លាក់នូវចំណែក នៃការចូលរួមរបស់ទ្រព្យសកម្មបំពេញបន្ថែមណាមួយនិងបំណុលដែលពាក់ពន្ធ័នៅក្នុងក្រុម ដែលនៅក្នុងនោះទ្រព្យសកម្មអរូបីនឹងត្រូវបានគេប្រើ។

(ង) នៅក្នុងស្ថានភាព ដែលមានកំណត់ នៅពេលដែលអង្គភាព ប្រើទ្រព្យសកម្ម ដែលស្ថិតនៅក្នុងក្រុមនៃទ្រព្យសកម្ម អង្គភាពអាចវាស់វែងទ្រព្យសកម្មនោះតាមបរិមាណដែលប្រហាក់ប្រហែលតម្លៃសមស្របរបស់វា នៅពេលបែងចែកតម្លៃសមស្របរបស់ក្រុម នៃទ្រព្យសកម្មទៅឱ្យទ្រព្យសកម្មនីមួយៗរបស់ក្រុមនោះ។ នោះអាចជាករណី ប្រសិនបើ ការវាយតម្លៃទាក់ទងនឹងអចលនទ្រព្យពិត ហើយតម្លៃសមស្របរបស់អចលនទ្រព្យនោះ (មានន័យថាក្រុមទ្រព្យ

សកម្ម) ត្រូវបានបែងចែកទៅទ្រព្យសកម្ម ជាសមាសធាតុរបស់វា (ដូចជា ដីធ្លីនិងបសិដ្ឋកម្ម)។

## តម្លៃសមស្របនៅពេលនៃការទទួលស្គាល់ដំបូង (កថាខណ្ឌ ៥៧ -៦០)

៦៤ នៅពេលកំណត់ថាតើតម្លៃសមស្រប នាពេលនៃការទទួលស្គាល់ដំបូងស្មើនឹងថ្លៃប្រតិបត្តិការ អង្គភាពត្រូវរាប់បញ្ចូលនូវកត្តាជាក់លាក់នានា ទៅក្នុងប្រតិបត្តិការនិងទៅក្នុងទ្រព្យសកម្មនិងបំណុល។ឧទាហរណ៍ថ្លៃប្រតិបត្តិការអាចមិនតំណាងឱ្យតម្លៃសមស្របរបស់ទ្រព្យសកម្ម និងបំណុល នៅពេលនៃការទទួលស្គាល់ដំបូង ប្រសិនបើ លក្ខខណ្ឌណាមួយខាងក្រោមកើត ឡើង:

(ក) ប្រតិបត្តិការដែលកើតឡើងរវាងភាគីដែលពាក់ពន្ធ័ បើទោះបីជា ថ្លៃនៅក្នុងប្រតិបត្តិការរបស់ភាគី ដែលពាក់ពន្ធ័អាចត្រូវបានប្រើជា ធាតុចូលនៅក្នុងការវាស់វែងតម្លៃសមស្រប ប្រសិនបើ អង្គភាពមានភស្តុតាងថា ប្រតិបត្តិការត្រូវបានបញ្ចូលទៅតាមលក្ខខណ្ឌទីផ្សារ។

(ខ) ប្រតិបត្តិការកើតឡើងនៅក្រោមការបង្ខិតបង្ខំ ឬអ្នកលក់ត្រូវបានបង្ខំឱ្យទទួលយកនូវថ្លៃនៅក្នុងប្រតិបត្តិការ។ ឧទាហរណ៍ នោះអាចជាករណីដែលអ្នកលក់ជួបប្រទះការលំបាកផ្នែកហិរញ្ញវត្ថុ។

(គ) ចំណែកនៃគណនី ដែលតំណាង ដោយថ្លៃប្រតិបត្តិការខុសគ្នាពីចំណែកគណនីសម្រាប់ទ្រព្យសកម្ម ឬបំណុលដែលវាស់វែង តាមតម្លៃសមស្រប។ ឧទាហរណ៍ នោះអាចជាករណីដែលទ្រព្យសកម្ម ឬបំណុលដែលវាស់វែង តាមតម្លៃសមស្រប គឺជាសមាសធាតុតែមួយគត់នៅក្នុងប្រតិបត្តិការ(ឧ.ការរួមបញ្ចូលអាជីវកម្ម),ប្រតិបត្តិការ

រួមមានសិទ្ធិនិងបុព្វសិទ្ធិដែលមិនបានចែង ដែលត្រូវបានវាស់វែងដាច់ដោយឡែកដោយអនុលោមតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិផ្សេងៗទៀត ឬថ្លៃប្រតិបត្តិការដែលរួមមាននៅក្នុងចំណាយប្រតិបត្តិការ។

(ឃ) ទីផ្សារដែលប្រតិបត្តិការកើតឡើងខុសគ្នាពីទីផ្សារគោល (ឬទីផ្សារដែលមានអាទិភាពបំផុត)។ ឧទាហរណ៍ ទីផ្សារទាំងនោះអាចខុសគ្នាប្រសិនបើអង្គភាពគឺជាឈ្មួញកណ្តាល ដែលមានប្រតិបត្តិការជាមួយអតិថិជននៅក្នុងទីផ្សារលក់រាយ ប៉ុន្តែមានប្រតិបត្តិការនៅក្នុងទីផ្សារគោល (ឬទីផ្សារដែលមានអាទិភាពបំផុត) សម្រាប់ប្រតិបត្តិការដកថយជាមួយនឹង ឈ្មួញកណ្តាលផ្សេងទៀត នៅក្នុងទីផ្សារឈ្មួញកណ្តាល។

## បច្ចេកទេសនៃការវាយតម្លៃ (កថាខណ្ឌ៦១-៦៦)

### វិធីសាស្ត្រទីផ្សារ

ខ៥ វិធីសាស្ត្រទីផ្សារប្រើថ្លៃនិងព័ត៌មានពាក់ព័ន្ធផ្សេងៗ ដែលបានបង្កើតឡើងដោយប្រតិបត្តិការទីផ្សារទាក់ទងនឹងទ្រព្យសកម្ម បំណុល ឬក្រុមនៃទ្រព្យសកម្ម និងបំណុលដូចគ្នា ឬអាចប្រៀបធៀបបាន (មានន័យថា ស្រដៀងគ្នា) ដូចជា អង្គភាពអាជីវកម្ម។

ខ៦ ឧទាហរណ៍ បច្ចេកទេសនៃការវាយតម្លៃ ដែលមានសង្គតិភាពជាមួយនឹងវិធីសាស្ត្រទីផ្សារតែងតែប្រើពហុគុណទីផ្សារ ដែលបានមកពីសំណុំ អាចប្រៀបធៀបបាន។ ពហុគុណអាចស្ថិតនៅក្នុងលំដាប់ជាពហុគុណផ្សេងៗគ្នា សម្រាប់ការអាចប្រៀបធៀបបាននិមួយៗ។ ការជ្រើសរើសពហុគុណ

សមរម្យនៅក្នុងលំដាប់ទាមទារនូវការវិនិច្ឆ័យ ពិចារណាកត្តាជាគុណវិស័យ និងបរិមាណវិស័យជាក់លាក់ទាក់ទងនឹងការវាស់វែង។

១៧ បច្ចេកទេសនៃការវាយតម្លៃមានសង្គតិភាពជាមួយវិធីសាស្រ្តទីផ្សារ រួមមានការកំណត់ថ្លៃជាម៉ាទ្រីស។ ការកំណត់ថ្លៃជាម៉ាទ្រីស គឺជាវិធីសាស្រ្តគណិតវិទ្យាដែលបានប្រើជាសំខាន់ ដើម្បីវាយតម្លៃឧបករណ៍ហិរញ្ញវត្ថុមួយចំនួនដូចជា មូលបត្របំណុល ដោយមិនចាំបាច់ពឹងផ្អែកទាំងស្រុងលើថ្លៃសម្រង់សម្រាប់មូលបត្រជាក់លាក់ ប៉ុន្តែជាជាងពឹងផ្អែកលើ ទំនាក់ទំនងរបស់ មូលបត្រទៅនឹងមូលបត្របានសម្រង់ជាគំរូផ្សេងទៀត។

## វិធីសាស្រ្តចំណាយថ្លៃដើម

១៨ វិធីសាស្រ្តចំណាយថ្លៃដើមឆ្លុះបញ្ចាំងបរិមាណ ដែលនឹងត្រូវបានតម្រូវឱ្យផ្លាស់ប្តូរនូវសមត្ថភាពសេវាកម្មរបស់ទ្រព្យសកម្ម (ជាធម្មតា សំដៅដល់ ថ្លៃដើមជំនួសបច្ចុប្បន្ន)។

១៩ ពីទស្សនទានរបស់អ្នកលក់ដែលជាអ្នកចូលរួមនៅក្នុងទីផ្សារ ថ្លៃដែលនឹងត្រូវបានទទួលសម្រាប់ទ្រព្យសកម្ម ត្រូវបានផ្អែកលើចំណាយ ចំពោះអ្នកទិញ ដែលជាអ្នកចូលរួមនៅក្នុងទីផ្សារ ដើម្បីទទួលបាន ឬបង្កើតនូវ ទ្រព្យសកម្មជំនួសរបស់សេវាអាចប្រៀបធៀបបាន ដែលបានកែសម្រួលសម្រាប់ភាពហួសសម័យ។ នោះគឺពីព្រោះអ្នកទិញ ដែលជាអ្នកចូលរួម នៅក្នុងទីផ្សារ នឹងមិនចំណាយលើទ្រព្យសកម្មមួយ ច្រើនជាងបរិមាណ ដែលខ្លួនអាចជំនួសសមត្ថភាពសេវាកម្មរបស់ទ្រព្យសកម្មនោះ។ភាពហួសសម័យរួមមានការខូចខាតផ្នែករូបរាង ភាពហួសសម័យខាងមុខងារ (ផ្នែកបច្ចេកវិទ្យា) និងភាពហួសសម័យខាងសេដ្ឋកិច្ច (ផ្នែកខាងក្រៅ) ហើយ

មានទំហំធំជាងការដករំលស់សម្រាប់គោលបំណងនៃការរាយការណ៍ហិរញ្ញវត្ថុ (វិភាជន៍នៃថ្លៃដើមដំបង) ឬសម្រាប់គោលបំណងពន្ធដារ(ដោយ ប្រើរយៈពេលនៃការផ្ដល់សេវាកម្មជាក់លាក់)។ នៅក្នុងករណីជាច្រើនវិធី សាស្ត្រថ្លៃដើមជំនួសបច្ចុប្បន្នត្រូវបានគេប្រើ ដើម្បីវាស់វែងតម្លៃសមស្របរបស់ទ្រព្យសកម្មរូបីយដែលបានប្រើនៅក្នុងការគួបផ្សំជាមួយនឹងទ្រព្យសកម្មផ្សេងទៀត ឬជាមួយនឹងទ្រព្យសកម្មនិងបំណុលផ្សេងទៀត។

## វិធីសាស្ត្រប្រាក់ចំណេញ

៦១០ វិធីសាស្ត្រប្រាក់ចំណេញបំប្លែងបរិមាណអនាគត (ឧ.លំហូរសាច់ប្រាក់ ឬចំណូល និងចំណាយ) ទៅជាបរិមាណបច្ចុប្បន្នតែមួយ (បរិមាណបានបន្ថយតម្លៃ)។ នៅពេលវិធីសាស្ត្រប្រាក់ចំណេញត្រូវបានប្រើ ការវាស់វែងតម្លៃសមស្របឆ្លុះបញ្ចាំង ការរំពឹងរបស់ទីផ្សារអំពី បរិមាណអនាគតទាំងនោះ។

៦១១ បច្ចេកទេសនៃការវាយតម្លៃទាំងនោះរួមមានជាឧទាហរណ៍ដូចខាងក្រោមៈ

(ក) បច្ចេកទេសតម្លៃបច្ចុប្បន្ន (មើល កថាខណ្ឌ ១១២-១៣០),

(ខ) ម៉ូលឌែលនៃការកំណត់ថ្លៃលក់ជម្រើស ដូចជារូបមន្តរបស់ **Black-Scholes-Merton** ឬវិធីសាស្ត្រ ប៊ីណូម៉ាយ(binomial model)(មានន័យថា វិធីសាស្ត្រប្រទើស -lattice model) ដែលរួមបញ្ចូល ទៅក្នុងបច្ចេកទេសតម្លៃបច្ចុប្បន្ន ហើយឆ្លុះបញ្ចាំងទាំង តម្លៃពេល វេលា និងតម្លៃមជ្ឈន្តិកៈរបស់ជម្រើស និង

(គ) វិធីសាស្ត្រប្រាក់ចំណេញអតិរេកច្រើនដំណាក់កាល ដែលត្រូវបានប្រើ ដើម្បីវាស់វែងតម្លៃសមស្រប របស់ទ្រព្យសកម្មអរូបីយមួយ ចំនួន។

## បច្ចេកទេសតម្លៃបច្ចុប្បន្ន

១១២ កថាខណ្ឌ ១១៣-១៣០ បរិយាយអំពីការប្រើបច្ចេកទេស តម្លៃបច្ចុប្បន្នសម្រាប់វាស់វែងតម្លៃសមស្រប។ កថាខណ្ឌទាំងនោះផ្តោតលើបច្ចេកទេសនៃការកែសម្រួលអត្រាអប្បហា និងបច្ចេកទេសលំហូរសាច់ប្រាក់អនាគត (តម្លៃបច្ចុប្បន្នរំពឹងបាន)។ កថាខណ្ឌទាំងនោះ មិនបរិយាយការប្រើប្រាស់បច្ចេកទេសតម្លៃបច្ចុប្បន្នជាក់លាក់តែមួយឬមិនកម្រិតអំពីការប្រើបច្ចេកទេសតម្លៃបច្ចុប្បន្នដើម្បីវាស់វែងតម្លៃសមស្របទៅនឹងវិធីសាស្ត្រនានា ដែលបានពិភាក្សា។បច្ចេកទេសតម្លៃបច្ចុប្បន្ន ដែលបានប្រើដើម្បីវាស់វែងតម្លៃសមស្របនឹងអាស្រ័យលើហេតុការណ៍និងកាលៈទេសៈជាក់លាក់ចំពោះទ្រព្យសកម្មឬបំណុលដែលកំពុងត្រូវបានវាស់វែង (ឧ.តើថ្លៃនៃទ្រព្យសកម្ម ឬបំណុលដែលអាប្រៀបធៀបបាន អាចត្រូវបានអង្កេត នៅក្នុងទីផ្សារ ឬយ៉ាងណា) និងភាពអាចរកបានទិន្នន័យគ្រប់គ្រាន់។

## សមាសធាតុនៃការវាស់វែងតម្លៃបច្ចុប្បន្ន

១១៣ តម្លៃបច្ចុប្បន្ន (មានន័យថា ការអនុវត្តន៍វិធីសាស្ត្រប្រាក់ចំណេញ) គឺជាឧបករណ៍ដែលបានប្រើដើម្បីតភ្ជាប់បរិមាណអនាគត (ឧ. តម្លៃ ឬលំហូរសាច់ប្រាក់)ទៅបរិមាណបច្ចុប្បន្នដោយប្រើអត្រាអប្បហារ។ ការវាស់វែងតម្លៃសមស្របរបស់ទ្រព្យសកម្ម ឬបំណុល ដោយប្រើបច្ចេកទេសតម្លៃបច្ចុប្បន្នចាប់យកបាននូវ សមាសធាតុទាំងអស់ដូចខាងក្រោមដោយឈរលើទស្សនៈរបស់អ្នកចូលរួមទីផ្សារនាកាលបរិច្ឆេទនៃការវាស់វែង÷

(ក) ការប៉ាន់ស្មានលំហូរសាច់ប្រាក់អនាគតរបស់ទ្រព្យសកម្ម ឬបំណុលដែលកំពុងត្រូវបានវាស់វែង។

(ខ) ការរំពឹងទុកអំពីបរបណាមធម៍ដែលអាចកើតមាននៅក្នុងបរិមាណ និង ការកំណត់ពេលវេលារបស់លំហូរសាច់ប្រាក់ដែលតំណាង នូវភាព មិនប្រាកដប្រជានៅក្នុងលំហូរសាច់ប្រាក់។

(គ) តម្លៃពេលវេលានៃទឹកប្រាក់ ដែលត្រូវបានតំណាង ដោយអត្រាលើទ្រព្យសកម្មមានតម្លៃជាទឹកប្រាក់គ្មានហានិភ័យដែលមានកាលបរិច្ឆេទ ឬរយៈពេលត្រូវគ្នា ជាមួយនឹងការិយបរិច្ឆេទដែលគ្របដណ្តប់ដោយលំហូរសាច់ប្រាក់ និងមិនមានភាពមិនប្រាកដប្រជា នៅក្នុងការកំណត់ពេលវេលា ឬមិនមានហានិភ័យនៃការខកខាន មិនបានសងទៅឱ្យអ្នកកាន់កាប់ (មានន័យថា អត្រាការប្រាក់និរភ័យ)

(ឃ) ថ្លៃសម្រាប់ការទទួលយកភាពមិនប្រាដកប្រជា ដែលបង្កប់នៅក្នុងលំហូរសាច់ប្រាក់ (តម្លៃអតិប្រមាណនៃហានិភ័យ)។

(ង) កត្តាផ្សេងៗ ដែលអ្នកចូលរួមទីផ្សារនឹងពិចារណា ទៅតាមកាលៈ ទេសៈ។

(ច) សម្រាប់បំណុល, ហានិភ័យ មិនទាក់ទងនឹងលទ្ធផលទាក់ទងនឹងបំណុលនោះ រួមមានហានិភ័យឥណទានផ្ទាល់របស់អង្គភាព (មានន័យថាជារបស់អ្នកមានកាតព្វកិច្ច)។

*គោលការណ៍ទូទៅ*

១១៤ បណ្តាបច្ចេកទេសតម្លៃបច្ចុប្បន្ន មានភាពខុសៗគ្នា នៅក្នុងរបៀប នៃការចាប់យកសមាសធាតុនៅក្នុងកថាខណ្ឌ ១៣។ ទោះជាយ៉ាងណា បណ្តាគោលការណ៍ទាំងអស់ខាងក្រោមគ្រប់គ្រងការអនុវត្តន៍បច្ចេកទេសនៃតម្លៃបច្ចុប្បន្នដែលបានប្រើសម្រាប់វាស់វែងតម្លៃសមស្របៈ

(ក) លំហូរសាច់ប្រាក់ និងអត្រាអប្បហារ គួរតែឆ្លុះបញ្ចាំងនូវការសន្មតនានាដែលអ្នកចូលរួមទីផ្សារនឹងប្រើនៅពេលកំណត់ថ្លៃទ្រព្យសកម្ម និងបំណុល។

(ខ) លំហូរសាច់ប្រាក់និងអត្រាអប្បហារគួរតែរាប់បញ្ចូលតែកត្តា ដែលទាក់ទងនឹងទ្រព្យសកម្មឬបំណុលដែលនឹងត្រូវវាស់វែងប៉ុណ្ណោះ។

(គ) ដើម្បីជៀសវាង ឬបំបាត់ចោលផលប៉ះពាល់ នៃកត្តាហានិភ័យអត្រាអប្បហារគួរតែឆ្លុះបញ្ចាំងការសន្មតនានា ដែលមានសង្គតិភាពជាមួយកត្តាហានិភ័យដែលមាននៅក្នុងលំហូរសាច់ប្រាក់។ឧទាហរណ៍ អត្រាអប្បហារដែលឆ្លុះបញ្ចាំងភាពមិនប្រាកដប្រជានៅក្នុងការរំពឹងទុកអំពីការខកខានមិនបានសងនាពេលអនាគតមានភាពសមស្រប ប្រសិនបើ មានការប្រើលំហូរសាច់ប្រាក់តាមកិច្ចសន្យារបស់ប្រាក់

កម្មី (មានន័យថា បច្ចេកទេសកែសម្រួលអត្រាអប្បហារ)។ អត្រាដូចគ្នា នោះមិនគួរត្រូវបានប្រើឡើយ ប្រសិនបើ មានការប្រើលំហូរសាច់ប្រាក់ (មានន័យថា ប្រូបាប៊ីលីតេមធ្យមទម្ងន់) ជាមធ្យម (មានន័យថា បច្ចេកទេសតម្លៃបច្ចុប្បន្នមធ្យម) ពីព្រោះលំហូរសាច់ ប្រាក់ជាមធ្យមបានឆ្លុះបញ្ចាំងរួចហើយនូវការសន្មតនានា អំពីភាព មិនប្រាកដប្រជានៃការខកខានមិនបានសងនាពេលអនាគត, ផ្ទុយ ទៅវិញ អត្រាអប្បហារដែលប្រដំប្រសងគ្នាជាមួយនឹង ហានិភ័យ ដែលមាននៅក្នុងលំហូរសាច់ប្រាក់ជាមធ្យម គួរតែត្រូវបានគេប្រើ។

(ឃ) ការសន្មត អំពីលំហូរសាច់ប្រាក់ និងអត្រាអប្បហារ គួរតែមានសង្គតិភាពផ្ទៃក្នុង។ ឧទាហរណ៍ លំហូរសាច់ប្រាក់ធម្មតា ដែលរួមមានទាំងផលប៉ះពាល់នៃអតិផរណាផង ត្រូវតែបានធ្វើអប្បហារតាមអត្រាមួយ ដែលរួមមានទាំងផលប៉ះពាល់ នៃអតិផរណា។ អត្រា ការប្រាក់ហានិរភ័យធម្មតារួមបញ្ចូលនូវផលប៉ះពាល់របស់អតិផរ ណា។ លំហូរសាច់ប្រាក់ពិត ដែលមិនរាប់បញ្ចូល នូវផលប៉ះពាល់ នៃអតិផរណា ត្រូវតែធ្វើអប្បហារតាមអត្រាមួយ ដែលមិនរាប់ បញ្ចូលនូវផលប៉ះពាល់នៃអតិផរណា ។ ស្រដៀងគ្នានេះ លំហូរ សាច់ប្រាក់ ក្រោយបង់ពន្ធត្រូវធ្វើអប្បហារដោយប្រើអត្រាការប្រាក់ក្រោយបង់ពន្ធ។ លំហូរសាច់ប្រាក់មុនបង់ពន្ធត្រូវធ្វើអប្បហារ តាមអត្រា ដែលមានសង្គតិភាពជាមួយនឹងលំហូរសាច់ប្រាក់ ទាំង នោះ ។

(ង) អត្រាអប្បហារត្រូវតែមានសង្គតិភាពជាមួយនឹងកត្តាសេដ្ឋកិច្ច ដែលពាក់ពន្ធ័របស់រូបិយវត្ថុដែលលំហូរសាច់ប្រាក់នោះប្រើ។

*ហានិភ័យនិងភាពមិនប្រាកដប្រជា*

១១៥ ការវាស់វែងតម្លៃសមស្របដោយប្រើបច្ចេកទេសតម្លៃបច្ចុប្បន្ន ត្រូវបានធ្វើឡើងក្រោមលក្ខខណ្ឌ នៃភាពមិនប្រាកដប្រជា ពីព្រោះលំហូរសាច់ប្រាក់ដែលប្រើគឺជាការប៉ាន់ស្មាន ជាជាងចំនួនដែលយើងដឹងពិតប្រាកដ។ នៅក្នុងករណីជាច្រើន ទាំងបរិមាណនិងពេលវេលានៃលំហូរសាច់ប្រាក់គឺមិនប្រាកដប្រជា។ ទោះបី ជាបរិមាណថេរតាមកិច្ចសន្យា ដូចជា ការទូទាត់ ប្រាក់កម្ចី គឺជាមិនប្រាកដប្រជា ប្រសិនបើមានហានិភ័យនៃការខកខាន មិនសង។

១១៦ អ្នកចូលរួមទីផ្សារជាទូទៅស្វែងរកការតបសង (មានន័យថា កម្រៃធានា ហានិភ័យ) សម្រាប់ការទទួលយកភាពមិនប្រាកដប្រជា ដែលមាននៅក្នុង លំហូរសាច់ប្រាក់របស់ទ្រព្យសកម្មឬបំណុល។ ការវាស់វែងតម្លៃសមស្រប ត្រូវរាប់បញ្ចូលកម្រៃធានាហានិភ័យដែលឆ្លុះបញ្ចាំងនូវបរិមាណ ដែលអ្នក ចូលរួមទីផ្សារនឹងទាមទារជាការតបសងសម្រាប់ភាពមិនប្រាកដប្រជាដែលមាននៅក្នុងលំហូរសាច់ប្រាក់។ បើមិនដូច្នោះទេ ការវាស់វែងនឹងមិន តំណាងយ៉ាងត្រឹមត្រូវនូវតម្លៃសមស្របឡើយ។នៅក្នុងករណីខ្លះ ការកំណត់ កម្រៃធានាហានិភ័យសមស្រប អាចជាការលំបាក។ ទោះជាយ៉ាងណា កម្រិតនៃភាពលំបាកតែឯកឯងមិនមែនជាហេតុផលគ្រប់គ្រាន់ ដើម្បី ដកចេញនូវកម្រៃធានាហានិភ័យឡើយ។

១១៧ បច្ចេកទេសតម្លៃបច្ចុប្បន្នខុសៗគ្នានៅក្នុងរបៀបនៃការកែសម្រួលហានិភ័យ និងនៅក្នុងប្រភេទលំហូរសាច់ប្រាក់ដែលប្រើ។ឧទាហរណ៍ៈ

(ក) បច្ចេកទេសនៃការកែសម្រួលអត្រាអប្បហារ (មើលកថាខណ្ឌ១១៨-១២២)ប្រើអត្រាអប្បហារដែលបានកែសម្រួលហានិភ័យរួច និង

ប្រើលំហូរសាច់ប្រាក់តាមកិច្ចសន្យាឬលំហូរសាច់ប្រាក់តាមការសន្យា ឬលំហូរសាច់ប្រាក់ដែលសមទំនងបំផុត។

(ខ) វិធីសាស្ត្រទី១នៃបច្ចេកទេសតម្លៃបច្ចុប្បន្នជាមធ្យម (មើលកថាខណ្ឌ ខ២៥) ប្រើលំហូរសាច់ប្រាក់ ដែលបានកែសម្រួលហានិភ័យរួច និង អត្រាការប្រាក់និរភ័យ ។

(គ) វីធិសាស្ត្រទី២នៃបច្ចេកទេសតម្លៃបច្ចុប្បន្នជាមធ្យម(មើលកថាខណ្ឌ ខ២៦) ប្រើលំហូរសាច់ប្រាក់មធ្យម ដែលមិនបាន កែសម្រួល ហានិភ័យ និងអត្រាការប្រាក់ ដែលបានកែសម្រួល ដើម្បីរាប់ បញ្ចូលកម្រៃធានាហានិភ័យ ដែលអ្នកចូលរួមទីផ្សារទាមទារ។ អត្រា នោះខុសគ្នាពីអត្រា ដែលបានប្រើនៅក្នុង បច្ចេកទេសនៃការកែ សម្រួលអត្រាអប្បហារ។

*បច្ចេកទេសនៃការកែសម្រួលអត្រាអប្បហារ*

ខ១៨ បច្ចេកទេស នៃការកែសម្រួលអត្រាអប្បហារប្រើលំហូរសាច់ប្រាក់តែមួយ ដែលកើតចេញពីលំដាប់នៃបរិមាណព្យាករណ៍ ដែលអាចមានថាតើ វាជាលំហូរសាច់ប្រាក់តាមកិច្ចសន្យា ឬលំហូរសាច់ប្រាក់តាមការសន្យាឬលំហូរសាច់ប្រាក់ ដែលសមទំនងបំផុត (ដូចជាករណីសញ្ញាប័ណ្ណ)។ នៅគ្រប់ករណីលំហូរសាច់ប្រាក់ទាំងនោះប្រកបដោយលក្ខខណ្ឌ ដែលអាស្រ័យលើការលេចឡើងនៃព្រឹត្តិការណ៍ដ៏ជាក់លាក់ (ឧ.លំហូរសាច់ប្រាក់តាមកិច្ចសន្យា ឬលំហូរសាច់ប្រាក់តាមការសន្យាឬលំហូរសាច់ប្រាក់ដែលសមទំនងបំផុតដែលបានមកពីសញ្ញាប័ណ្ណគឺប្រកបដោយលក្ខខណ្ឌ ដែលអាស្រ័យលើព្រឹត្តិការណ៍នៃការមិនមានការខកខានមិនបានសងរបស់កូនបំណុល)។ អត្រាអប្បហា ដែលប្រើនៅក្នុងបច្ចេកទេសនៃការកែសម្រួលអត្រាអប្បហារ

បានមកពីអត្រាចំណេញបានអង្កេតរបស់ទ្រព្យសកម្មឬបំណុលអាចប្រៀបធៀបបាន ដែលត្រូវបានជួញដូរនៅក្នុងទីផ្សារ។ យោងតាមនោះ លំហូរសាច់ប្រាក់តាមកិច្ចសន្យា ឬលំហូរសាច់ប្រាក់តាមការសន្យា ឬលំហូរសាច់ប្រាក់ដែលសមទំនងបំផុត ត្រូវបានធ្វើអប្បហារតាមអត្រាទីផ្សារប៉ាន់ស្មាន ឬបានអង្កេតសម្រាប់លំហូរសាច់ប្រាក់ប្រកបដោយលក្ខខណ្ឌ (មានន័យថា អត្រាចំណេញទីផ្សារ) ។

១១៩ បច្ចេកទេសនៃការកែសម្រួលអត្រាអប្បហារតម្រូវឱ្យមានការវិភាគទិន្នន័យទីផ្សារសម្រាប់ទ្រព្យសកម្ម ឬបំណុលអាចប្រៀបធៀបបាន ។ ភាពអាចប្រៀបធៀបបានត្រូវបានបង្កើតឡើងដោយការពិចារណានូវចរិតលក្ខណៈរបស់លំហូរសាច់ប្រាក់ (ឧ.ថាតើលំហូរសាច់ប្រាក់នោះ គឺជាលំហូរសាច់ប្រាក់តាមកិច្ចសន្យា ឬជាលំហូរសាច់ប្រាក់មិនតាមកិច្ចសន្យា ដែលហាក់ដូចជាឆ្លើយតបស្រដៀងគ្នាទៅនឹង ការផ្លាស់ប្តូរនៃលក្ខខណ្ឌសេដ្ឋកិច្ច) ក៏ដូចជា កត្តាផ្សេងៗទៀត (ឧ. ជំហរឥណទាន, ទ្រព្យដាក់បញ្ចាំ, រយៈពេល, កិច្ចព្រមព្រៀងមានដាក់កំហិត និងសន្ទនីយភាព)។ ម៉្យាងវិញទៀត ប្រសិនបើទ្រព្យសកម្ម ឬបំណុលអាចប្រៀបធៀបបានទោលមិនឆ្លុះបញ្ចាំងឱ្យបានត្រឹមត្រូវនូវហានិភ័យដែលមាននៅក្នុងលំហូរសាច់ប្រាក់របស់ទ្រព្យសកម្ម ឬបំណុលដែលត្រូវវាស់វែង វាអាចទទួលបាននូវអត្រាអប្បហារ ដោយប្រើទិន្នន័យរបស់ទ្រព្យសកម្មឬ បំណុលច្រើនដោយការរួមជាមួយនឹង ខ្សែកោងទិន្នផលនិរភ័យ (មានន័យថាវិធីសាស្រ្តបង្គរថែម)។

១២០ ដើម្បីពន្យល់ពីវិធីសាស្រ្តបង្គរថែម សន្មតថា ទ្រព្យសកម្ម A គឺជាទ្រព្យសកម្មដែលមានសិទ្ធិទទួលបាន តាមកិច្ចសន្យានូវទឹកប្រាក់ ៨០០ ឯកតារូបិយវត្ថុនៅក្នុងមួយឆ្នាំ (មានន័យថា គឺជាភាពមិនប្រាកដប្រជាដែលគ្មាន

កាលវេលាកំណត់)។ មានទីផ្សារស្រេចបាច់មួយសម្រាប់ទ្រព្យសកម្ម អាចប្រៀបធៀបបាន ហើយព័ត៌មានអំពីទ្រព្យសកម្ម ទាំងនោះ រួមមាន ទាំងព័ត៌មានថ្លៃផងអាចរកបាន។ នៃទ្រព្យសកម្ម អាចប្រៀបធៀបបាន ទាំងនោះ÷

(ក) ទ្រព្យសកម្ម B គឺជាទ្រព្យសកម្មដែលមានសិទ្ធិទទួលបានតាមកិច្ចសន្យានូវទឹកប្រាក់ ១២០០ ឯកតារូបិយវត្ថុ នៅក្នុងមួយឆ្នាំ និងមានថ្លៃទីផ្សារ ១០៨៣ ឯកតារូបិយវត្ថុ។ ដូច្នេះ អត្រាចំណេញគឺ (មានន័យថា អត្រាចំណេញទីផ្សារ រយៈពេលមួយឆ្នាំ)១០.៨% [(១២០០ ឯកតារូបិយវត្ថុ÷១០៨៣ ឯកតារូបិយវត្ថុ) - ១]។

(ខ) ទ្រព្យសកម្ម C គឺជាទ្រព្យសកម្មដែលមានសិទ្ធិទទួលបានតាមកិច្ចសន្យានូវទឹកប្រាក់ ៧០០ ឯកតារូបិយវត្ថុ នៅក្នុងរយៈពេលពីរឆ្នាំ និងមានថ្លៃទីផ្សារ ៥៦៦ ឯកតារូបិយវត្ថុ។ ដូច្នេះ អត្រាចំណេញគឺ (មានន័យថា អត្រាចំណេញទីផ្សារ រយៈពេលពីរឆ្នាំ) ១១.២% [(៧០០ ឯកតារូបិយវត្ថុ÷ ៥៦៦ ឯកតារូបិយវត្ថុ) - ១]។

(គ) ទ្រព្យសកម្មទាំងនោះ អាចប្រៀបធៀបបានជាមួយនឹងហានិភ័យដែលពាក់ពន្ធ័ (មានន័យថា ជាគំលាតរវាងផលចំណេញ ដែលអាចកើតមាននិងឥណទាន)។

ខ២១ ឈរលើមូលដ្ឋាននៃការកំណត់ពេលវេលានៃការទូទាត់តាមកិច្ចសន្យាដែលនឹងត្រូវទទួលពីទ្រព្យសកម្ម A ធៀបនឹងការកំណត់ពេលវេលា សម្រាប់ទ្រព្យសកម្មB និង ទ្រព្យសកម្មC (នោះគឺ រយៈពេលមួយឆ្នាំ សម្រាប់ ទ្រព្យសកម្ម B និងរយៈពេលពីរឆ្នាំសម្រាប់ទ្រព្យសកម្ម C), ទ្រព្យសកម្ម B ហាក់ដូចជាមានលក្ខណៈអាចប្រៀបធៀបបានច្រើនជាងទ្រព្យសកម្មA ។ ដោយ

ប្រើការទូទាត់តាមកិច្ចសន្យាដែលនឹងត្រូវទទួលសម្រាប់ទ្រព្យសកម្ម A (៨០០ ឯកតារូបិយវត្ថុ)និងអត្រាទីផ្សាររយៈពេលមួយឆ្នាំដែលបានមកពីទ្រព្យសកម្ម B (១០.៨%),តម្លៃសមស្របរបស់ទ្រព្យសកម្មA គឺ៧២២ ឯកតារូបិយវត្ថុ (៨០០ ឯកតារូបិយវត្ថុ ÷ ១.១០៨)។ ម៉្យាងវិញទៀត ក្នុង ករណីមិនមានព័ត៌មានទីផ្សាររបស់ទ្រព្យសកម្ម B, អត្រាទីផ្សាររយៈពេល មួយឆ្នាំអាចបានមកពីទ្រព្យសកម្ម C ដោយប្រើវិធីសាស្ត្របង្គរថែម ។ នៅ ក្នុងករណីនោះ អត្រាទីផ្សាររយៈពេលពីរឆ្នាំ ដែលបានបង្ហាញ ដោយទ្រព្យសកម្ម C (១១.២%) នឹងត្រូវបានកែសម្រួលទៅជា អត្រាទីផ្សាររយៈពេលមួយឆ្នាំវិញ ដោយប្រើរូបមន្តខ្សែកោងផលចំណេញហានិភ័យ។ ការវិភាគនិងព័ត៌មានបន្ថែមអាចត្រូវបានតម្រូវឱ្យមានដើម្បីកំណត់ថាតើ កម្រៃធានាហានិភ័យសម្រាប់រយៈពេលមួយឆ្នាំ និងរយៈពេលពីរឆ្នាំគឺដូចគ្នា។ ប្រសិនបើគេកំណត់ថា កម្រៃធានាហានិភ័យរយៈពេលមួយឆ្នាំនិងរយៈពេលពីរឆ្នាំមិនដូចគ្នា អត្រាទីផ្សាររយៈពេលពីរឆ្នាំនឹងត្រូវកែសម្រួលបន្ថែម សម្រាប់ផលប៉ះពាល់នោះ។

ខ២២ នៅពេលដែល បច្ចេកទេស នៃការកែសម្រួលអត្រាអប្បហារ ត្រូវបាន អនុវត្តសម្រាប់ការទទួលបានថេរឬការទូទាត់តើថេរ ការកែសម្រួល ហានិភ័យដែលមាននៅក្នុងលំហូរសាច់ប្រាក់របស់ទ្រព្យសកម្ម ឬបំណុលដែលវាស់វែងត្រូវបានដាក់បញ្ចូលនៅក្នុងអត្រាអប្បហារ ។ នៅក្នុងការអនុវត្តន៍ខ្លះ នៃបច្ចេកទេសកែសម្រួលអត្រាអប្បហារចំពោះលំហូរសាច់ប្រាក់ ដែលមិនមែនជាការទទួលបានថេរឬការទូទាត់ថេរ ការកែសម្រួលចំពោះលំហូរសាច់ប្រាក់អាចមានភាពចាំបាច់ ដើម្បីសម្រេចបានភាពអាចប្រៀបធៀបបានជាមួយនឹងទ្រព្យសកម្ម ឬបំណុលដែលអត្រា អប្បហារបានទទួល។

## *បច្ចេកទេសតម្លៃបច្ចុប្បន្នជាមធ្យម*

១២៣ បច្ចេកទេសតម្លៃបច្ចុប្បន្នមធ្យម ប្រើជាចំណុចចាប់ផ្តើម នៃសំណុំលំហូរសាច់ប្រាក់ ដែលតំណាងឱ្យមធ្យមទម្ងន់ ប្រូបាប៊ីលីតេ នៃលំហូរសាច់ប្រាក់ទាំងអស់ដែលអាចមាន (មានន័យថាសាច់ប្រាក់អនាគត)។ ការប៉ាន់ស្មានដែលបាននេះគឺស្រដៀងគ្នាទៅនឹងតម្លៃអនាគត, ដែលជាលក្ខខណ្ឌខាងស្ថិតិ, គឺជាមធ្យមទម្ងន់នៃតម្លៃរបស់អថេរដាច់បានជ្រើសរើសដោយចៃដន្យដោយគោរពតាមកម្រិតនៃប្រូបាប៊ីលីតេថាជាទម្ងន់។ ដោយសារតែរាល់ លំហូរសាច់ប្រាក់ដែលអាចកើតមានត្រូវបានគិតមធ្យមទម្ងន់ប្រូបាប៊ីលីតេ លំហូរសាច់ប្រាក់អនាគត គឺមិនប្រកបដោយលក្ខខណ្ឌ អាស្រ័យលើការ កកើតឡើងនៃព្រឹត្តិការណ៍ជាក់លាក់ណាមួយ (មិនមែនជាលំហូរសាច់ប្រាក់ដែលបានប្រើនៅក្នុងបច្ចេកទេសនៃការកែសម្រួលអត្រាអប្បហារ) ។

១២៤ នៅក្នុងការសម្រេចចិត្តវិនិយោគ អ្នកចូលរួមទីផ្សារ ដែលជាប្រភេទអ្នកមិនទទួលយកហានិភ័យ នឹងត្រូវរាប់បញ្ចូលហានិភ័យ ដែលសាច់ប្រាក់ជាក់ស្តែងអាចខុសគ្នាពីលំហូរសាច់ប្រាក់អនាគត។ ទ្រឹស្តីផលបត្រញែកដាច់ចេញពីគ្នានូវប្រភេទហានិភ័យទាំងពីរៈ

(ក) ហានិភ័យមិនមែនជាប្រព័ន្ធ (អាចបន្ថយបាន) ដែលជាហានិភ័យដែលកើតឡើងចំពោះទ្រព្យសកម្មឬបំណុលណាមួយ។

(ខ) ហានិភ័យជាប្រព័ន្ធ (មិនអាចបន្ថយបាន) ដែលជាហានិភ័យទូទៅចំពោះទ្រព្យសកម្មឬបំណុលជាមួយធាតុផ្សេងទៀតនៅក្នុងផលបត្រអាចបន្ថយហានិភ័យ ។

ទ្រឹស្តីផលបត្របានចែងថានៅក្នុងទីផ្សារដែលមានសមតាអ្នកចូលរួមទីផ្សារនឹងត្រូវបានតបសងតែចំពោះហានិភ័យជាប្រពន្ធ័ដែលមាន នៅក្នុងលំហូរសាច់ប្រាក់នោះ ។ (នៅក្នុងទីផ្សារដែលគ្មានអានុភាព ឬនៅក្រៅសមតា, ទម្រង់ផ្សេងទៀតនៃប្រាក់ចំណេញ ឬការតបសងអាចរកបាន ។)

ខ២៥ វិធីសាស្ត្រទី ១ នៃបច្ចេកទេសតម្លៃបច្ចុប្បន្នមធ្យមកែសម្រួល លំហូរសាច់ប្រាក់អនាគតរបស់ទ្រព្យសកម្មទៅនឹងហានិភ័យទីផ្សារ ដោយដកចេញនូវកម្រៃធានាហានិភ័យជាសាច់ប្រាក់ (មានន័យថា លំហូរសាច់ប្រាក់អនាគតបានកែសម្រួលហានិភ័យរួច)។ លំហូរសាច់ប្រាក់អនាគតបានកែសម្រួលហានិភ័យ រួចទាំងនោះ តំណាងឱ្យលំហូរសាច់ប្រាក់សមមូលជាក់លាក់ដែលត្រូវបានធ្វើអប្បហារតាមអត្រាការប្រាក់និរភ័យ។ លំហូរសាច់ប្រាក់សមមូលជាក់លាក់សំដៅដល់លំហូរសាច់ប្រាក់អនាគត (ដូចបានកំណត់អត្ថន័យ), បានកែសម្រួលចំពោះហានិភ័យ ដើម្បីឱ្យអ្នកចូលរួមទីផ្សារមិនខុសគ្នាចំពោះការជួញដូរលំហូរសាច់ប្រាក់ជាក់លាក់ សម្រាប់លំហូរសាច់ប្រាក់អនាគត។ ឧទាហរណ៍ ប្រសិនបើអ្នកចូលរួមទីផ្សារមានឆន្ទះក្នុងការជួញដូរសាច់ប្រាក់អនាគតចំនួន ១២០០ ឯកតារូបិយវត្ថុ សម្រាប់លំហូរសាច់ប្រាក់ជាក់លាក់ ចំនួន ១០០០ ឯកតារូបិយវត្ថុ, ១០០០ ឯកតារូបិយវត្ថុគឺជាសមមូលសាច់ប្រាក់ជាក់លាក់នៃ ១២០០ ឯកតារូបិយវត្ថុ (មានន័យថា ២០០ ឯកតារូបិយវត្ថុ តំណាងឱ្យកម្រៃធានាហានិភ័យជា សាច់ប្រាក់)។ នៅក្នុងករណីនោះអ្នកចូលរួមទីផ្សារ នឹងមិនមានភាពខុសគ្នា ទេក្នុងន័យនៃទ្រព្យសកម្មដែលកាន់កាប់។

ខ២៦ ផ្ទុយទៅវិញ វិធីសាស្ត្រទី ២នៃបច្ចេកទេសតម្លៃបច្ចុប្បន្នមធ្យម កែសម្រួលហានិភ័យទីផ្សារដោយបញ្ចូលកម្រៃធានាហានិភ័យ ទៅក្នុងអត្រាការប្រាក់

និរភ័យ។ ដោយយោងតាមនោះ លំហូរសាច់ប្រាក់អនាគត ត្រូវបានធ្វើ អប្បហារតាមអត្រាមួយដែលឆ្លើយតបទៅនឹងអត្រាអនាគតដែលជាប់ពាក់ពន្ធ័ជាមួយលំហូរសាច់ប្រាក់មធ្យមទម្ងន់ប្រូបាប៊ីលីតេ (មានន័យថា អត្រាចំណេញរំពឹងទុក)។ បណ្តាម៉ូឌែលដែលប្រើ សម្រាប់ការកំណត់ថ្លៃទ្រព្យសកម្មមានហានិភ័យ ដូចជាម៉ូឌែលនៃការកំណត់ថ្លៃទ្រព្យសកម្មវិនិយោគអាចត្រូវបានគេប្រើដើម្បីប៉ាន់ស្មានអត្រាចំណេញរំពឹងទុក។ដោយសារតែអត្រាអប្បហារ ដែលបានប្រើនៅក្នុងបច្ចេកទេសនៃការកែសម្រួលអត្រា អប្បហារគឺជាអត្រាចំណេញទាក់ទងនឹង លំហូរសាច់ប្រាក់មានលក្ខខណ្ឌ វាហាក់ដូចជាមានកម្រិតខ្ពស់ជាង អត្រាអប្បហារ ដែលបានប្រើនៅក្នុង វិធីសាស្ត្រទី ២ នៃបច្ចេកទេសតម្លៃបច្ចុប្បន្នមធ្យមដែលជាអត្រាចំណេញ រំពឹងទុកទាក់ទងនឹងលំហូរសាច់ប្រាក់អនាគតឬលំហូរសាច់ប្រាក់តាមមធ្យមទម្ងន់ប្រូបាប៊ីលីតេ។

១២៧ ដើម្បីពន្យល់វិធីសាស្ត្រទី ២ និងវិធីសាស្ត្រទី ២ សន្មតថា ទ្រព្យសកម្មមួយមានលំហូរសាច់ប្រាក់អនាគត ៧៨០ឯកតារូបិយវត្ថុក្នុងរយៈពេលមួយឆ្នាំដែលបានកំណត់ឈរលើមូលដ្ឋាននៃលំហូរសាច់ប្រាក់ដែលអាចកើតមាន និងប្រូបាប៊ីលីតេដូចបានបង្ហាញខាងក្រោម។អត្រាការប្រាក់និរភ័យ ដែលអាចអនុវត្តបានចំពោះលំហូរសាច់ប្រាក់មានរយៈពេលមួយឆ្នាំគឺ៥% ហើយកម្រៃធានាហានិភ័យទីផ្សារ សម្រាប់ទ្រព្យសកម្មមួយដែលមានហានិភ័យដូចគ្នាគឺ៣%។

| លំហូរសាច់ប្រាក់ | ប្រូបាប៊ីលីតេ | លំហូរសាច់ប្រាក់មធ្យមទម្ងន់ប្រូបាប៊ីលីតេ |
|---|---|---|
| ៥០០ ឯកតារូបិយវត្ថុ | ១៥% | ៧៥ ឯកតារូបិយវត្ថុ |

| | | |
|---|---|---|
| ៨០០ ឯកតារូបិយវត្ថុ | ៦០% | ៤៨០ ឯកតារូបិយវត្ថុ |
| ៩០០ ឯកតារូបិយវត្ថុ | ២៥% | ២២៥ ឯកតារូបិយវត្ថុ |
| លំហូរសាច់ប្រាក់រំពឹងទុក | | ៧៨០ ឯកតារូបិយវត្ថុ |

ខ២៨ នៅក្នុងការពន្យល់យ៉ាងសាមញ្ញនេះ លំហូរសាច់ប្រាក់អនាគត (៧៨០ ឯកតារូបិយវត្ថុ) តំណាងឱ្យមធ្យមទម្ងន់ប្រូបាប៊ីលីតេនៃលំហូរសាច់ប្រាក់ ដែលកើតមានទាំងបី។ នៅក្នុងស្ថានភាពជាក់លាក់ជាច្រើន អាចមាន លទ្ធភាពជាច្រើនបានកើតឡើង។ ទោះជាយ៉ាងណាដើម្បីអនុវត្តបច្ចេកទេស តម្លៃបច្ចុប្បន្នមធ្យមវាមិនមែនជានិច្ចកាលចាំបាច់ត្រូវរាប់បញ្ចូលនូវបំណែង ចែកនៃលំហូរសាច់ប្រាក់ ដែលអាចកើតមានដោយប្រើម៉ូឌែល និងបច្ចេក ទេសស្មុគ្រស្មាញនោះឡើយ។ ផ្ទុយទៅវិញ វាអាចបង្កើតចំនួនជាក់លាក់ មួយនៃសេណារីយ៉ូដាច់ឬប្រូបាប៊ីលីតេដាច់ដែលចាប់យកនូវលំដាប់ជួរ នៃ លំហូរសាច់ប្រាក់ដែលអាចកើតមាន។ ឧទាហរណ៍ អង្គភាព អាចប្រើលំហូរ សាច់ប្រាក់ពិតសម្រាប់ការិយបរិច្ឆេទអតីតកាលដែលពាក់ពន្ធ័, ដែលបាន កែសម្រួលសម្រាប់បម្រែបម្រួលតាមកាលៈទេសៈ ដែលកើតឡើងជាបន្តបន្ទាប់ (ឧ.បម្រែបម្រួលនៃកត្តាខាងក្រៅ ដែលរួមមាន លក្ខខណ្ឌសេដ្ឋកិច្ច ឬទីផ្សារ, និន្នាការអាជីវកម្មនិងការប្រកួតប្រជែង ក៏ដូចជាបម្រែបម្រួល នៃកត្តាខាងក្នុងដែលកំពុងមានផលប៉ះពាល់ដល់អង្គភាពយ៉ាងជាក់លាក់) ដោយរាប់បញ្ចូលនូវការសន្មតរបស់អ្នកចូលរួមទីផ្សារ។

១២៩ នៅក្នុងទ្រឹស្តីតម្លៃបច្ចុប្បន្ន(មានន័យថាតម្លៃសមស្រប) នៃលំហូរសាច់ប្រាក់របស់ទ្រព្យសកម្មគឺដូចគ្នា ទោះបីជាគេបានកំណត់ប្រើ វិធីសាស្ត្រទី ១ ឬ វិធីសាស្ត្រទី ២ ដូចខាងលក្រោមៈ

(ក) ប្រើវិធីសាស្ត្រទី ១, លំហូរសាច់ប្រាក់អនាគត ត្រូវបានកែសម្រួលសម្រាប់ហានិភ័យជាប្រព័ន្ធ (មានន័យថា ហានិភ័យទីផ្សារ)។ ខណៈដែលមិនមានទិន្នន័យទីផ្សារដែលបង្ហាញដោយផ្ទាល់នូវបរិមាណនៃការកែសម្រួលហានិភ័យ ការកែសម្រួលនបែបនោះអាចទទួលបានពីវិធីសាស្ត្រនៃការកំណត់ថ្លៃទ្រព្យសកម្មវិនិយោគ ដោយប្រើទ្រឹស្តីសមមូលជាក់លាក់។ ឧទាហរណ៍ ការកែសម្រួលហានិភ័យ (មានន័យថាកម្រៃធានាហានិភ័យជាសាច់ប្រាក់ចំនួន២២ឯកតារូបិយវត្ថុ) អាចត្រូវបានគេគណនា ដោយប្រើកម្រៃធានាហានិភ័យជាប្រពន្ធ័ចំនួន៣ភាគរយ (៧៨០ ឯកតារូបិយវត្ថុ - [៧៨០ ឯកតារូបិយវត្ថុ × (១.០៥/១.០៨)] ដែលធ្វើឱ្យយើងទទួលបានលំហូរសាច់ប្រាក់ រំពឹងទុកបានកែសម្រួលហានិភ័យរួចចំនួន ៧៥៨ ឯកតារូបិយវត្ថុ (៧៨០ ឯកតារូបិយវត្ថុ - ២២ឯកតារូបិយវត្ថុ)។ ៧៥៨ ឯកតារូបិយវត្ថុ គឺជាសមមូលជាក់លាក់នៃ ៧៨០ឯកតារូបិយវត្ថុនិងត្រូវបានធ្វើ អប្បហារតាមអត្រាការប្រាក់និរភ័យ (៥ភាគរយ)។តម្លៃបច្ចុប្បន្ន (មានន័យថាតម្លៃសមស្រប) របស់ទ្រព្យសកម្មគឺ ៧២២ ឯកតារូបិយវត្ថុ (៧៥៨ ឯកតារូបិយវត្ថុ/១.០៥)។

(ខ) ប្រើវិធីសាស្ត្រទី ២ លំហូរសាច់ប្រាក់អនាគតមិនត្រូវបានកែសម្រួលជាមួយនឹងហានិភ័យជាប្រពន្ធ័ (មានន័យថា ហានិភ័យទីផ្សារ)ទេ។ ផ្ទុយទៅវិញ ការកែសម្រួលសម្រាប់ហានិភ័យ នោះត្រូវបានដាក់

បញ្ចូលទៅក្នុងអត្រាអប្បហារ។ ដូច្នេះ លំហូរសាច់ប្រាក់អនាគត ត្រូវបានធ្វើអប្បហារ តាមអត្រារំពឹងទុក៨ភាគរយ (គឺ ៥ភាគរយ ជាអត្រាការប្រាក់និរភ័យ បូកនឹង ៣ភាគរយ ជាកម្រៃធានាហានិ- ភ័យ)។ តម្លៃបច្ចុប្បន្ន (មានន័យថាតម្លៃសមស្រប) របស់ទ្រព្យសកម្ម គឺ ៧២២ ឯកតារូបិយវត្ថុ(៧៨០ ឯកតារូបិយវត្ថុ/១.០៨)។

ខ៣០ នៅពេលប្រើ បច្ចេកទេសតម្លៃបច្ចុប្បន្នជាមធ្យម ដើម្បីវាស់វែងតម្លៃសមស្របវិធីសាស្ត្រទី ១ ឬវិធីសាស្ត្រទី ២ អាចត្រូវបានគេប្រើ។ ការជ្រើសរើសវិធីសាស្ត្រទី១ឬវិធីសាស្ត្រទី២នឹងអាស្រ័យលើហេតុការណ៍និងកាលៈទេសៈជាក់លាក់ចំពោះទ្រព្យសកម្ម ឬបំណុល ដែលត្រូវវាស់វែង ភាពគ្រប់គ្រាន់នៃទិន្នន័យដែលអាចរកបាន និងការវិនិច្ឆ័យដែលប្រើ។

## ការអនុវត្តន៍បច្ចេកទេសតម្លៃបច្ចុប្បន្ន ចំពោះបំណុល និងឧបករណ៍មូលធនផ្ទាល់របស់ម្ចាស់ដែលមិនកាន់កាប់ដោយបណ្តាភាគីផ្សេងៗ ដើម្បីធ្វើជាទ្រព្យសកម្ម(កថាខណ្ឌ ៤០ និង៤១)

ខ៣១ នៅពេលប្រើ បច្ចេកទេសតម្លៃបច្ចុប្បន្ន ដើម្បីវាស់វែងតម្លៃសមស្របរបស់បំណុលដែលមិនកាន់កាប់ដោយភាគីផ្សេងទៀត ដើម្បីធ្វើជាទ្រព្យសកម្ម (ឧ.បំណុលផុតអាណត្តិ) អង្គភាពត្រូវ ក្នុងចំណោមបញ្ហាផ្សេងៗ ប៉ាន់ស្មានលំហូរសាច់ប្រាក់ចេញអនាគតដែលអ្នកចូលរួមទីផ្សាររំពឹងថានឹងកើតឡើងនៅក្នុងការបំពេញកាតព្វកិច្ចបំណុល។ លំហូរសាច់ប្រាក់ចេញទាំងនោះ ត្រូវដាក់បញ្ចូលទៅក្នុងការរំពឹងទុករបស់អ្នកចូលរួមទីផ្សារអំពីការចំណាយ នៃការបំពេញកាតព្វកិច្ចបំណុល និងការកម្រៃតបសង ដែលអ្នកចូលរួម ទីផ្សារនឹងទាមទារសម្រាប់ការទទួលកាតព្វកិច្ចនោះ។កម្រៃតបសងដែល រួមមានផលដែលអ្នកចូលរួមទីផ្សារនឹងទាមទារ សម្រាប់ៈ

(ក) ការធ្វើសកម្មភាព(មានន័យថា តម្លៃនៃការបំពេញកាតព្វកិច្ចបំណុល, ឧ.ដោយប្រើធនធាន ដែលគេអាចប្រើបាន សម្រាប់សកម្មភាព ផ្សេងៗ) និង

(ខ) ការទទួលយកហានិភ័យ ដែលទាក់ទងនឹងកាតព្វកិច្ចបំណុលនោះ (មានន័យថា កម្រៃធានាហានិភ័យ ដែលឆ្លុះបញ្ចាំងនូវ ហានិភ័យដែលលំហូរសាច់ប្រាក់ចេញជាក់ស្តែងអាចខុសគ្នាពីលំហូរសាច់ ប្រាក់ចេញ រំពឹងទុក, មើលកថាខណ្ឌ ខ៣៣)។

ខ៣២ ឧទាហរណ៍ បំណុលដែលមិនមែនហិរញ្ញវត្ថុមិនរួមមានផលចំណេញ តាមកិច្ចសន្យា និងមិនមានអត្រាទីផ្សារដែលអាចអង្កេតបាន សម្រាប់បំណុលនោះ។នៅក្នុងករណីខ្លះ សមាសធាតុ នៃផលចំណេញដែលអ្នកចូលរួម ទីផ្សារនឹងទាមទារ នឹងមិនអាចញែកចេញដាច់ពីគ្នាបានឡើយ (ឧ.នៅពេលប្រើថ្លៃដែលអ្នកម៉ៅការបន្តជា ភាគីទីបី នឹងយកកម្រៃលើមូលដ្ឋានថេរមួយ)។ នៅក្នុងករណីខ្លះ អង្គភាពចាំបាច់ត្រូវប៉ាន់ស្មានសមាសធាតុទាំងនោះដាច់ដោយឡែកពីគ្នា (ឧ. នៅពេលប្រើថ្លៃដែលអ្នកម៉ៅការបន្តជាភាគីទីបីនឹងយកកម្រៃលើមូលដ្ឋាន ចំណាយបូកថែមចំណេញ ពីព្រោះអ្នកម៉ៅការបន្តនៅក្នុងករណីនេះ នឹងមិនទទួលយកហានិភ័យ នៃការផ្លាស់ប្តូរ នាពេលអនាគតនៃចំណាយឡើយ)។

ខ៣៣ អង្គភាព អាចដាក់បញ្ចូលកម្រៃធានាហានិភ័យ នៅក្នុងការវាស់វែងតម្លៃសមស្របរបស់បំណុលមួយ ឬឧបករណ៍ទ្រព្យម្ចាស់ផ្ទាល់ ដែលមិនត្រូវបានកាន់កាប់ដោយភាគីផ្សេងទៀត ដើម្បីធ្វើជាទ្រព្យសកម្ម តាមវិធីមួយ នៃវិធីនានាដូចខាងក្រោមៈ

(ក) ដោយការកែសម្រួល លំហូរសាច់ប្រាក់ (មានន័យថា ជាកំណើន បរិមាណ លំហូរសាច់ប្រាក់ចេញ) ឬ

(ខ) ដោយកែសម្រួលអត្រាការប្រាក់ដែលបានប្រើដើម្បីធ្វើអប្បហារលំហូរ សាច់ប្រាក់អនាគតឱ្យទៅជា តម្លៃបច្ចុប្បន្ន(មានន័យថា ជាការបន្ថយ អត្រាអប្បហារ)។

អង្គភាពត្រូវធានាថា វាត្រូវបានដាក់បញ្ចូលទ្វេរដង ឬបំបាត់ចោល ការកែ សម្រួលហានិភ័យ។ ឧទាហរណ៍ ប្រសិនបើ លំហូរសាច់ប្រាក់ប៉ាន់ស្មាន ត្រូវ បានបង្កើន ដើម្បីដាក់បញ្ចូលកម្រៃតបសងសម្រាប់ការទទួលយកនូវ ហានិ ភ័យដែលទាក់ទងនឹងកាតព្វកិច្ចបំណុលអត្រាអប្បហារ មិនត្រូវបាន កែ សម្រួលដើម្បីឆ្លុះបញ្ចាំងហានិភ័យនោះឡើយ។

## ធាតុចូលរបស់បច្ចេកទេសនៃការវាយតម្លៃ (កថាខណ្ឌ ៦៧-៧១)

ខ៣៤ ឧទាហរណ៍អំពីទីផ្សារដែលធាតុចូលអាចអង្កេតបាន សម្រាប់ទ្រព្យសកម្ម និងបំណុល (ឧ. ឧបករណ៍ហិរញ្ញវត្ថុ) រួមមានដូចខាងក្រោម:

(ក) *ទីផ្សារមូលបត្រ (Exchange Market)*។ នៅក្នុងទីផ្សារមូលបត្រ ថ្លៃ បិទទីផ្សារគឺអាចរកបាន ដោយងាយនិងជាតំណាងឱ្យតម្លៃសម ស្រប។ឧទាហរណ៍ គឺទីផ្សារមូលបត្រក្រុងឡុងដ៍ (London Stock Exchange)។

(ខ) *ទីផ្សារឈ្មួញអន្តរការី*។ នៅក្នុងទីផ្សារឈ្មួញអន្តរការី ឈ្មួញអន្តរការី ប្រុងប្រៀងជាស្រេចដើម្បីធ្វើការជួញដូរ (ទិញ ឬលក់ ក្នុងនាមខ្លួន ឯង), ដោយការផ្តល់ឱ្យនូវសន្ទនីយភាពដោយការប្រើដើមទុនរបស់ ខ្លួនដើម្បីរក្សាទុកសន្និធិសម្រាប់ការបង្កើតទីផ្សារ។ ជាធម្មតា ថ្លៃទិញ

និងថ្លៃលក់ (តំណាងនូវថ្លៃដែលឈ្មួញអន្តរការីនឹងទិញនិងថ្លៃដែលឈ្មួញអន្តរការីនឹងលក់)។ ទីផ្សារនៃការទិញ-លក់តាមបញ្ជរ (ដែលថ្លៃត្រូវបានរាយការណ៍ជាសាធារណៈ) គឺជាទីផ្សារឈ្មួញអន្តរការី ។ ទីផ្សារឈ្មួញអន្តរការីក៏កើតមាន សម្រាប់ទ្រព្យសកម្ម និងបំណុលមួយចំនួនផ្សេងទៀត ដែលរួមមាន ឧបករណ៍ហិរញ្ញវត្ថុ កុំម៉ូឌីធី និងទ្រព្យសកម្មរូបីយមួយចំនួន (ឧ. បរិក្ខារ)។

(គ) *ទីផ្សារឈ្មួញកម្រៃជើងសារ*។ នៅក្នុងទីផ្សារឈ្មួញកម្រៃជើងសារ ឈ្មួញកម្រៃជើងសារព្យាយាមធ្វើឱ្យស៊ីគ្នា រវាងអ្នកទិញនិងអ្នកលក់ ប៉ុន្តែមិនត្រៀមខ្លួន សម្រាប់ការជួញដូរនៅក្នុងនាមខ្លួនឯងឡើយ។ និយាយម្យ៉ាងទៀត ឈ្មួញកម្រៃជើងសារមិនប្រើប្រាស់ដើមទុនផ្ទាល់ខ្លួនដើម្បីរក្សាទុកសន្និធិសម្រាប់ការបង្កើតទីផ្សារឡើយ។ ឈ្មួញកម្រៃជើងសារដឹងពីថ្លៃស្នើរទិញនិងថ្លៃស្នើលក់ដែលបានទាមទារ ដោយភាគីនិមួយៗ ប៉ុន្តែភាគីនិមួយៗមិនដឹងអំពីការទាមទារថ្លៃរបស់ភាគីផ្សេងទៀតឡើយ។ថ្លៃនៃប្រតិបត្តិការដែលបានបញ្ចប់ ជួនកាលអាចរកបាន។ ទីផ្សារឈ្មួញកម្រៃជើងសាររួមមាន បណ្តាញទំនាក់ទំនងតាមប្រព័ន្ធអេឡិចត្រូនិច ដែលនៅក្នុងនោះ ការបញ្ជាទិញ និងការបញ្ជាលក់ត្រូវបានបន្ស៊ីគ្នា, និងទីផ្សារអចលនទ្រព្យ។

(ឃ) *ទីផ្សាររវាងភារប្បទាយីនិងភារប្បទាយី*។ នៅក្នុងទីផ្សាររវាងភារប្បទាយីនិងភារប្បទាយី បណ្តាប្រតិបត្តិការ ទាំងប្រតិបត្តិការដើមដំបូង និងប្រតិបត្តិការលក់បន្ត ត្រូវបានចចារដោយឯករាជ្យ ដោយមិនមានអន្តរការី។ ព័ត៌មានតិចតួចប៉ុណ្ណោះដែលត្រូវបានបង្ហាញ ជាសាធា- រណៈ។

**ធាតុចូលកម្រិត២(កថាខណ្ឌ ៨១-៨៥)**

ខ៣៥ ឧទាហរណ៍អំពី ធាតុចូលកម្រិត ២ សម្រាប់ទ្រព្យសកម្ម និងបំណុលមួយចំនួន មានដូចខាងក្រោមៈ

(ក) *ការដោះដូរ នៃអត្រាការប្រាក់ទទួលថេរ និងទូទាត់សងប្រែប្រួលដោយផ្អែកលើការដោះដូរ អត្រាការប្រាក់បានផ្តល់ឱ្យ ដោយអន្តរធនាគារក្រុងឡុងដ៍ (LIBOR)។* ធាតុចូលកម្រិត ២ គឺជាអត្រានៃការដោះដូរតាម LIBOR ប្រសិនបើ អត្រានោះអាចអង្កេតបាននៅ ក្នុងចន្លោះបានធ្វើសម្រង់ជាទូទៅសម្រាប់លក្ខខណ្ឌពេញលេញនៃការដោះដូរ។

(ខ) *ការដោះដូរ នៃអត្រាការប្រាក់ទទួលថេរ និងទូទាត់សងប្រែប្រួលដោយផ្អែកលើខ្សែរកោងទិន្នផលបានកំណត់ជារូបិយវត្ថុបរទេស។* ធាតុចូលកម្រិត ២ គឺជាអត្រានៃការដោះដូរដែលផ្អែកលើខ្សែរកោងទិន្នផលបានកំណត់ជារូបិយវត្ថុបរទេស ដែលអាចអង្កេតបាន តាមចន្លោះដែលបានធ្វើសម្រង់ជាទូទៅ សម្រាប់លក្ខខណ្ឌពេញលេញនៃការដោះដូរ។ នោះអាចជាករណី ប្រសិនបើលក្ខខណ្ឌ នៃការដោះដូរ គឺរយៈពេល ១០ឆ្នាំ ហើយ អត្រាការប្រាក់អាចអង្កេតបានតាមចន្លោះ ដែលបានធ្វើសម្រង់ជាទូទៅសម្រាប់រយៈពេល ៩ឆ្នាំ ដោយផ្តល់ឱ្យ នូវការធ្វើវិចារណកិច្ចសមហេតុផលនៃខ្សែរកោងទិន្នផលសម្រាប់រយៈពេល១០ឆ្នាំ នឹងមិនមានសារៈសំខាន់ សម្រាប់ការវាស់វែងតម្លៃសមស្របនៃការដោះដូរទាំងស្រុងរបស់វា។

(គ) *ការដោះដូរ នៃអត្រាការប្រាក់ទទួលថេរ និងទូទាត់សងប្រែប្រួល ដោយផ្អែកលើ អត្រាការប្រាក់មូលដ្ឋាន របស់ធនាគារណាមួយ។* ធាតុចូលកម្រិត ២ គឺជាអត្រាការប្រាក់មូលដ្ឋានដែលបានមកតាម រយៈការធ្វើវិចារណកិច្ច ប្រសិនបើ តម្លៃដែលបានធ្វើវិចារណកិច្ច ត្រូវបានអះអាងដោយទិន្នន័យទីផ្សារដែលអាចអង្កេតបាន ឧទាហរ- ណ៍ តាមរយៈសម្ពន្ធ័ស្ទួល ជាមួយនឹងអត្រាការប្រាក់ ដែលអាច អង្កេតបានទៅតាមលក្ខខណ្ឌពេញលេញនៃការដោះដូរ។

(ឃ) *ជម្រើសពិសេសរយៈពេលបីឆ្នាំនៃសន្លឹកហ៊ុនដែលបានជួញដូរ នៅក្នុងទីផ្សារមូលបត្រ។*ធាតុចូលកម្រិត២ គឺជាភាពមិនអាចព្យាករណ៍បានដែលជាប់ទាក់ទិននៃសន្លឹកហ៊ុន ដែលបានមកពីការធ្វើវិចារ- ណកិច្ចស្មើនឹងរយៈពេលបីឆ្នាំ ប្រសិនបើលក្ខខណ្ឌទាំងពីរខាងក្រោម កើត ឡើង:

(១) ថ្លៃរយៈពេលមួយឆ្នាំនិងថ្លៃរយៈពេលពីរឆ្នាំសម្រាប់ ជម្រើសពិសេសរបស់សន្លឹកហ៊ុនអាចអង្កេតបាន។

(២) ភាពមិនអាចព្យាករណ៍បាន ដែលជាប់ទាក់ទិន ដែលបានធ្វើវិចារណកិច្ចនៃជម្រើសពិសេសរយៈ បីឆ្នាំ ត្រូវបានអះអាងតាមរយៈទិន្នន័យទីផ្សារដែលអាចអង្កេតបានតាមលក្ខខណ្ឌពេញលេញនៃជម្រើសពិសេសនោះ។

នៅក្នុងករណីនោះភាពមិនអាចព្យាករណ៍បានដែលជាប់ទាក់ទិន អាចទទួលបានតាមរយៈការធ្វើវិចារណកិច្ចពីភាពមិនអាចព្យាករបាន ដែលជាប់ទាក់ទិននៃជម្រើសពិសេសរយៈពេលមួយឆ្នាំនិងជម្រើសពិសេសរយៈពេល ពីរឆ្នាំ តាមសន្លឹកហ៊ុន និងបានអះអាងដោយភាពមិនអាចព្យាករបានដែលជាប់ទាក់ទិន

សម្រាប់ជម្រើសពិសេសរយៈពេលបីឆ្នាំផ្អែកលើសន្លឹកហ៊ុនរបស់អង្គភាព ដែលអាចប្រៀបធៀបបាន ដោយបានកំណត់ថាសម្ពន្ធ័ស្ទូលជាមួយនឹងភាពមិនអាចព្យាករណ៍បានដែលជាប់ទាក់ទិនសម្រាប់រយៈពេលពីរឆ្នាំ និងមួយឆ្នាំ ត្រូវបានបង្កើតឡើង។

(ង) *កិច្ចព្រមព្រៀងអាជ្ញាប័ណ្ណ* ។ សម្រាប់កិច្ចព្រមព្រៀងអាជ្ញាប័ណ្ណមួយដែលត្រូវបានទទួលនៅក្នុងការរួមបញ្ចូលអាជីវកម្ម ហើយត្រូវបានចចារថ្មីៗជាមួយនឹងភាគីមិនពាក់ពន្ធ័មួយដោយអង្គភាព ដែលបានទិញ (អង្គភាពនៃកិច្ចព្រមព្រៀងអាជ្ញាប័ណ្ណ) ធាតុចូលកម្រិត ២ គឺជាអត្រានៃកម្រៃបង់សិទ្ធិនៅក្នុងកិច្ចសន្យាជាមួយនឹងភាគីមិន ពាក់ពន្ធ័ នៅដំណាក់កាលដំបូងនៃកិច្ចព្រមព្រៀង។

(ច) *សន្និធិផលិតផលសម្រេចតាមដេប៉ូលក់រាយ*។សន្និធិផលិតផលសម្រេចដែលទទួលបានពីការរួមបញ្ចូលអាជីវកម្ម ធាតុចូលកម្រិត ២ គឺជាថ្លៃសម្រាប់អតិថិជននៅក្នុងទីផ្សារលក់រាយ ឬថ្លៃ សម្រាប់អ្នកលក់រាយនៅក្នុងទីផ្សារលក់ដុំ ដែលបានកែសម្រួល សម្រាប់ភាពខុសគ្នារវាងលក្ខខណ្ឌនិងទីតាំងរបស់សន្និធិ និងសន្និធិអាចប្រៀបធៀបបាន (មានន័យថា ស្រដៀងគ្នា) ហេតុដូច្នេះ ការវាស់វែងតម្លៃសមស្របឆ្លុះបញ្ចាំងថ្លៃ ដែលនឹងទទួលបាន នៅក្នុងប្រតិបត្តិការលក់ សន្និធិទៅឱ្យអ្នកលក់រាយផ្សេងទៀត ដែលនឹងបញ្ចប់ប្រតិបត្តិការ លក់ដែលតម្រូវមុន។ជាទ្រឹស្តី ការវាស់វែងតម្លៃសមស្របនឹងដូចគ្នាទោះបីជាថាតើ ការកែសម្រួលត្រូវបានធ្វើឡើងចំពោះថ្លៃលក់រាយ (ការធ្លាក់ចុះ) ឬចំពោះថ្លៃលក់ដុំ (ការកើនឡើង)។ ជាទូទៅថ្លៃដែល

តម្រូវឱ្យមានយ៉ាងតិច នូវបរិមាណនៃការកែសម្រួលជាអញ្ញាថាវត្ថុ គួរតែត្រូវបានគេប្រើសម្រាប់ការវាស់វែងតម្លៃសមស្រប។

(ឆ) អគារទុកសម្រាប់ប្រើ ។ ធាតុចូលកម្រិត ២ គឺជាថ្លៃក្នុងមួយម៉ែត្រការេ របស់អគារ (មេគុណនៃការវាយតម្លៃ) ដែលបានមកពីទិន្នន័យ ទីផ្សារដែលអាចអង្កេតបាន ឧ.មេគុណដែលបានមកពីថ្លៃនានានៅក្នុងប្រតិបត្តិការបានអង្កេត ទាក់ទងនឹងអគារអាចប្រៀបធៀបបាន (មានន័យថា ស្រដៀងគ្នា)នៅទីតាំងស្រដៀងគ្នា)

(ជ) *អង្គភាពបង្កើតសាច់ប្រាក់* ។ ធាតុចូលកម្រិត ២ គឺជាមេគុណនៃការវាយតម្លៃ (ឧ.មេគុណនៃប្រាក់ចំណេញឬថ្លៃលក់នៅក្នុងប្រតិបត្តិការបានអង្កេតទាក់ទងនឹងអាជីវកម្មអាចប្រៀបធៀបបាន (មានន័យថាស្រដៀងគ្នា) ដោយរាប់បញ្ចូល កត្តាប្រតិបត្តិការ កត្តាទីផ្សារកត្តាហិរញ្ញវត្ថុ ឬកត្តាមិនមែនហិរញ្ញវត្ថុ)។

**ធាតុចូលកម្រិត៣** (កថាខណ្ឌ ៨៦-៩០)

ខ៣៦ ឧទាហរណ៍នៃធាតុចូលកម្រិត៣សម្រាប់ទ្រព្យសកម្មនិងបំណុលមួយចំនួនដែលរួមមានដូចខាងក្រោមៈ

(ក) *ការដោះដូររូបិយវត្ថុមានកាលបរិច្ឆេទវែង។* ធាតុចូលកម្រិត ៣ គឺជាអត្រាការប្រាក់ គិតជារូបិយវត្ថុជាក់លាក់ណាមួយ ដែលមិនអាចអង្កេតបាន និងមិនអាចអះអាងបានដោយទិន្នន័យទីផ្សារ តាមចន្លោះដែលបានធ្វើសម្រង់ជាទូទៅ ឬបើមិនដូច្នេះទេ គឺសម្រាប់តាមលក្ខខណ្ឌពេញលេញនៃការដោះដូរ។ អត្រាការប្រាក់ជាការដោះដូរ

រូបិយវត្ថុគឺជាអត្រានៃការដោះដូរដែលបានគណនាពីខ្សែរកោងទិន្ន-ផលរបស់ប្រទេសនានាដែលពាក់ព័ន្ធ ។

(ខ) ជម្រើសពិសេសរយៈពេលបីឆ្នាំ លើសន្លឹកហ៊ុន ដែលជួញដូរលើ ទីផ្សារមូលបត្រ។ ធាតុចូលកម្រិត៣ គឺភាពងាយប្រែប្រួលពី អតីត-កាល មានន័យថា ភាពងាយប្រែប្រួលរបស់សន្លឹកហ៊ុន ដែលបានមកពីថ្លៃអតីតកាលរបស់សន្លឹកភាគហ៊ុន។ ជាធម្មតា ភាពងាយប្រែប្រួលអតិតកាលមិនតំណាងឱ្យការរំពឹងទុករបស់អ្នកចូលរួមទីផ្សារបច្ចុនប្បន្ន អំពីភាពងាយប្រែប្រួលអនាគតឡើយ បើទោះបីជាវាគឺ ជាព័ត៌មានតែមួយគត់ដែលមានសម្រាប់ថ្លៃនៃជម្រើសពិសេសមួយ។

(គ) *ការដោះដូរអត្រាការប្រាក់*។ ធាតុចូលកម្រិត៣គឺជាការកែសម្រួលចំពោះថ្លៃយល់ស្របគ្នា (មិនមែនការដេញថ្លៃ) សម្រាប់ការដោះដូរដែលបានបង្កើតដោយប្រើទិន្នន័យដែលមិនអាចអង្កេតបានដោយផ្ទាល់និងមិនអាចត្រូវបានអះអាងដោយទិន្នន័យទីផ្សារ ដែលអាចអង្កេតបាន។

(ឃ) *បំណុលផុតអាណត្តិ ដែលបានទទួលយក នៅក្នុងការរួមបញ្ចូលអាជីវកម្ម*។ធាតុចូលកម្រិត ៣ គឺជាការប៉ាន់ស្មានបច្ចុប្បន្ន ដោយប្រើទិន្នន័យផ្ទាល់ខ្លួនរបស់អង្គភាពអំពីលំហូរសាច់ប្រាក់ចេញអនាគតដែលនឹងត្រូវសងដើម្បីបំពេញកាតព្វកិច្ចបំណុល និងជាការតបសងដែលអ្នកចូលរួមទីផ្សារនឹងទាមទារ សម្រាប់ការទទួលយកកាតព្វកិច្ចបំណុលសម្រាប់ការដូរយកទ្រព្យសកម្មនោះ) ប្រសិនបើ មិនមានព័ត៌មានដែលបង្ហាញថាអ្នកចូលរួមទីផ្សារនឹងប្រើការសន្មតផ្សេងៗ។ ធាតុចូលកម្រិត៣នឹងត្រូវបានប្រើនៅក្នុងបច្ចេកទេសតម្លៃបច្ចុប្បន្ន

រួមជាមួយនឹង ធាតុចូលផ្សេងទៀត, ឧទាហរណ៍ អត្រាការប្រាក់និរភ័យបច្ចុប្បន្ន ឬអត្រាការប្រាក់និរភ័យ ដែលបានកែសម្រួល ឥណទានរួច ប្រសិនបើផលប៉ះពាល់របស់ជំហរឥណទាន លើតម្លៃ សមស្របរបស់បំណុល ត្រូវបានឆ្លុះបញ្ចាំង នៅក្នុងអត្រាអប្បហារ ជាជាងនៅក្នុងការប៉ាន់ស្មានលំហូរសាច់ប្រាក់ចេញអនាគត។

(ង) *អង្គភាពបង្កើតសាច់ប្រាក់*។ ធាតុចូលកម្រិត ៣ គឺជាការព្យាករណ៍ហិរញ្ញវត្ថុ (ឧ. លំហូរសាច់ប្រាក់ ឬចំណេញ ឬខាត) ដែលបានធ្វើឡើង ដោយប្រើទិន្នន័យផ្ទាល់ខ្លួនរបស់អង្គភាព ប្រសិនបើមិនមានព័ត៌មានដែលបង្ហាញថា អ្នកចូលរួមទីផ្សារនឹងប្រើការសន្មតផ្សេង។

## ការវាស់វែងតម្លៃសមស្រប នៅពេលដែលទំហំឬកម្រិតសកម្មភាពរបស់ទ្រព្យសកម្មឬបំណុលមានការថយចុះយ៉ាងខ្លាំង

ខ៣៧ តម្លៃសមស្របរបស់ទ្រព្យសកម្ម ឬបំណុលអាចត្រូវរងផលប៉ះពាល់ នៅពេលដែល មានការថយចុះយ៉ាងខ្លាំងនូវបរិមាណ ឬសកម្មភាពសម្រាប់ទ្រព្យសកម្ម ឬបំណុលនោះធៀបនឹងសកម្មភាពទីផ្សារធម្មតា របស់ទ្រព្យសកម្មឬបំណុល (ទ្រព្យសកម្មឬបំណុលស្រដៀងគ្នា)។ ដើម្បីកំណត់ថាដោយឈរលើភស្តុតាងដែលមាន តើមានការថយចុះយ៉ាងខ្លាំងនៃទំហំ និងកម្រិតសកម្មភាពរបស់ទ្រព្យសកម្ម ឬបំណុល អង្គភាពត្រូវវាយតម្លៃភាពមានសារៈសំខាន់និងភាពជាប់ពាក់ពន្ធ័នៃកត្តាដូចខាងក្រោមៈ

(ក) មានប្រតិបត្តិការថ្មីៗតិចតួច។

(ខ) ការធ្វើសម្រង់ថ្លៃមិនត្រូវបានបង្កើតឡើងដោយប្រើព័ត៌មានបច្ចុប្បន្ន។

(គ) ការធ្វើសម្រង់ថ្លៃប្រែប្រួលយ៉ាងខ្លាំងពីពេលមួយទៅពេលមួយទៀត ឬ នៅក្នុងចំណោមអ្នកបង្កើតទីផ្សារ (ឧ.ទីផ្សារឈ្មួញកម្រៃជើងសារមួយចំនួន)។

(ឃ) សន្ទស្ស ដែលពីមុនមកមានសម្ពន្ធ័ស្ទួល ជាមួយនឹងតម្លៃសមស្រប របស់ទ្រព្យសកម្មឬបំណុលត្រូវបានបង្ហាញថាលែងមានសម្ព័ន្ធស្ទួល ជាមួយនឹងសូចនាករថ្មីៗ នៃតម្លៃសមស្របសម្រាប់ទ្រព្យសកម្ម ឬ បំណុលនោះ។

(ង) មានការកើនឡើងយ៉ាងខ្លាំង នៅក្នុងកម្រៃធានាហានិភ័យសន្ទនីយភាពដែលជាប់ពាក់ពន្ធ័, សូចនាករទិន្នផល ឬលទ្ធផល (ដូចជា អត្រាបទល្មើស ឬភាពធ្ងន់ធ្ងរនៃការខាតបង់) សម្រាប់ប្រតិបត្តិការដែលបានអង្កេត ឬថ្លៃដែលបានធ្វើសម្រង់ នៅពេលប្រៀបធៀបជាមួយនឹងការប៉ាន់ស្មានសាច់ប្រាក់អនាគតរបស់អង្គភាព ដោយរាប់បញ្ចូលនូវរាល់ព័ត៌មាន ដែលមានទាំងអស់អំពីហានិភ័យឥណទាន និងហានិភ័យមិនមែនលទ្ធផលរបស់ទ្រព្យសកម្មឬបំណុល ។

(ច) មានគំលាតថ្លៃលក់-ថ្លៃទិញធំ ឬមានការកើនឡើងយ៉ាងខ្លាំងនៅក្នុងគំលាតថ្លៃលក់-ថ្លៃទិញ។

(ឆ) មានការធ្លាក់ចុះយ៉ាងខ្លាំងនៅក្នុងសកម្មភាពទីផ្សារសម្រាប់ ការបោះផ្សាយថ្មី ឬមិនមានទីផ្សារសម្រាប់ការបោះផ្សាយថ្មី (ទីផ្សារទីមួយ) សម្រាប់ទ្រព្យសកម្មឬបំណុល ឬទ្រព្យសកម្មឬបំណុលស្រដៀងគ្នា។

(ជ) មានព័ត៌មានតិចតួច បានបោះផ្សាយជាសាធារណៈ (ឧ.សម្រាប់ប្រតិបត្តិការដែលកើតឡើង នៅក្នុងទីផ្សាររវាងភាគីឯករាជ្យ និង ភាគីឯករាជ្យ)។

១៣៨ ប្រសិនបើអង្គភាពសន្និដ្ឋានថាមានការថយចុះយ៉ាងខ្លាំងនូវទំហំ និងកម្រិតនៃសកម្មភាព សម្រាប់ទ្រព្យសកម្ម ឬបំណុលធៀបនឹងសកម្មភាពទីផ្សារធម្មតា សម្រាប់ទ្រព្យសកម្មឬបំណុល (ឬទ្រព្យសកម្មឬបំណុលស្រដៀងគ្នា) ការវិភាគបន្ថែមទៀតនៃប្រតិបត្តិការ ឬថ្លៃសម្រង់គឺជាការចាំបាច់។ ការ ថយចុះនូវទំហំឬកម្រិតសកម្មភាពដោយខ្លួនឯង អាចមិនបង្ហាញថាថ្លៃ ប្រតិបត្តិការ ឬថ្លៃសម្រង់នោះ មិនតំណាងឱ្យតម្លៃសមស្របឬថាប្រតិបត្តិការនៅក្នុងទីផ្សារនោះមិនមានលក្ខណៈជាប្រព័ន្ធិក ។ ទោះជាយ៉ាង ណា ប្រសិនបើអង្គភាពកំណត់ថាថ្លៃប្រតិបត្តិការ ឬថ្លៃសម្រង់ មិនតំណាង ឲ្យតម្លៃសមស្រប (ឧ.អាចមានប្រតិបត្តិការដែលមិនមែនជា ប្រព័ន្ធិក) កាកែសម្រួលចំពោះថ្លៃប្រតិបត្តិការ ឬថ្លៃសម្រង់នឹងមានភាព ចាំបាច់ ប្រសិនបើអង្គភាពប្រើថ្លៃទាំងនោះជាមូលដ្ឋាន សម្រាប់ការវាស់វែង តម្លៃសមស្រប ហើយការកែសម្រួលនោះអាចមានសារៈសំខាន់ ចំពោះ ការវាស់វែងតម្លៃសមស្របទាំងស្រុង។ ការកែសម្រួលអាចចាំបាច់ផងដែរ នៅក្នុងកាលៈទេសៈផ្សេង (ឧ.នៅពេលដែលថ្លៃ សម្រាប់ទ្រព្យសកម្ម ស្រដៀងគ្នាទាមទារការកែសម្រួលជាដុំកំភួនដើម្បីធ្វើឱ្យវាអាចប្រៀបធៀប បានទៅនឹងទ្រព្យសកម្មដែលនឹងធ្វើការវាស់វែង ឬនៅពេលដែលថ្លៃមិន ល្អ) ។

១៣៩ ស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុនេះមិនបញ្ជាក់ម្រូវនូវវិធីសាស្រ្តសម្រាប់ធ្វើការកែសម្រួល ជាដុំកំភួនចំពោះថ្លៃប្រតិបត្តិការ ឬថ្លៃសម្រង់។ មើលកថាខណ្ឌ៦១-៦៦ និងកថាខណ្ឌ ខ៥-ខ១១ សម្រាប់ការពិភាក្សា អំពីការប្រើប្រាស់បច្ចេកទេសនៃការវាយតម្លៃនៅពេលវាស់វែងតម្លៃសមស្រប។ មិន ចំពោះបច្ចេកទេស នៃការវាយតម្លៃ ដែលបានប្រើណាមួយឡើយ អង្គភាពត្រូវដាក់បញ្ចូលការកែសម្រួលហានិភ័យសមរម្យ រួមមានកម្រៃ ធានា

ហានិភ័យដែលឆ្លុះបញ្ចាំងបរិមាណដែលអ្នកចូលរួមទីផ្សារនឹងទាមទារ ជាការតបសងចំពោះភាពមិនប្រាកដប្រជា ដែលមាននៅក្នុងលំហូរសាច់ ប្រាក់របស់ទ្រព្យសកម្ម ឬបំណុល (មើលកថាខណ្ឌ១១៧)។ ផ្ទុយទៅវិញ ការវាស់វែងមិនតំណាងដោយស្មោះត្រង់នូវតម្លៃសមស្របឡើយ។ នៅក្នុងករណីខ្លះការកំណត់នូវការកែសម្រួលហានិភ័យសមរម្យអាចជាការលំបាក។ ទោះជាយ៉ាងណាក៏ដោយ កម្រិតនៃការលំបាកតែឯងមិនមែនជាមូលដ្ឋានគ្រប់គ្រាន់ដើម្បីដកចេញការកែសម្រួលហានិភ័យឡើយ។ ការកែសម្រួលហានិភ័យត្រូវតែឆ្លុះបញ្ចាំង នូវប្រតិបត្តិការប្រព័ន្ធិករវាងអ្នកចូលរួមទីផ្សារនាកាលបរិច្ឆេទនៃការវាស់វែងតាមលក្ខខណ្ឌទីផ្សារបច្ចុប្បន្ន។

១៤០ ប្រសិនបើ មានការធ្លាក់ចុះជាដុំកំភួន នូវទំហំនិងកម្រិត នៃសកម្មភាពសម្រាប់ទ្រព្យសកម្ម ឬបំណុល ការផ្លាស់ប្តូរបច្ចេកទេសនៃការវាយតម្លៃ ឬការប្រើបច្ចេកទេសនៃការវាយតម្លៃចំរុះអាចមានភាពសមស្រប (ឧ.ការប្រើវិធីសាស្ត្រទីផ្សារ និងបច្ចេកទេសតម្លៃបច្ចុប្បន្ន)។ នៅពេលថ្លឹងថ្លែងនូវការចង្អុលបង្ហាញ នៃតម្លៃសមស្រប ដែលជាលទ្ធផលបានមកពី ការប្រើបច្ចេកទេសវាយតម្លៃចំរុះ អង្គភាពត្រូវពិចារណានូវភាពសមហេតុសមផលនៃលំដាប់នៃការវាស់វែងតម្លៃសមស្រប។ កម្មវត្ថុ គឺត្រូវកំណត់ចំណុចនៅក្នុងលំដាប់ដែល ជាតំណាងល្អបំផុតនៃតម្លៃសមស្របតាមលក្ខខណ្ឌទីផ្សារធម្មតា។ លំដាប់ដ៏ទូលាយនៃការវាស់វែងតម្លៃសមស្របអាចជាការចង្អុលបង្ហាញថាការវិភាគបន្ថែមទៀតអាចនឹងមានភាពចាំបាច់។

១៤១ នៅពេលដែលមានការការធ្លាក់ចុះជាដុំកំភួននូវទំហំនិងកម្រិត នៃសកម្មភាពសម្រាប់ទ្រព្យសកម្ម ឬបំណុល កម្មវត្ថុនៃការវាស់វែងតម្លៃសមស្របនៅរក្សាដដែល។ តម្លៃសមស្របគឺថ្លៃដែលនឹងត្រូវទទួលបានពីការលក់

ទ្រព្យសកម្មឬថ្លៃដែលនឹងត្រូវបង់ចំពោះការផ្ទេរបំណុលនៅក្នុងប្រតិបត្តិការប្រព័ន្ធិក (មានន័យថាមិនមែនជម្រះបញ្ជីដោយបង្ខំ ឬការលក់ចេញដោយ បង្ខំឡើយ) រវាងអ្នកចូលរួមទីផ្សារនៅកាលបរិច្ឆេទ នៃការវាស់វែងក្រោម លក្ខខណ្ឌទីផ្សារបច្ចុប្បន្ន។

ខ៤២ ការប៉ាន់ស្មានថ្លៃដែលអ្នកចូលរួមទីផ្សារធ្វើប្រតិបត្តិការនាកាលបរិច្ឆេទ នៃការវាស់វែងក្រោមលក្ខខណ្ឌទីផ្សារបច្ចុប្បន្ន ប្រសិនបើមានការថយចុះ ជាដុំកំភួននូវទំហំ ឬកម្រិតសកម្មភាពរបស់ទ្រព្យសកម្ម ឬបំណុលអាស្រ័យ លើហេតុការណ៍និងកាលៈទេសៈនៅកាលបរិច្ឆេទនៃការវាស់វែងនិងទាមទារនូវការវិនិច្ឆ័យ។ ចេតនារបស់អង្គភាពដើម្បីកាន់កាប់ទ្រព្យសកម្ម ឬដើម្បីទូទាត់ ឬបំពេញកាតព្វកិច្ចបំណុល មិនមានការពាក់ពន្ធ័នៅពេលវាស់វែងតម្លៃសមស្របពីព្រោះតម្លៃសមស្របគឺជាការវាស់វែងផ្អែកលើទីផ្សារ, មិនមែនជាការវាស់វែងផ្អែកលើអង្គភាពជាក់លាក់ណាមួយឡើយ។

## កំណត់អត្តសញ្ញាណកម្មប្រតិបត្តិការដែលមិនមានជាប្រតិបត្តិការប្រព័ន្ធិក

ខ៤៣ ការកំណត់ថាតើ ប្រតិបត្តិការមួយជាប្រព័ន្ធិក (ឬមិនមែនជាប្រព័ន្ធិក) មានការលំបាកជាង ប្រសិនបើការថយចុះជាដុំកំភួននូវទំហំ ឬកម្រិតសកម្មភាពសម្រាប់ទ្រពក្យសកម្ម ឬបំណុលធៀបនឹងសកម្មភាពទីផ្សារធម្មតាសម្រាប់ទ្រព្យសកម្ម ឬបំណុល (ឬទ្រព្យសកម្ម ឬបំណុលស្រដៀងគ្នា)។ នៅក្នុងកាលៈទេសៈបែបនេះ វាមិនសមរម្យទេដើម្បីសន្និដ្ឋានថារាល់ប្រតិបត្តិការទាំងអស់នៅក្នុងទីផ្សារនោះមិនមែនជាប្រតិបត្តិការប្រព័ន្ធិក(មានន័យថាការជម្រះបញ្ជីដោយបង្ខំ ឬការលក់ចេញដោយបង្ខំ)។ បណ្តាកាលៈទេសៈ

ដែលអាចបង្ហាញថាប្រតិបត្តិការមួយមិនមែនជាប្រព័ន្ធិករួមមាន ដូចខាងក្រោម៖

(ក) មិនមានការប្រឈមគ្រប់គ្រាន់ទៅនឹង ទីផ្សារសម្រាប់ការិយបរិច្ឆេទមុនកាលបរិច្ឆេទ នៃការវាស់វែង ដើម្បីអនុញ្ញាតឱ្យមានសកម្មភាពម៉ាឃីតទីងដែលជាធម្មតានិងជាទម្លាប់ សម្រាប់ប្រតិបត្តិការទាក់ទងនឹងទ្រព្យសកម្មឬបំណុលក្រោមលក្ខខណ្ឌទីផ្សារបច្ចុប្បន្ន ។

(ខ) មានរយៈពេលសកម្មភាពម៉ាឃីតទីងជាធម្មតានិងជាទម្លាប់ ប៉ុន្តែអ្នកលក់បានលក់ទ្រព្យសកម្មឬបំណុលទៅអ្នកចូលរួមទីផ្សារទោល។

(គ) អ្នកស្ថិតក្នុង ឬនៅក្បែរស្ថានភាពនៃការក្ស័យធន ឬភាពជាអ្នកទទួល (មានន័យថា អ្នកលក់មានវិបត្តិ)

(ឃ) អ្នកលក់ត្រូវបានតម្រូវឱ្យលក់ដើម្បីបំពេញការតម្រូវ តាមផ្លូវច្បាប់ ឬនិយ័តកម្ម (មានន័យថា អ្នកលក់ត្រូវបានបង្ខំ)។

(ង) ថ្លៃប្រតិបត្តិការ គឺជាមិនមែនជាផ្នែកសំខាន់នៅពេលប្រៀបធៀបជាមួយនឹងប្រតិបត្តិការថ្មីផ្សេងៗទៀតសម្រាប់ទ្រព្យសកម្មឬបំណុលដូចគ្នា ឬទ្រព្យសកម្មឬបំណុលស្រដៀងគ្នា។

អង្គភាព ត្រូវវាយតម្លៃកាលទេសៈ ដើម្បីកំណត់ថាតើ ផ្អែកលើទម្ងន់នៃ ភស្តុតាងដែលមាន ប្រតិបត្តិការគឺជាប្រតិបត្តិការប្រព័ន្ធិក។

ខ៤៤ អង្គភាព ត្រូវវាតម្លៃរាល់កត្តាខាងក្រោមនៅពេលវាស់វែងតម្លៃសមស្រប ឬប៉ាន់ស្មានកម្រៃធានាហានិភ័យ៖

(ក) ប្រសិនបើភស្តុតាងបង្ហាញថា ប្រតិបត្តិការមិនមែនជាប្រតិបត្តិការប្រព័ន្ធិក អង្គភាពត្រូវជំនួសបន្តិច ប្រសិនបើមាននូវទម្ងន់ (ដោយ

ប្រៀបធៀបជាមួយនឹង ការចង្អុលបង្ហាញផ្សេងទៀត នៃតម្លៃសម ស្រប) លើថ្លៃប្រតិបត្តិការនោះ។

(ខ) ប្រសិនបើ ភស្តុតាងបង្ហាញថាប្រតិបត្តិការជាប្រតិបត្តិការប្រព័ន្ធិក អង្គភាពត្រូវរាប់បញ្ចូលនូវថ្លៃប្រតិបត្តិការនោះ។ បរិមាណនៃទម្ងន់ ដែលបានដាក់លើថ្លៃប្រតិបត្តិការនោះ នៅពេលប្រៀបធៀបជាមួយ នឹងការចង្អុលបង្ហាញផ្សេងៗនៃតម្លៃសមស្របនឹងអាស្រ័យលើហេតុ ការណ៍និងកាលៈទេសៈ ដូចខាងក្រោម៖

(១) ទំហំនៃប្រតិបត្តិការ

(២) ភាពអាចប្រៀបធៀបបាននៃប្រតិបត្តិការទៅនឹងទ្រព្យសកម្ម ឬបំណុលដែលកំពុងត្រូវបានវាស់វែង។

(៣) ភាពនៅកៀងរបស់ប្រតិបត្តិការទៅនឹងកាលបរិច្ឆេទ នៃការ វាស់វែង។

(គ) ប្រសិនបើ អង្គភាពមិនមានព័ត៌មានគ្រប់គ្រាន់ ដើម្បីសន្និដ្ឋានថាតើ ប្រតិបត្តិការមួយគឺជាប្រតិបត្តិការប្រព័ន្ធិកអង្គភាព ត្រូវរាប់បញ្ចូល នូវថ្លៃប្រតិបត្តិការនោះ។ ទោះជាយ៉ាងណា ថ្លៃប្រតិបត្តិការនោះអាច មិនតំណាងឲ្យតម្លៃសមស្រប (មានន័យថា ថ្លៃប្រតិបត្តិការមិន ចាំបាច់ថាជាមូលដ្ឋានតែមួយគត់ ឬមូលដ្ឋានចំបងសម្រាប់ការវាស់ វែងតម្លៃសមស្រប ឬប៉ាន់ស្មានកម្រៃធានាហានិភ័យទីផ្សារ)។ នៅ ពេល អង្គភាព មិនមានព័ត៌មានគ្រប់គ្រាន់ ដើម្បីសន្និដ្ឋានថាតើ ប្រតិបត្តិការមួយគឺជាប្រតិបត្តិការប្រព័ន្ធិក អង្គភាពត្រូវដាក់ទម្ងន់ តិចតួចលើប្រតិបត្តិការទាំងនោះ នៅពេលប្រៀបធៀបជាមួយនឹង

ប្រតិបត្តិការផ្សេងទៀត ដែលត្រូវបានគេដឹងថា ជាប្រតិបត្តិការប្រព័ន្ធិក។

អង្គភាពមិនចាំបាច់ខិតខំខ្លាំងពេកទេនៅក្នុងការកំណត់ថាតើ ប្រតិបត្តិការមួយជាប្រតិបត្តិការប្រព័ន្ធិក ឬយ៉ាងណា ប៉ុន្តែ អង្គភាពមិនត្រូវបោះបង់ចោលនូវព័ត៌មានដែលមានរួចជាស្រេចហើយនោះទេ។ នៅពេលដែល អង្គភាពគជាភាគីមួយនៃប្រតិបត្តិការ គេសន្មតជាមុនថាខ្លួនមានព័ត៌មាន គ្រប់គ្រាន់ដើម្បីសន្និដ្ឋានថាប្រតិបត្តិការនោះជាប្រតិបត្តិការប្រព័ន្ធិក។

## ការប្រើថ្លៃសម្រង់ដែលបានផ្តល់ឱ្យដោយបណ្តាភាគីទីបី

ខ៤៥ ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុនេះមិនច្រានចោលជាមុន នូវការប្រើថ្លៃសម្រង់ដែលបានផ្តល់ដោយភាគីទីបីនោះឡើយ ដូចជា សេវាកម្មកំណត់ថ្លៃ ឬឈ្មួញកម្រៃជើងសារ ប្រសិនបើ អង្គភាពបានកំណត់ថាថ្លៃសម្រង់ ដែលផ្តល់ឱ្យដោយភាគីទាំងនោះ ត្រូវបានបង្កើតឡើង ដោយអនុលោម តាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុនេះ។

ខ៤៦ ប្រសិនបើ មានការធ្លាក់ចុះជាដុំកំភួននូវបរិមាណ ឬកម្រិតនៃសកម្មភាពសម្រាប់ទ្រព្យសកម្មឬបំណុល អង្គភាពត្រូវវាយតម្លៃថាតើថ្លៃសម្រង់ ដែលបានផ្តល់ឱ្យដោយភាគីទីបីត្រូវបានបង្កើតឡើង ដោយប្រើព័ត៌មានបច្ចុប្បន្នបានឆ្លុះបញ្ចាំងប្រតិបត្តិការប្រព័ន្ធិក ឬបច្ចេកទេសវាយតម្លៃបានឆ្លុះបញ្ចាំងការសន្មតរបស់អ្នកចូលរួមទីផ្សារ (រួមទាំងការសន្មតអំពីហានិភ័យ) ដែរ ឬទេ។ នៅក្នុងការថ្លឹងថ្លែង អំពីថ្លៃសម្រង់ថាជាធាតុចូលមួយ នៅក្នុងការ វាស់វែងតម្លៃសមស្របអង្គភាពដាក់ទម្ងន់តិច(នៅពេលប្រៀបធៀបជាមួយ ការចង្អុលបង្ហាញផ្សេងទៀតនៃតម្លៃសមស្របដែលឆ្លុះបញ្ចាំងនូវលទ្ធផល នៃ

ប្រតិបត្តិការ) លើការធ្វើសម្រង់ដែលមិនឆ្លុះបញ្ចាំងលទ្ធផលនៃប្រតិបត្តិ-ការ។

ខ៤៧ ជាងនេះទៀត ចរិតនៃការធ្វើសម្រង់ (ឧ.ថាតើការធ្វើសម្រង់ គឺជាថ្លៃដែលមានការចង្អុលបង្ហាញ ឬជាសំណើដេញថ្លៃ) ត្រូវតែបានរាប់បញ្ចូល នៅពេលថ្លឹងថ្លែង លើភស្តុតាង ដែលមានជាមួយនឹងទម្ងន់កាន់តែច្រើននឹងត្រូវផ្តល់ឱ្យចំពោះសម្រង់ថ្លៃដែលបានផ្តល់ដោយបណ្តា ភាគីទីបី ដែល នឹងតំណាងឱ្យសំណើដេញថ្លៃ ។

**ឧបសម្ពន្ធ័ គ**

**កាលបរិច្ឆេទអន្តរកាលនិងកាលបរិច្ឆេទចូលជាធរមាន**

*ឧបសម្ពន្ធ័នេះគឺជាផ្នែកមួយនៃស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ និងមានសិទ្ធិអំណាយដូចគ្នានឹងផ្នែកផ្សេងទៀតនៃស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ។*

គ១ អង្គភាព ត្រូវអនុវត្តស្តង់ដារបាយការណ៍ទាក់ទង នឹងហិរញ្ញវត្ថុអន្តរជាតិនេះ សម្រាប់ការិយបរិច្ឆេទចាប់ផ្តើមនៅថ្ងៃទី ១ ឬបន្ទាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០១៣។ ការអនុវត្តន៍មុនត្រូវបានអនុញ្ញាតិ។ ប្រសិនបើ អង្គភាព អនុវត្តស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុនេះសម្រាប់ការិយបរិច្ឆេទ មុន អង្គភាពត្រូវលាតត្រដាងហេតុការណ៍នោះ។

គ២ ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនេះ ត្រូវតែបានអនុវត្តជាអនាគត ខណៈពេលចាប់ផ្តើមការិយបរិច្ឆេទប្រចាំឆ្នាំ ដែលអង្គភាពបានអនុវត្តលើកដំបូង។

គ៣ ការតម្រូវសម្រាប់ ការលាតត្រដាង នៃស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនេះមិនចាំបាច់ត្រូវអនុវត្តក្នុងទម្រង់ព័ត៌មានប្រៀបធៀបដែលបានផ្តល់ឱ្យដោយបណ្តាការិយបរិច្ឆេទមុនពេលនៃការអនុវត្តន៍លើកដំបូងនៃស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនេះឡើយ។

ក្រុមប្រឹក្សាជាតិគណនេយ្យ
ក.ជ.គ គឺជាស្ថាប័នបញ្ញត្តិករនៃវិស័យគណនេយ្យ និងសវនកម្មនៅកម្ពុជា
អាសយដ្ឋាន៖ ផ្លូវ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
អ៊ីម៉ែល៖ info@naccambodia.gov.kh | គេហទំព័រ៖ www.naccambodia.gov.kh

ក.ជ.គ រក្សាសិទ្ធិក្នុងការកែប្រែស្តង់ដាទៅតាមការវិវត្តក្នុងក្របខណ្ឌអន្តរជាតិ